ធនាគារជាតិនៃកម្ពុជា
ប្រាក់រៀល ស្ថិរភាព អភិវឌ្ឍន៍

# ព្រឹត្តិបត្រប្រចាំត្រីមាស




## លេខ ៤៨

## ត្រីមាសទី ៣ ឆ្នាំ២០១៦

ចេញផ្សាយតាមប្រកាសលេខ ធ៦-០១១-១២៣ ប្រ.ក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១

បោះពុម្ពផ្សាយដោយ

# ធនាគារជាតិ នៃ កម្ពុជា

| | | |
|---|---|---|
| អាសយដ្ឋាន | : | ២២-២៤ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា |
| ប្រអប់សំបុត្រ | : | ២៥ |
| ទូរស័ព្ទ | : | (៨៥៥) ២៣ ៧២២ ៥៦៣ |
| ទូរសារ | : | (៨៥៥) ២៣ ៤២៦ ១១៧ |
| គេហទំព័រ | : | www.nbc.org.kh |

*********

Published by

# National Bank of Cambodia

| | | |
|---|---|---|
| Address | : | 22-24 Preah Norodom Blvd.<br>Phnom Penh, Cambodia |
| P.O.BOX | : | 25 |
| Phone | : | (855) 23 722 563 |
| FAX | : | (855) 23 426 117 |
| Website | : | www.nbc.org.kh |



| គណៈកម្មការត្រួតពិនិត្យ | | Review Commission | |
|---|---|---|---|
| - ឯកឧត្តម ថា យ៉ាវ | ប្រធាន | H.E. Tha Yao | Chairman |
| - ឯកឧត្តម ស៊ុំ សន្និសិទ្ធ | និពន្ធនាយក | H.E. Dr. Sum Sannisith | Chief Editor |

# អារម្ភកថា



## ឯកឧត្តម ជា ចាន់តូ
## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

***ប្រិយមិត្តអ្នកអានជាទីមេត្រី !***

ខ្ញុំមានក្តីសោមនស្សរីករាយក្រៃលែង និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ប្រិយមិត្តអ្នកអានទាំងអស់ ដែលបន្តគាំទ្រការចេញផ្សាយព្រឹត្តិបត្រប្រចាំត្រីមាសរបស់ធនាគារជាតិនៃកម្ពុជា ដែលជាកម្រងព័ត៌មានថ្មីៗអំពីការបន្តបំពេញមុខងារ និងតួនាទីរបស់ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធររូបិយវត្ថុ និងជាអាណាព្យាបាលលើប្រព័ន្ធធនាគារកម្ពុជាសំដៅរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឱ្យរីកចម្រើនប្រកបដោយចីរភាព បរិយាប័ន្ន និងសមធម៌។

នៅក្នុងព្រឹត្តិបត្រប្រចាំត្រីមាសទី៣ ឆ្នាំ២០១៦នេះ មានរួមបញ្ចូលនូវព័ត៌មាន ព្រឹត្តិការណ៍និងព័ត៌មានសំខាន់ៗមួយចំនួនត្រូវបានសម្រិតសម្រាំងដើម្បីយកមកដាក់បញ្ចូល ដូចជា៖ i/.សន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅឆមាសទី២ របស់ធនាគារជាតិនៃកម្ពុជា ii/.ការបណ្តុះបណ្តាលធនធានមនុស្សរបស់ធនាគារជាតិនៃកម្ពុជាផ្ទៃក្នុង និងក្រៅប្រព័ន្ធ iii/.ការបន្តជំរុញការស្រាវជ្រាវនៅកម្ពុជា និង iv/.ព័ត៌មានអំពីសកម្មភាពការងារផ្សេងៗទៀតរបស់ធនាគារជាតិនៃកម្ពុជា។ ជាពិសេសក្នុងព្រឹត្តិបត្រនេះ ក៏មានដាក់បញ្ចូលនូវអត្ថបទស្រាវជ្រាវរួមគ្នារវាងធនាគារជាតិនៃកម្ពុជា និងសហព័ន្ធស្រូវអង្ករកម្ពុជា អំពីការផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្មផងដែរ។ អត្ថបទនេះ បានផ្តោតលើការស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមនៅក្នុងវិស័យកសិកម្ម ដូចជា ការពឹងផ្អែកលើអាកាសធាតុ កង្វះទីផ្សារ និងការចំណាយថ្លៃដើមខ្ពស់ក្នុងការផលិតស្រូវអង្ករ ទន្ទឹមនឹងការមិនទាន់បំពេញលក្ខខណ្ឌបានគ្រប់គ្រាន់ដើម្បីទទួលបានហិរញ្ញប្បទានពីគ្រឹះស្ថានធនាគារ។

***ប្រិយមិត្តអ្នកអានជាទីមេត្រី!***

នៅឆ្នាំ២០១៦នេះ សេដ្ឋកិច្ចពិភពលោកបន្តមានកំណើន ប៉ុន្តែមានល្បឿនយឺតជាងឆ្នាំមុន និងមានភាពមិនស្មើសាច់នៅតាមតំបន់។ កំណើនទាបជាងមុននេះ ជាចម្បងដោយសារការថយចុះសកម្មភាពសេដ្ឋកិច្ចនៅប្រទេសអភិវឌ្ឍន៍ បន្ទាប់ពីការបោះឆ្នោតចាកចេញរបស់អង់គ្លេសពីសហភាពអឺរ៉ុប និងកំណើនទាបជាងការរំពឹងទុកនៅសហរដ្ឋអាមេរិក។ ទោះជាយ៉ាងនេះក្តី សេដ្ឋកិច្ចប្រទេសកំពុងងើបឡើង និងប្រទេសកំពុងអភិវឌ្ឍន៍មានការកើនឡើងបន្តិច ជាពិសេសនៅតំបន់មជ្ឈិមបូព៌ា ខណៈដែលនៅតំបន់អាស៊ីបន្តមានស្ថិរភាពរឹងមាំ។ ទន្ទឹមនេះ សេដ្ឋកិច្ចពិភពលោកក៏ប្រឈមនឹង

ភាពមិនច្បាស់លាស់ផងដែរ ទាក់ទិននឹងការចាកចេញរបស់អង់គ្លេសពីសហភាពអឺរ៉ុប និងការកើនឡើងនៃគោលនយោបាយគាំពារពាណិជ្ជកម្ម។

ទោះស្ថិតក្នុងបរិការណ៍ដែលសេដ្ឋកិច្ចពិភពលោកមានកំណើនយឺត សេដ្ឋកិច្ចកម្ពុជាបន្តសម្រេចបានកំណើនខ្ពស់ក្នុងអត្រា៧% ស្មើនឹងឆ្នាំ២០១៥ដែរ ដែលគាំទ្រដោយកំណើនរឹងមាំនៃការនាំចេញសម្លៀកបំពាក់និងស្បែកជើង កំណើនក្នុងវិស័យសំណង់និងអចលនទ្រព្យ និងវិស័យទេសចរណ៍ ស្របពេលដែលវិស័យកសិកម្មបានកើនឡើងជាងមុនបន្តិច។ ស្របពេលនេះដែរ កម្ពុជាបន្តទទួលបានលំហូរចូលមូលធនជាបន្តបន្ទាប់ ដែលនាំឱ្យជញ្ជីងទូទាត់កម្ពុជាមានអតិរេក និងរួមចំណែកគរពូនទុនបម្រុងអន្តរជាតិរបស់កម្ពុជាឱ្យកើនឡើង និងអាចទ្រទ្រង់ការនាំចេញទំនិញ និងសេវាកាន់តែខ្ពស់រហូតដល់ប្រមាណ ៥ខែ នៅឆ្នាំនេះ។ រីឯស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ក៏បន្តមានលំនឹងល្អប្រសើរ ដោយអតិផរណាមានកម្រិតទាបអាចគ្រប់គ្រងបានប្រមាណ ២,៩% ប៉ុណ្ណោះ ហើយអត្រាប្តូរប្រាក់មានស្ថិរភាពក្នុងរង្វង់ ៤.០៥០ រៀលក្នុងមួយដុល្លារអាមេរិក។

ទន្ទឹមនឹងការរីកចម្រើននៃសេដ្ឋកិច្ច វិស័យធនាគារក៏បន្តអភិវឌ្ឍជាបន្តបន្ទាប់ និងមានភាពរឹងមាំផងដែរ។ ទ្រព្យសកម្ម ប្រាក់បញ្ញើ និងឥណទានរបស់វិស័យនេះទាំងមូលបានបន្តកើនឡើង ហើយបណ្តាញសាខារបស់គ្រឹះស្ថានក៏ត្រូវបានពង្រីកបន្ថែមផងដែរ។ ស្ថិតក្នុងបរិការណ៍ដែលវិស័យនេះ មានការអភិវឌ្ឍឥតឈប់ឈរ និងមានភាពប្រទាក់ក្រឡាកាន់តែខ្ពស់ ធនាគារជាតិនៃកម្ពុជាបានបន្តការត្រួតពិនិត្យយ៉ាងខ្ជាប់ខ្ជួននិងយកចិត្តទុកដាក់ជាប្រចាំ និងថែមទាំងដាក់ចេញនូវបទប្បញ្ញត្តិប្រុងប្រយ័ត្នមួយចំនួនដើម្បីកាត់បន្ថយហានិភ័យ ក៏ដូចជាបង្កើនភាពរឹងមាំនៃវិស័យនេះស្របតាមឧត្តមានុវត្តអន្តរជាតិផងដែរ។ ជាក់ស្តែង សុខមាលភាពប្រព័ន្ធធនាគារមានភាពរឹងមាំល្អប្រសើរ ដែលឆ្លុះបញ្ចាំងតាមរយៈកម្រិតខ្ពស់នៃអនុបាតសាធនភាពនិងសន្ទនីយភាព និងកម្រិតទាប នៃអនុបាតឥណទានមិនដំណើរការ។

ធនាគារជាតិនៃកម្ពុជា នឹងបន្តខិតខំប្រឹងប្រែងក្នុងការរក្សាស្ថិរភាពថ្លៃ និងអត្រាប្តូរប្រាក់រួមនឹងធានាការអភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុប្រកបដោយភាពរឹងមាំ ស្របតាមគោលនយោបាយដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ដើម្បីរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។ ខ្ញុំសង្ឃឹមថា បន្ទាប់ពីបានអានព្រឹត្តិបត្រលេខ ៤៨ នេះ ប្រិយមិត្តអ្នកអានទាំងអស់នឹងអាចទទួលបាននូវព័ត៌មានជាច្រើនទាក់ទងនឹងបច្ចុប្បន្នភាពនៃប្រព័ន្ធធនាគារកម្ពុជា សកម្មភាពការងាររបស់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា និងខ្លឹមសារនៃឯកសារស្រាវជ្រាវលើការរួមចំណែករបស់វិស័យធនាគារក្នុងការគាំទ្រវិស័យកសិកម្ម។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា និងមន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់ ព្រមទាំងក្រសួងស្ថាប័ន និងដៃគូអភិវឌ្ឍន៍ទាំងអស់ដែលបានសហការ និងរួមចំណែកសម្រេចបាននូវសមិទ្ធផលនាពេលកន្លងមក ហើយខ្ញុំសង្ឃឹមថាប្រពៃណីដ៏ល្អនេះនឹងបន្តនាំមកនូវសមិទ្ធផលថ្មីៗបន្ថែមទៀតក្នុងពេលអនាគត។

ខ្ញុំសូមប្រសិទ្ធពរជ័យ សិរីសួស្តី ជូនដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្ត អ្នកអានទាំងអស់ សូមប្រកបតែសេចក្តីសុខ ទទួលបានជោគជ័យគ្រប់ភារកិច្ច និងជួបប្រទះតែពុទ្ធពរ ទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**

# មាតិកា

ទំព័រ


- អារម្ភកថា ........................................................................................................ i-ii
- សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងពិធីសម្ពោធបើកឱ្យដំណើរការជាផ្លូវការ ធនាគារឯកទេស អាស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ភីអិលស៊ី Asia-Pacific Development Specialized Bank Plc. រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៦ (ជាភាសាខ្មែរ)................................................................................. ១
- សុន្ទរកថាគន្លឹះ ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ក្នុងពិធីបើកសិក្ខាសាលាស្តីពី "ផ្តើមនិយាយពីបំណុលវ័ណ្ឌកឥឡូវនេះ" សណ្ឋាគារភ្នំពេញ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ (ជាភាសាខ្មែរ)................................................................... ៣
- សុន្ទរកថាឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងឱកាសសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៦ របស់ធនាគារជាតិនៃកម្ពុជានៅសាខាធនាគារជាតិនៃកម្ពុជា ខេត្តកំពង់ចាម ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៦ (ជាភាសាខ្មែរ)................................................................................. ៧
- សុន្ទរកថា ឯកឧត្តម ទេសាភិបាល និងជាប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ក្នុងពិធីបើកកិច្ចប្រជុំជាមួយក្រុមការងារវាយតម្លៃអញ្ញមញ្ញរបស់ APG នៅថ្ងៃទី២៣-២៥ ខែសីហា ឆ្នាំ២០១៦ (ភាសាខ្មែរ)........... ១៨
- សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជាថ្លែងក្នុងឱកាសបើកវគ្គគូលៃនលើកទី៤ កម្រិតមូលដ្ឋាន ស្តីពី"ភាពជាអ្នកដឹកនាំ"នៅធនាគារជាតិនៃកម្ពុជា ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ (ជាភាសាខ្មែរ)................................................................... ២០
- សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់ប្រកាសនីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារ ជំនាន់ទី២១ ២២ និង ២៣ នៅសាលមហោស្រពកោះពេជ្រ ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៦ (ជាភាសាខ្មែរ)..................... ២៣
- សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងពិធីសម្ពោធទីស្នាក់ការកណ្តាលថ្មី ធនាគារ សៃហ្គន - ហាណូយ កម្ពុជា លីមីតធីត នៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ (ជាភាសាខ្មែរ)........................................................ ២៨

| | |
|---|---|
| ➢ សេចក្តីថ្លែងការណ៍រួម រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា (ជាភាសាខ្មែរ)........................................................................................... | ៣១ |
| ➢ សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជាថ្លែងក្នុងពិធីបើកវេទិកាការងារក្នុងវិស័យធនាគារ "Careers in Banking Forum" នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦(ជាភាសាខ្មែរ)............................................................ | ៣២ |
| ➢ សុន្ទរកថាឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជាថ្លែងក្នុងឱកាសបិទវគ្គគូលែនលើកទី ៤ កម្រិតមូលដ្ឋាន ស្តីពី "ភាពជាអ្នកដឹកនាំ" នៅធនាគារជាតិនៃកម្ពុជា ថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០១៦ (ជាភាសាខ្មែរ)................................................................. | ៣៦ |
| ➢ ឯកសារសិក្សាស្រាវជ្រាវ ស្តីពីការផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្ម (ភាសាខ្មែរ)........... | ៤០ |
| ➢ តារាងអត្រាប្តូរប្រាក់ប្រចាំខែ (ភាសាខ្មែរនិងអង់គ្លេស) ................................................ | ៥៣ |
| ➢ តារាងអត្រាការប្រាក់លើប្រាក់បញ្ញើ (ភាសាខ្មែរនិងអង់គ្លេស) ....................................... | ៥៥ |
| ➢ តារាងអត្រាការប្រាក់លើប្រាក់កម្ចី (ភាសាខ្មែរនិងអង់គ្លេស)............................................ | ៥៧ |
| ➢ បញ្ជីឈ្មោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ (ជាភាសាខ្មែរនិងអង់គ្លេស) ............................ | ៥៩ |
| ➢ បញ្ជីឈ្មោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង NGO (ជាភាសាខ្មែរនិងអង់គ្លេស) ........................ | ៦៤ |
| ➢ ប្រព័ន្ធធនាគារកម្ពុជា (ភាសាខ្មែរនិងអង់គ្លេស) ......................................................... | ៧៦ |
| ➢ រូបថតសកម្មភាពថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា...................................................... | ៧៨-៩០ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

# សន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងពិធីសម្ពោធបើកឱ្យដំណើរការជាផ្លូវការ
## ធនាគារឯកទេស អាស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ភីអិលស៊ី

Asia-Pacific Development Specialized Bank Plc.

**រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៦**

៚៚៚✵៛៛៛

**សូមគោរព ៖**

- ឯកឧត្តម ឡាវ ម៉េងឃីន សមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ
- លោក វង្ស ពេជ្រ ប្រធានក្រុមប្រឹក្សាភិបាល ធនាគារឯកទេស អាស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ភីអិលស៊ី
- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញាជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអតិបរមា ដែលបានចូលរួមក្នុងពិធីសម្ពោធបើកឱ្យដំណើរការជាផ្លូវការ ធនាគារឯកទេស អាស៊ាប៉ាស៊ីហ្វិក ឌីវេឡុបមេន ភីអិលស៊ី ដែលបានបើកសម្ពោធជាផ្លូវការនាពេលនេះ ។ តាងនាមឱ្យធនាគារជាតិនៃកម្ពុជា ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅនិងអបអរសាទរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ភាគទុនិក និងគណៈគ្រប់គ្រងធនាគារឯកទេសអាស៊ាប៉ាស៊ីហ្វិក ឌីវេឡុបមេន ភីអិលស៊ី ក្នុងការបើកធ្វើប្រតិបត្តិការអាជីវកម្មជាផ្លូវការរបស់ខ្លួននាពេលនេះ ។ ការបើកសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការធនាគារឯកទេសអាស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ភីអិលស៊ីនាពេលនេះស្របពេលដែលប្រទេសកម្ពុជាបានធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងតំបន់អាស៊ាននិងបានឆ្លុះបញ្ចាំងពីកំណើនជំនឿទុកចិត្តពីមជ្ឈដ្ឋានមហាជនទាំងក្នុង និងក្រៅប្រទេសមកលើវិស័យធនាគារ ក៏ដូចជាមកលើការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា ។ ខ្ញុំសង្ឃឹមថា ធនាគារឯកទេសអាស៊ាប៉ាស៊ីហ្វិកឌីវេឡុបមេន ភីអិលស៊ីនឹងចូលរួមចំណែកផ្តល់ឥណទានដល់សហគ្រាសធុនតូច និងមធ្យម ដល់ប្រជាពលរដ្ឋតាមរាជធានី-ខេត្តដើម្បីទ្រទ្រង់សេដ្ឋកិច្ចព្រះរាជាណាចក្រកម្ពុជា ឱ្យបន្តកើនឡើងជាលំដាប់។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញាជាទីមេត្រី**

វិស័យធនាគារបាននិងកំពុងចូលរួមចំណែកយ៉ាងខ្លាំងក្លាក្នុងការជំរុញបរិយាប័ន្នហិរញ្ញវត្ថុដើម្បីបង្កើនប្រសិទ្ធភាពអាជីវកម្ម បង្កើតឱកាសការងារដល់ប្រជាពលរដ្ឋនៅតាមជនបទ កាត់បន្ថយគម្លាតចំណូល និងភាពក្រីក្រ ដែលមានសារៈសំខាន់ក្នុងការគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងសមភាព។ ជាមួយគ្នានេះ វិស័យធនាគារក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ទាំងវិសាលភាព និងទំហំប្រតិបត្តិការ។ ជាក់ស្តែង គិតត្រឹមដើមឆ្នាំ២០១៦ ទ្រព្យសកម្មកើនឡើងប្រមាណ ២៥ប៊ីលានដុល្លារ

អាមេរិក ក្នុងនោះឥណទានមានចំនួនប្រមាណ ១៥,៦ប៊ីលានដុល្លារអាមេរិក និងអ្នកខ្ចីប្រាក់ប្រមាណ ២,៦លាននាក់។ ចំណែកឯប្រាក់បញ្ញើកើនឡើងដល់ប្រមាណ ១៣,៦ដុល្លារអាមេរិក និងអតិថិជនម្ចាស់ប្រាក់បញ្ញើមានចំនួនប្រមាណ ៨,២លាននាក់។ ទន្ទឹមនេះ របាយការណ៍ថ្មីៗនេះបានបង្ហាញថា ប្រជាជនកម្ពុជាដែលមានអាយុពេញវ័យប្រមាណ ៥១% បានទទួលសេវាហិរញ្ញវត្ថុផ្លូវការ ធៀបនឹង ៨,៧% កាលពី១០ឆ្នាំមុន។

ខ្ញុំមានជំនឿយ៉ាងមុតមាំថា ធនាគារឯកទេស អាស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ភីអិលស៊ីនឹងជាដៃគូអភិវឌ្ឍន៍ដ៏ល្អមួយជាមួយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈការជួយបង្កើតការងារ និងរួមចំណែកជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នឹងបន្តជាប្រតិបត្តិការល្អជាមួយធនាគារជាតិនៃកម្ពុជាក្នុងការអនុវត្តបទប្បញ្ញត្តិយ៉ាងខ្ជាប់ខ្ជួន និងជាអ្នកផ្តល់សេវាកម្មហិរញ្ញវត្ថុល្អជាមួយអតិថិជនទូទៅក្នុងការពង្រីកប្រតិបត្តិការរបស់ខ្លួនឱ្យមានប្រសិទ្ធភាពមួយកម្រិតថែមទៀត។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញាជាទីមេត្រី**

ជាថ្មីម្តងទៀត ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងស្វាគមន៍ចំពោះភាគទុនិក ថ្នាក់ដឹកនាំនិងបុគ្គលិករបស់ធនាគារឯកទេស អាស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ភីអិលស៊ី ហើយខ្ញុំសង្ឃឹមថា ធនាគារនឹងបន្តចូលរួមចំណែកក្នុងការពង្រឹងប្រតិបត្តិការឱ្យកាន់តែមានភាពរឹងមាំ ដើម្បីបំពេញសេចក្តីត្រូវការរបស់អតិថិជននៅពេលបច្ចុប្បន្ន ក៏ដូចជានៅពេលអនាគត។

ជាទីបញ្ចប់ ឆ្លៀតឱកាសដ៏ឱឡារិកនេះ ខ្ញុំសូមគោរពជូនពរ ឯកឧត្តម លោកជំទាវ អ្នក**ឧកញ៉ា** លោក លោកស្រី អ្នកនាងកញ្ញា ជាភ្ញៀវកិត្តិយសទាំងអស់ ជាពិសេស ភាគទុនិក ថ្នាក់ដឹកនាំ និងបុគ្គលិកទាំងអស់របស់ធនាគារឯកទេស អាស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ភីអិលស៊ី សូមជួបប្រទះតែពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

# សុន្ទរកថាគន្លឹះ
# ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
# ក្នុងពិធីបើកសិក្ខាសាលាស្តីពី "ផ្តើមនិយាយពីបំណុលវ័ណ្ឌកឥឡូវនេះ"
## សណ្ឋាគារភ្នំពេញ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦

សូមគោរព ៖

- លោកឧកញ៉ា ហ្វូត អៀងគុង ប្រធានសមាគមមីក្រូហិរញ្ញវត្ថុ
- លោក Philippne Steinmetz នាយកតំបន់ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) ប្រចាំប្រទេសកម្ពុជា និងប្រទេសឡាវ
- លោកស្រី Yong Saraz Zhou តំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ប្រចាំប្រទេសកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញានិងភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយដោយបានចូលរួមក្នុងសិក្ខាសាលា ក្រោមប្រធានបទស្តីពី "ផ្តើមនិយាយពីបំណុលវ័ណ្ឌកឥឡូវនេះ" ជាមួយឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវជាតិនិងអន្តរជាតិនាពេលនេះ។

តាងនាមធនាគារជាតិនៃកម្ពុជានិងខ្ញុំផ្ទាល់ ខ្ញុំសូមកោតសរសើរចំពោះគ្រប់ភាគី និងដៃគូអភិវឌ្ឍន៍ទាំងអស់ជាពិសេសចំពោះសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងសមាជិកទាំងអស់ ដែលតែងតែសហការនិងសាមគ្គីគ្នាយ៉ាងល្អក្នុងការរួមចំណែកសម្រេចបាននូវលទ្ធផលជាទីពេញចិត្ត ដែលនាំមកនូវការរីកចម្រើននៃវិស័យមីក្រូហិរញ្ញវត្ថុរបស់យើងជាបន្តបន្ទាប់ រហូតទទួលបានកិត្តិនាមល្បីល្បាញទាំងថ្នាក់ជាតិនិងអន្តរជាតិ។

ខ្ញុំក៏សូមឆ្លៀតឱកាសនេះជម្រាបជូនអង្គសិក្ខាសាលាទាំងមូលថា ធនាគារជាតិនៃកម្ពុជាទទួលបានជោគជ័យដ៏ធំធេងក្នុងការរៀបចំសន្និសីទជាតិស្តីពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាដែលប្រព្រឹត្តទៅកាលពីថ្ងៃទី១៤-១៥ ខែមីនា ឆ្នាំ២០១៦។ កម្មវិធីបើកនៃសន្និសីទនេះ បានប្រព្រឹត្តទៅប្រកបដោយកិត្តិយសក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចតេជោនាយករដ្ឋមន្ត្រី ។ សន្និសីទនេះបានទទួលការចូលរួមពីសមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន និងជាពិសេស ការចូលរួមរបស់អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ដែលរួមមាន អភិបាលរាជធានី-ខេត្ត ស្នងការរាជធានី-ខេត្ត អភិបាលខណ្ឌ-ស្រុក និងអធិការខណ្ឌ-ស្រុក សរុបមានចំនួនប្រមាណ ៩០០ នាក់។

អង្គសន្និសីទនេះ មានគោលបំណង ៖ ទី១ ផ្សព្វផ្សាយអំពីសារៈសំខាន់ អត្ថប្រយោជន៍ និងតួនាទី

របស់វិស័យមីក្រូហិរញ្ញវត្ថុ ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ទី២ រាយការណ៍ពីសមិទ្ធផលសម្រេចបានក្នុងរយៈពេល ១០ ឆ្នាំ បន្ទាប់ពីសម្ដេចតេជោនាយករដ្ឋមន្ត្រី បានប្រកាសយកឆ្នាំ២០០៦ ជាឆ្នាំមីក្រូហិរញ្ញវត្ថុកម្ពុជា ទី៣ ស្វែងយល់ពីបញ្ហាប្រឈម និងទី៤ កំណត់ទិសដៅសម្រាប់ការអភិវឌ្ឍនាពេលអនាគត។

ជារួមអង្គសន្និសីទទាំងមូលទទួលបានជោគជ័យ និងការកោតសរសើរពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ និងគាំទ្រអនុសាសន៍ទាំង ៥ចំណុច របស់សម្ដេចតេជោនាយករដ្ឋមន្ត្រីដែលបានលើកឡើងក្នុងអង្គសន្និសីទ ហើយធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរបញ្ញត្តកម្មនិងត្រួតពិនិត្យលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ប្ដេជ្ញាចិត្តយ៉ាងមុតមាំ អនុវត្តតាមអនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាល និងទទួលយកនូវអនុសាសន៍ព្រមទាំងសំណូមពរផ្សេងៗដែលបានលើកឡើង ដើម្បីរៀបចំជាទិសដៅនិងផែនការសកម្មភាពបន្ថែមទៀត សម្រាប់បន្តគាំទ្រដល់ការរីកចម្រើននៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។

**ឯកឧត្ដម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញាជាទីមេត្រី**

យើងទាំងអស់គ្នាទទួលស្គាល់អំពីតួនាទីសំខាន់របស់មីក្រូហិរញ្ញវត្ថុ ក្នុងការរួមចំណែកអនុវត្តគោលនយោបាយចតុកោណរបស់រាជរដ្ឋាភិបាល ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ជាពិសេសតាមរយៈការផ្ដល់ហិរញ្ញប្បទានជនបទ និងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ។ ជាក់ស្ដែង ក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានពង្រីកតំបន់ប្រតិបត្តិការរបស់ខ្លួនចូលជ្រៅដល់តំបន់ជនបទ ដែលផ្ដល់ឱកាសដល់ប្រជាពលរដ្ឋក្រីក្រអាចប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ និងប្រកបដោយកិច្ចការពារត្រឹមត្រូវ ។ ទន្ទឹមនេះ អត្រាកំណើនឥណទានមធ្យមប្រចាំឆ្នាំរបស់វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាបានកើនឡើងជាលំដាប់ពីចំនួន ៣៨% ក្នុងឆ្នាំ២០១២ ដល់ ៥០% ក្នុងឆ្នាំ២០១៤ និងកម្រិតប្រហាក់ប្រហែលគ្នាក្នុងឆ្នាំ២០១៥ ។ ដូច្នេះហើយ យើងមានមោទនភាពចំពោះសមិទ្ធផលដែលសម្រេចបានកន្លងមកនេះ ប៉ុន្តែទន្ទឹមនេះក៏ត្រូវយកចិត្តទុកដាក់ចំពោះភាពរឹងមាំនៃវិស័យនេះ ដើម្បីឱ្យមាននិរន្តរភាព។

ទោះយ៉ាងណា បទពិសោធន៍កន្លងមករបស់ប្រទេសមួយចំនួនបង្ហាញថា ការរីកចម្រើនលឿនពេកនៃវិស័យហិរញ្ញវត្ថុក៏អាចនាំមកនូវវិបត្តិផងដែរដោយសារ ៖ ទី១).ការប្រកួតប្រជែងខ្លាំងក្នុងស្ថានភាពទីផ្សារមួយកាន់តែចង្អៀតអាចជំរុញឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទទួលយកហានិភ័យខ្ពស់លើសលប់ដើម្បីទាក់ទាញអតិថិជន និងការដាក់ឱ្យប្រើប្រាស់ផលិតផលថ្មីៗដោយរិះរកវិធីសាស្ត្រនានាដើម្បីលក់ផលិតផលឥណទាន ឬវិធីសាស្ត្រនានាដែលផ្ដល់ភាពកាន់តែងាយស្រួលដល់អតិថិជនក្នុងការទទួលបានប្រាក់កម្ចីកាន់តែរហ័ស ទី២).ការប្រកួតប្រជែងទីផ្សារបានផ្ដល់ជម្រើសនិងឱកាសច្រើនដល់អតិថិជនខ្ចីប្រាក់បានច្រើនពីប្រភពច្រើនផ្សេងៗគ្នា ដែលអាចបណ្ដាលឱ្យមានបំណុលច្រើនហួសហេតុលើសពីតម្រូវការ ឬរងនូវបន្ទុកបំណុលធ្ងន់ធ្ងរនិងពុំមានលទ្ធភាពសងបំណុលត្រលប់វិញជាដើម និងទី៣).គ្រឹះស្ថានទាំងនោះ អាចនឹងជួបនូវកង្វះខាតប្រព័ន្ធគ្រប់គ្រងដែលបណ្ដាលមកពីការអនុវត្តមិនបានត្រឹមត្រូវនិងសមស្របនូវនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុងនិងមុខងារប្រតិបត្តិតាម ។ ដូចគ្នាដែរកត្តាបច្ចេកវិទ្យាព័ត៌មានុសាស្ត្រ ក៏នៅតែជាបញ្ហាចម្បងដែលត្រូវគិតគូរផងដែរ។

លើសពីនេះ កំណើននេះមិនត្រឹមតែប៉ះពាល់ដល់ស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនិងស្ថានភាពរស់នៅរបស់អតិថិជនប៉ុណ្ណោះទេ ក៏អាចប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុកំណើនសេដ្ឋកិច្ចនិងសណ្ដាប់ធ្នាប់សង្គមទាំងមូលផងដែរ។

ដូច្នេះហើយ ប្រធានបទនៃសិក្ខាសាលារបស់យើងថ្ងៃនេះផ្តល់ឱកាសពិភាក្សាបន្ថែមទៀតពាក់ព័ន្ធនឹងការកំណត់គោលនយោបាយ និងបទប្បញ្ញត្តិ ក៏ដូចជាការបន្តពង្រឹងសមត្ថភាពរបស់មន្ត្រីត្រួតពិនិត្យសំដៅពង្រឹងនិរន្តរភាពវិស័យហិរញ្ញវត្ថុនិងជំនឿទុកចិត្តរបស់សាធារណជន។ ទន្ទឹមនេះកិច្ចសហការរួមរវាងគ្រប់ភាគីពាក់ព័ន្ធនៅតែជាកត្តាចម្បងនៃជ័យជម្នះ។

**ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញាជាទីមេត្រី**

ទស្សនវិស័យ និងយុទ្ធសាស្ត្ររយៈពេលវែង ដែលមានចែងក្នុងចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុកម្ពុជាឆ្នាំ២០០១-២០១០ ឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ និងឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ ត្រូវបានដាក់ចេញឱ្យអនុវត្តហើយជារួមរាជរដ្ឋាភិបាលកម្ពុជាសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ។ ដើម្បីឆ្លើយតបនឹងការវិវត្តនៃស្ថានភាពបច្ចុប្បន្ននិងតម្រូវការជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចធ្វើបច្ចុប្បន្នកម្មឯកសារយុទ្ធសាស្ត្រខាងលើឱ្យទៅជា "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥" ។ ឯកសារយុទ្ធសាស្ត្រថ្មីនេះ មានគោលដៅអភិវឌ្ឍវិស័យហិរញ្ញវត្ថុរឹងមាំមួយដែលអាចគាំទ្រកំណើនសេដ្ឋកិច្ច និងជំរុញលទ្ធភាពរបស់ប្រជាជនក្រីក្រក្នុងការទទួលបានសេវាហិរញ្ញវត្ថុកាន់តែទូលំទូលាយ សំដៅរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។ ចំពោះចក្ខុវិស័យសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុគឺសំដៅជំរុញបរិយាប័ន្នហិរញ្ញវត្ថុ ដែលមានន័យថាជួយឱ្យប្រជាពលរដ្ឋក្រីក្រអាចទទួលបានសេវាហិរញ្ញវត្ថុក្នុងតម្លៃសមស្របដើម្បីបង្កើនចំណូល និងកាត់បន្ថយភាពក្រីក្រ។

ដើម្បីចូលរួមអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ខាងលើនិងក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យនិងបញ្ញត្តកម្មធនាគារជាតិនៃកម្ពុជានឹង៖

(១) បន្តពង្រឹងសមត្ថភាពត្រួតពិនិត្យឱ្យស្របតាមការរីកចម្រើននៃសកម្មភាពទាំងទំហំប្រតិបត្តិការនិងវិសាលភាពរបស់វិស័យមីក្រូហិរញ្ញវត្ថុ។

(២) លើកកម្ពស់ការប្រតិបត្តិតាមគោលការណ៍ស្នូលសម្រាប់ការត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាព សម្រាប់សកម្មភាពមីក្រូហិរញ្ញវត្ថុរបស់គណៈកម្មាធិការទីក្រុងបាសែល។ ធនាគារជាតិនៃកម្ពុជា ក៏នឹងពិនិត្យឡើងវិញនូវបទប្បញ្ញត្តិបច្ចុប្បន្នសម្រាប់ការពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផងដែរ។

(៣) ពិនិត្យឡើងវិញនូវគោលការណ៍នៃកិច្ចការពារអតិថិជន ដែលមាននៅក្នុងបទប្បញ្ញត្តិបច្ចុប្បន្នដើម្បីបំពេញបានតាមតម្រូវការនៃការពង្រីកគោលការណ៍កិច្ចការពារអតិថិជន។

(៤)បន្តរៀបចំកម្មវិធីអប់រំដល់ប្រជាពលរដ្ឋឱ្យកាន់តែទូលំទូលាយនិងចំគោលដៅ ហើយការយល់ដឹងរបស់សាធារណជនអំពីប្រតិបត្តិការមីក្រូហិរញ្ញវត្ថុនិងហានិភ័យចម្បងៗក៏នឹងត្រូវបានពង្រឹងផងដែរ និង

(៥)បន្តលើកទឹកចិត្តដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជាផ្តល់នូវកម្មវិធី ឬវគ្គបណ្តុះបណ្តាលផ្សេងៗដល់អតិថិជននិងប្រជាជនទូទៅ។

ទន្ទឹមនេះ ខ្ញុំសូមលើកទឹកចិត្តដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា៖ ១).បន្តអនុវត្តតាមគោលការណ៍កិច្ចការពារអតិថិជនរបស់ SMART Campaign ២). ពង្រឹងនូវគោលនយោបាយនិងនីតិវិធីនៃការផ្តល់និងការតាមដានឥណទាន ៣). ធ្វើពិពិធកម្មផលិតផលនិងសេវាកម្មដែលអាចបំពេញនូវតម្រូវការរបស់អតិថិជន ជាពិសេសអតិថិជននៅតំបន់ជនបទ។

**ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញាជាទីមេត្រី**

ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យនៅតែបន្តកិច្ចខិតខំប្រឹងប្រែង និងអនុវត្តយន្តការនានាគ្រប់ជ្រុងជ្រោយក្នុងគោលបំណងបង្កើតនូវក្របខណ្ឌបទប្បញ្ញត្តិសមស្រប ក្នុងការធានាឱ្យវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា មានភាពរឹងមាំនិងប្រកបដោយសុខភាពល្អ ។ ទន្ទឹមនេះធនាគារជាតិនៃកម្ពុជា ក៏នៅតែផ្តល់អាទិភាពចម្បងដល់ការបន្តការអនុវត្តគោលនយោបាយលើកកម្ពស់កិច្ចការពារអតិថិជន និងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុផងដែរ។

ជាថ្មីម្តងទៀត ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការសម្រេចបាននូវសមិទ្ធផលដ៏ជោគជ័យនៃវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាយើង ដែលបានបញ្ជាក់ឱ្យឃើញពីកិច្ចសហប្រតិបត្តិការល្អរវាងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ភាគីពាក់ព័ន្ធទាំងអស់និងធនាគារជាតិនៃកម្ពុជា ។ ខ្ញុំក៏សូមប្រសិទ្ធពរជ័យជូន ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់សូមមានសុខភាពល្អ កម្លាំងមាំមួន និងមានជ័យជម្នះគ្រប់ភារកិច្ចរៀងៗខ្លួន។

ខ្ញុំសូមប្រកាសបើកសិក្ខាសាលាស្តីពី"ផ្តើមនិយាយពីបំណុលវណ្ឌកឥឡូវនេះ"ចាប់ពីពេលនេះតទៅ។

**សូមអរគុណ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៦ របស់ធនាគារជាតិនៃកម្ពុជា
**នៅសាខាធនាគារជាតិនៃកម្ពុជា ខេត្តកំពង់ចាម ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៦**

**សូមគោរព :**

- **គណៈអធិបតី!**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអនេកប្បការ ដែលបានចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងាររបស់ធនាគារជាតិនៃកម្ពុជាប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៦ នៅសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ចាម ។ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ដែលមានវត្តមាននៅក្នុងសន្និបាតនាពេលនេះ ។ សន្និបាតរបស់យើងត្រូវបានធ្វើឡើងក្នុងគោលបំណងអបអរសាទរ និងផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយអំពីលទ្ធផលដែលធនាគារជាតិនៃកម្ពុជាទទួលបានកន្លងមក និងទិសដៅការងារ ដើម្បីឈានទៅសម្រេចឱ្យបានជោគជ័យថ្មីៗបន្ថែមទៀត ។ លើសពីនេះ ការជ្រើសរើសយកខេត្តកំពង់ចាមជាទីតាំងប្រារព្ធកម្មវិធី ក៏មានគោលបំណងផ្តល់ឱកាសជូនឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់បានស្វែងយល់ពីការអភិវឌ្ឍរីកចម្រើនជាក់ស្តែងរបស់ខេត្តនេះ ដែលមានសកម្មភាពសេដ្ឋកិច្ចរស់រវើក ហើយក៏ជាទីតាំងនៃទឹកដីប្រវត្តិសាស្ត្រមួយដ៏សំខាន់របស់កម្ពុជាយើងផងដែរ ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរយ៉ាងខ្លាំងចំពោះមន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់ ដែលបានខិតខំប្រឹងប្រែងបំពេញមុខងារភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងសម្រេចបានសមិទ្ធផលជូនធនាគារជាតិនៃកម្ពុជានាពេលកន្លងមក ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

នៅឆមាសទី១ ឆ្នាំ២០១៦នេះ កំណើនសេដ្ឋកិច្ចពិភពលោកបានបន្តងើបឡើងក្នុងល្បឿនយឺត ។ នៅប្រទេសអភិវឌ្ឍន៍ សកម្មភាពសេដ្ឋកិច្ចតំបន់អឺរ៉ូនិងជប៉ុនមានសន្ទុះកំណើនខ្សោយ ប៉ុន្តែខ្ពស់ជាងការរំពឹងទុក ខណៈដែលកំណើនសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកបានថយល្បឿនបន្តិច ។ នៅប្រទេសកំពុងងើបឡើង និងប្រទេសកំពុងអភិវឌ្ឍន៍ កំណើនមានភាពមិនស្មើសាច់ ដោយនៅតំបន់មួយចំនួនទទួលបានកំណើនអវិជ្ជមាន ដូចជា ប្រេស៊ីលនិងរុស្ស៊ី និងមួយចំនួនទៀតមានកំណើនខ្ពស់ ជាពិសេស នៅតំបន់អាស៊ី ។ គួរកត់សម្គាល់ថា ប្រទេសកំពុងងើបឡើង និងប្រទេសកំពុងអភិវឌ្ឍន៍ក្នុងតំបន់អាស៊ីនៅតែបន្តរួមចំណែកជាចម្បងក្នុងកំណើនសេដ្ឋកិច្ចពិភពលោកដោយមានទំហំ ផ.ស.ស ស្មើនឹងប្រមាណ ១/៣ នៃ ផ.ស.ស ពិភពលោក។ នៅក្នុងតំបន់នេះ សេដ្ឋកិច្ចចិនបានបន្តបន្ថយល្បឿនកំណើនសន្សឹមៗ ចំណែកឯ សេដ្ឋកិច្ចតំបន់អាស៊ានបន្តរក្សាកំណើនខ្ពស់ ជាពិសេស នៅក្នុងប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម (CLMV) ខណៈដែលសេដ្ឋកិច្ចថៃបន្តមានកំណើនយឺតនៅឡើយ ហើយប្រ៊ុយណេមានកំណើនអវិជ្ជមាន ដោយសារការធ្លាក់ចុះនៃថ្លៃប្រេង ។

ចំពោះទស្សនវិស័យខាងមុខ សេដ្ឋកិច្ចពិភពលោកអាចនឹងប្រឈមភាពមិនច្បាស់លាស់ខ្ពស់ជាងមុន ក្រោយពីការសម្រេចចិត្តចាកចេញរបស់ប្រទេសអង់គ្លេសពីសហភាពអឺរ៉ុប (Brexit) កាលពីខែមិថុនា ឆ្នាំ២០១៦ កន្លងទៅ ។ ការចាកចេញនេះត្រូវបានប៉ាន់ស្មានថា អាចនឹងមានឥទ្ធិពលនាំឱ្យស្ថានភាពទីផ្សារហិរញ្ញវត្ថុអន្តរជាតិកាន់តែមានភាពរឹតត្បិត និងអាចមានផលប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចអង់គ្លេសនិងសហភាពអឺរ៉ុប ដែលទាំងនេះអាចបង្កជាហានិភ័យថ្មីមួយទៀតបន្ថែមលើហានិភ័យដែលមានស្រាប់ ចំពោះសេដ្ឋកិច្ចពិភពលោក ដូចជា ៖ ភាពតានតឹងភូមិសាស្ត្រនយោបាយ វិបត្តិជនភៀសខ្លួន ការបន្តថយចុះល្បឿនកំណើនសេដ្ឋកិច្ចចិន និងការបន្តស្ថិតក្នុងកម្រិតទាបនៃថ្លៃទំនិញពាណិជ្ជកម្ម ។

ក្នុងបរិការណ៍នេះ បណ្តាប្រទេសអភិវឌ្ឍន៍និងប្រទេសកំពុងងើបឡើងរំពឹងថា នឹងបន្តអនុវត្តគោលនយោបាយសេដ្ឋកិច្ចចម្បងៗមួយចំនួន សម្រាប់ជំរុញកំណើនសេដ្ឋកិច្ចរួមមាន ៖ ការអនុវត្តគោលនយោបាយរូបិយវត្ថុរិត្បារកម្ម ដែលផ្សារភ្ជាប់ទៅនឹងការរក្សាស្ថិរភាពហិរញ្ញវត្ថុ ការធ្វើកំណែទម្រង់រចនាសម្ព័ន្ធដែលកំពុងមានភាពយឺតនៅឡើយ និងការបង្កើនសមាហរណកម្មនៅក្នុងតំបន់និងពិភពលោក សំដៅពង្រឹងភាពធន់នៃមូលដ្ឋានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ចំពោះតំបន់អាស៊ី គោលនយោបាយជាអាទិភាពគឺការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងការកែទម្រង់រចនាសម្ព័ន្ធ ដែលមានគោលដៅគាំទ្រកំណើន កាត់បន្ថយហានិភ័យខាងក្រៅនិងពង្រឹងការគ្រប់គ្រងភាពងាយរងគ្រោះនៃសេដ្ឋកិច្ចទល់នឹងហានិភ័យនានា ។

ដោយឡែកនៅកម្ពុជាក្នុងឆមាសទី១នេះ សកម្មភាពសេដ្ឋកិច្ចមានជីវភាពល្អប្រសើរក្នុងស្ថានភាពដែលស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចត្រូវបានបន្តរក្សាយ៉ាងរឹងមាំជាប្រក្រតី ។ លទ្ធផលនេះ ទទួលបានដោយសារកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការធ្វើកំណែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ការធ្វើពិពិធកម្មលើមូលដ្ឋានសេដ្ឋកិច្ច និងការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចសមស្រប ដើម្បីធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគជំរុញពាណិជ្ជកម្ម និងអភិវឌ្ឍវិស័យចម្បងៗតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ច្បាស់លាស់ ។ តាមរយៈការបោះជំហានប្រកបដោយភាពរឹងមាំនេះ ធនាគារពិភពលោកបានទទួលស្គាល់និងប្រកាសជាផ្លូវការកាលពីពេលថ្មីៗនេះ ពីចំណាត់ថ្នាក់ថ្មីរបស់កម្ពុជា ជាប្រទេសមានចំណូលមធ្យមកម្រិតទាប ដោយយោងតាមកំណើនកម្រិតចំណូលរបស់ប្រជាជនកម្ពុជា ។ ចំណាត់ថ្នាក់ថ្មីនេះ បានឆ្លុះបញ្ចាំងពីការអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល ក្រោមការធានាបាននូវសន្តិភាព សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ហើយបានលើកកិត្យានុភាពកម្ពុជានៅលើឆាកអន្តរជាតិមួយកម្រិតថែមទៀត ។

ក្នុងនាមជាអាជ្ញាធររូបិយវត្ថុនិងអាជ្ញាធរត្រួតពិនិត្យប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជាបានរួមចំណែកគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងអភិវឌ្ឍវិស័យធនាគារប្រកបដោយបរិយាប័ន្ន និងសមាហរណកម្មស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ឆ្នាំ២០១៣-២០១៨ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព និងយុទ្ធ-សាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០ ។

ចំពោះការរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានបន្តអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពទន់ភ្លន់និងប្រុងប្រយ័ត្ន ដោយរក្សាបាននូវស្ថិរភាពថ្លៃនិងតម្លៃប្រាក់រៀលយ៉ាងល្អប្រសើរ ។ ជាក់ស្តែង អត្រាអតិផរណាមានកម្រិតជាមធ្យម ២,៨% នៅឆមាសទី១ នេះ ហើយអត្រាប្តូរប្រាក់មានស្ថិរភាពក្នុងរង្វង់ ៤.០៤៤រៀល ក្នុងមួយដុល្លារអាមេរិក ។ ទន្ទឹមនេះ ទុនបម្រុងអន្តរជាតិបានកើនដល់ ៥,៥ ប៊ីលានដុល្លារអាមេរិក ដែលអាចធានាការទូទាត់ទំនិញ និងសេវាបានប្រមាណ៥ខែ ខ្ពស់ជាងកម្រិតអប្បបរមាដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន (៣ខែ) ។ ទោះជាយ៉ាងណា កម្រិតខ្ពស់នៃដុល្លារូបនីយកម្មនៅតែបន្តដាក់កំហិតលើប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុ ។ ឆ្លើយតបនឹងបញ្ហានេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុង i/- អភិវឌ្ឍទីផ្សារអន្តរធនាគារនិងរូបិយវត្ថុ តាមរយៈការជំរុញតម្រូវការលើមូលបត្រអាចជួញដូរបាន (NCD) ដើម្បីពង្រឹងការគ្រប់គ្រងសន្ទនីយភាពនៅក្នុងប្រព័ន្ធធនាគារ និងបង្កើតឧបករណ៍គោលនយោបាយរូបិយវត្ថុផ្អែកលើយន្តការទីផ្សារ ii/-អភិវឌ្ឍទីផ្សារប្តូរប្រាក់ ដើម្បីឆ្លើយតបនឹងតម្រូវការប្រាក់រៀល ក៏ដូចជាស្រូបយករូបិយប័ណ្ណចូលមកក្នុង ប្រព័ន្ធធនាគារ

និង iii/- លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ផ្អែកលើយន្តការទីផ្សារនិងគោលការណ៍ស្ម័គ្រចិត្ត ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពនៃគោលនយោបាយរូបិយវត្ថុ ។ ថ្មីៗនេះ ប្រព័ន្ធទូទាត់រាយអេឡិចត្រូនិកត្រូវបានដាក់ឱ្យដំណើរការ ដើម្បីសម្រួលដល់ការទូទាត់ជាប្រាក់រៀលស្របពេលដែលប្រជាជនកម្ពុជា កំពុងតែគាំទ្រយ៉ាងស្រួចស្រាល់លើការប្រើប្រាស់ប្រាក់រៀលក្នុងប្រតិបត្តិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយការយល់ដឹងរបស់សាធារណជនមកលើអត្ថប្រយោជន៍និងតួនាទីប្រាក់រៀលនៅក្នុងសេដ្ឋកិច្ចនិងសង្គម ក៏ត្រូវបានពង្រឹងជាលំដាប់ផងដែរ ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំក៏សូមកោតសរសើរចំពោះគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុន និងសហគ្រាសមួយចំនួន ដែលបាននិងកំពុងបង្កើនការប្រើប្រាស់ប្រាក់រៀលជាលំដាប់ក្នុងប្រតិបត្តិការរបស់ខ្លួន ដូចជាការផ្តល់សេវាហិរញ្ញវត្ថុ ការទូទាត់ បិទថ្លៃទំនិញ និងបើកប្រាក់ខែជាប្រាក់រៀលជូនបុគ្គលិក ជាដើម ។

គួរកត់សម្គាល់ថា យោងតាមការវាយតម្លៃរបស់មូលនិធិរូបិយវត្ថុអន្តរជាតិបង្ហាញថា ការរីកចម្រើននៃប្រព័ន្ធធនាគារកម្ពុជាបានរួមចំណែកយ៉ាងសំខាន់ ក្នុងការគាំទ្រការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចនិងជំរុញកំណើន ។ នៅឆមាសទី១នេះ ទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារបានកើនឡើងប្រមាណ ២,២ ប៊ីលានដុល្លារអាមេរិក ដែលបានធ្វើឱ្យទ្រព្យសកម្មសរុបកើនឡើងដល់ប្រមាណ ២៦ ប៊ីលានដុល្លារអាមេរិកស្មើនឹង ១៣១% នៃផ.ស.ស ។ ទន្ទឹមនេះ ប្រាក់បញ្ញើសរុបបានកើនដល់ ៦៧% នៃផ.ស.ស ហើយឥណទានសរុបបានកើនឡើងដល់ ៨០% នៃផ.ស.ស ដែលត្រូវបានបែងចែកប្រកបដោយប្រសិទ្ធភាពទៅវិស័យសេដ្ឋកិច្ចចម្បងៗ ។ ទោះជាយ៉ាងណា ក្នុងបរិការណ៍ដែលស្ថានភាពទីផ្សារហិរញ្ញវត្ថុអន្តរជាតិកំពុងតែប្រឈមនឹងភាពមិនច្បាស់លាស់ ហើយប្រព័ន្ធធនាគារកម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័ស ធនាគារជាតិនៃកម្ពុជាបានតាមដានយ៉ាងយកចិត្តទុកដាក់លើការវិវត្តនានា និងបានដាក់ចេញនូវវិធានការមីក្រូនិងម៉ាក្រូប្រុងប្រយ័ត្ន ដែលមានលក្ខណៈបុរេសកម្មជាបន្តបន្ទាប់ ដើម្បីគ្រប់គ្រងហានិភ័យជាប្រព័ន្ធដែលអាចកើតឡើងជាយថាហេតុ ផ្អែកលើយន្តការទីផ្សារ និងមានលក្ខណៈទន់ភ្លន់សំដៅរក្សាស្ថិរភាពហិរញ្ញវត្ថុឱ្យបានរឹងមាំ ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានពង្រឹងកិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ក្នុងការតាមដាននិងវាយតម្លៃស្ថិរភាពហិរញ្ញវត្ថុនៅកម្ពុជាឱ្យកាន់តែគ្រប់ជ្រុងជ្រោយ ។

យ៉ាងណាមិញ ធនាគារជាតិនៃកម្ពុជាបានធ្វើការវិភាគយ៉ាងស៊ីជម្រៅលើកំណើនឥណទានទាំងទៅលើប្រភពកំណើន ការបែងចែកតាមវិស័យនានា (ទៅកាន់វិស័យផលិតកម្មនិងមិនមែនផលិតកម្ម) និងគុណភាពសំពៀតឥណទាន ព្រមទាំងបានវាយតម្លៃគ្រប់ជ្រុងជ្រោយលើស្ថានភាពហានិភ័យឥណទាន តាមរយៈសូចនាករប្រុងប្រយ័ត្ននានា។ លទ្ធផលនៃការវិភាគបានបង្ហាញថា

ប្រភពមូលនិធិសម្រាប់ផ្តល់ឥណទាននៅកម្ពុជា ភាគច្រើនមានរយៈពេលវែងនិងស្ថិរភាព ហើយការបែងចែកឥណទានមិនមានការប្រមូលផ្តុំហួសហេតុទៅលើវិស័យណាមួយទេ ក្នុងពេលដែលសំពៀតឥណទានមានគុណភាពល្អបង្គួរ ដែលឆ្លុះបញ្ចាំងដោយកម្រិតទាបនៃអនុបាតឥណទានមិនដំណើរការ ។ ម៉្យាងទៀត ធនាគារជាតិនៃកម្ពុជាក៏បានវិភាគលើហានិភ័យឥណទានចំពោះវិស័យសំណង់និងអចលនទ្រព្យយ៉ាងយកចិត្តទុកដាក់ ដើម្បីពិនិត្យមើលទៅលើភាពប្រទាក់ក្រឡានៃវិស័យនេះ ជាមួយនឹងវិស័យធនាគារនិងហិរញ្ញវត្ថុ ។ ឆ្លើយតបនឹងការវិវត្តនៃស្ថានភាពទាំងនេះ និងដើម្បីបង្ការហានិភ័យ ដែលអាចកើតឡើងជាយថាហេតុ ធនាគារជាតិនៃកម្ពុជាបានពង្រឹងនូវការត្រួតពិនិត្យទាំងលើឯកសារ និងដល់ទីកន្លែងលើកំណើនឥណទាន និងសុខភាពប្រព័ន្ធធនាគារទាំងកម្រិតមីក្រូនិងម៉ាក្រូ និងដាក់ចេញនូវវិធានការចម្បងៗ ដូចជា អនុបាតក្របខ័ណ្ឌសន្ទនីយភាព ការដំឡើងដើមទុនចុះបញ្ជី និងវិធានការមីក្រូនិងម៉ាក្រូដទៃទៀត សំដៅពង្រឹងការគ្រប់គ្រងហានិភ័យ និងស្ថិរភាពប្រព័ន្ធធនាគារទាំងមូល ។

ក្នុងការរួមចំណែក អនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាបានបន្តលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ដើម្បីពង្រីកការផ្តល់សេវាហិរញ្ញវត្ថុឱ្យកាន់តែទូលំទូលាយក្នុងតម្លៃសមរម្យដល់ប្រជាជនក្រីក្រ ជាពិសេស តាមរយៈការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ ។ នៅខែមីនាឆ្នាំ២០១៦នេះ ធនាគារជាតិនៃកម្ពុជាបានរៀបចំសន្និសីទជាតិស្តីពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីអបអរសាទរការរីកចម្រើនវិស័យមីក្រូហិរញ្ញវត្ថុក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ ក៏ដូចជាដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា និងតួនាទីដ៏សំខាន់របស់វិស័យនេះ ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។ គួរបញ្ជាក់ថា បរិយាប័ន្នហិរញ្ញវត្ថុមិនត្រឹមតែបានផ្តល់លទ្ធភាពដល់ប្រជាជនក្រីក្រឱ្យទទួលបានសេវាហិរញ្ញវត្ថុក្នុងតម្លៃសមរម្យប៉ុណ្ណោះទេ តែថែមទាំងបានពង្រីកការផ្តល់សេវាឥណទានដល់សហគ្រាសធុនតូចនិងមធ្យម ដែលបានរួមចំណែកគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ២០១៥-២០២៥ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៤-២០១៨ របស់រាជរដ្ឋាភិបាលទៀតផង ។ ដើម្បីបន្តលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព ធនាគារជាតិនៃកម្ពុជាបាននិងកំពុង i/- ពង្រឹងក្របខណ្ឌត្រួតពិនិត្យនិងបទប្បញ្ញត្តិក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ii/-ជំរុញឱ្យអង្គការក្រៅរដ្ឋាភិបាលដែលធ្វើប្រតិបត្តិការផ្តល់ឥណទាននិងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុមកចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជា iii/-រៀបចំក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងកិច្ចការពារអតិថិជន ដើម្បីការពារអត្ថប្រយោជន៍របស់អ្នកប្រើប្រាស់សេវា

ហិរញ្ញវត្ថុ iv/-បង្កើនចំណេះដឹងហិរញ្ញវត្ថុដល់សាធារណជនដែលគ្រោងនឹងបញ្ចូលទៅក្នុងកម្មវិធីសិក្សាទូទៅនៃប្រព័ន្ធអប់រំ និង v/-រៀបចំយុទ្ធសាស្ត្រជាតិស្តីពីបរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា។ ថ្មីៗនេះ មូលនិធិអភិវឌ្ឍន៍មូលធនអង្គការសហប្រជាជាតិ (UNCDF) បានធ្វើការអង្កេតលើការប្រើប្រាស់សេវាហិរញ្ញវត្ថុនៅកម្ពុជា ហើយលទ្ធផលបង្ហាញថាប្រជាជនពេញវ័យប្រមាណ ៧១% នៅកម្ពុជាកំពុងប្រើប្រាស់សេវាហិរញ្ញវត្ថុ ដែលក្នុងនោះ ៥៩% ប្រើប្រាស់សេវាផ្លូវការ ។ យោងតាម UNCDF អត្រានេះជាកម្រិតខ្ពស់មួយបើធៀបនឹងប្រទេសនៅក្នុងតំបន់ដែលមានស្ថានភាពប្រហាក់ប្រហែលនឹងកម្ពុជា ហើយ UNCDF បានអបអរសាទរចំពោះកម្ពុជា ដែលសម្រេចបានការពង្រីកការផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាជនពេញវ័យយ៉ាងឆាប់រហ័សនាពេលកន្លងមក ។

ស្របពេលដែលស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភពលោកកាន់តែមានភាពប្រទាក់ក្រឡា ហើយប្រព័ន្ធធនាគារកម្ពុជាកាន់តែមានសមាហរណកម្មខ្ពស់ ធនាគារជាតិនៃកម្ពុជាបានពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិទាំងក្នុងក្របខណ្ឌតំបន់ និងពិភពលោក ហើយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក៏បានពង្រឹងប្រសិទ្ធភាពនៃការទប់ស្កាត់សកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មក្នុងប្រព័ន្ធធនាគារផងដែរ ។ ទន្ទឹមនេះ ការគ្រប់គ្រងផ្ទៃក្នុងត្រូវបានពង្រឹង ហើយសមត្ថភាពធនធានមនុស្សលើផ្នែកឯកទេសកម្មចំណេះដឹងបច្ចេកទេសត្រូវបានអភិវឌ្ឍជាលំដាប់ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងាររបស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងពង្រឹងសមត្ថភាពរបស់មន្ត្រីយើងនាពេលកន្លងមក ដោយបច្ចុប្បន្នយើងមានមន្ត្រីដែលទទួលបានសញ្ញាបត្រជំនាញទទួលស្គាល់ជាអន្តរជាតិកាន់តែច្រើនឡើង ជាពិសេសពាក់ព័ន្ធនឹង i/- ជំនាញគណនេយ្យ សញ្ញាបត្រ CPA ii/- ជំនាញវិភាគហិរញ្ញវត្ថុ សញ្ញាបត្រ CFA និង iii/- ជំនាញត្រួតពិនិត្យធនាគារ សញ្ញាបត្រពី FSI Connect-BIS ជាដើម ។

ចំពោះទស្សនវិស័យលើស្ថានភាពសេដ្ឋកិច្ចកម្ពុជា កំណើនរំពឹងថានឹងសម្រេចបានក្នុងអត្រាប្រមាណ ៧,១% នៅឆ្នាំ២០១៦នេះ ជាមួយនឹងអត្រាទាបនៃអតិផរណាប្រមាណក្រោម ៣% និងស្ថិរភាពអត្រាប្តូរប្រាក់ក្នុងរង្វង់ ៤.០៥០ រៀលក្នុងមួយដុល្លារអាមេរិក។ ទន្ទឹមនេះ ប្រព័ន្ធធនាគារនឹងបន្តអភិវឌ្ឍយ៉ាងរឹងមាំ និងដើរតួនាទីកាន់តែសំខាន់ក្នុងការគាំទ្រ និងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ដើម្បីជ្រាបពីសមិទ្ធផលលម្អិតដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន និងទិសដៅការងារសំខាន់ៗ ខ្ញុំសូមអង្គសន្និបាតមេត្តាត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំយើង ដែលនឹងរាយការណ៍ជូនអង្គសន្និបាតនាពេលបន្តិចទៀតនេះ។ ខ្ញុំសង្ឃឹមថា ឯកឧត្តម លោកជំទាវ

លោក លោកស្រី នាងកញ្ញា នឹងបានយល់ច្បាស់លើខ្លឹមសារនៃអង្គសន្និបាតយើង ព្រមទាំងយកទៅផ្សព្វផ្សាយបន្តនិងអនុវត្តក្នុងការងារឱ្យបានជោគជ័យ មានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណជាតិយេ្យាភាព ចំពោះក្រុមប្រឹក្សាភិបាលនិងមន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់របស់ធនាគារជាតិនៃកម្ពុជា ដែលបានខិតខំប្រឹងប្រែងក្នុងការបំពេញមុខងារភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីសម្រេចបានសមិទ្ធផលដ៏ប្រសើរជាបន្តបន្ទាប់នារយៈពេលកន្លងមក ។ ខ្ញុំក៏សូមថ្លែងអំណរគុណជាអនេកចំពោះគ្រប់ក្រសួង ស្ថាប័ននានានៅក្នុងវិស័យសាធារណៈនិងឯកជន ព្រមទាំងដៃគូអភិវឌ្ឍន៍ទាំងអស់ដែលបានគាំទ្រ និងរួមចំណែកនៅក្នុងសមិទ្ធផលនេះ ។

ជាបរិយោសាន ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញា ឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបី ឃ្លៀងឃ្លាតឡើយ ។ ខ្ញុំសូមឱ្យអង្គសន្និបាតរបស់យើងប្រព្រឹត្តទៅប្រកបដោយជោគជ័យ និងផ្លែផ្កា ។

**ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ!**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៦ របស់ធនាគារជាតិនៃកម្ពុជា
### នៅសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ចាម ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៦

**សូមគោរព :**

- **គណៈអធិបតី!**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

នាពេលនេះ សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៦ របស់យើងបានឈានដល់ទីបញ្ចប់ហើយ ។ ជារួម ខ្ញុំសូមវាយតម្លៃខ្ពស់ថា សន្និបាតរបស់យើងបានប្រព្រឹត្តទៅប្រកបដោយជោគជ័យ ក្រោមបរិយាកាសសប្បាយរីករាយ និងស្និទ្ធស្នាលក្នុងស្មារតីសាមគ្គីភាពនិងភាតរភាពបំផុត ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះថ្នាក់ដឹកនាំរបស់យើងដែលបានធ្វើបទ-បង្ហាញនិងបទអន្តរាគមន៍អំពីលទ្ធផលចម្បងៗដែលសម្រេចបាន និងទិសដៅការងារសំខាន់ៗរបស់ធនាគារជាតិនៃកម្ពុជា និងចំពោះការចូលរួមយ៉ាងសកម្ម និងដោយយកចិត្តទុកដាក់ខ្ពស់របស់សមាជិក-សមាជិកានៃអង្គសន្និបាតទាំងមូល ។ ខ្ញុំសូមឯកភាពលើការបូកសរុបលទ្ធផល ទស្សនវិស័យនិងមតិដែលបានលើកឡើងរបស់ថ្នាក់ដឹកនាំយើងពិតជាមានសារៈសំខាន់ណាស់ក្នុងការសម្រេចឱ្យបានសមិទ្ធផលថ្មីៗ បន្ថែមទៀត ជូនធនាគារជាតិនៃកម្ពុជា ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ការបន្តងើបឡើងនៃសេដ្ឋកិច្ចពិភពលោក ជាពិសេសនៅក្នុងប្រទេសជាដៃគូពាណិជ្ជកម្ម និងវិនិយោគជាមួយកម្ពុជានឹងអាចផ្តល់ភាពអំណោយផលដល់កំណើននៃការនាំចេញ ការវិនិ-យោគផ្ទាល់បរទេសនិងវិស័យទេសចរណ៍នៅកម្ពុជា ។ កត្តាទាំងនេះ គួបផ្សំនឹងកំណើនតម្រូវការ

និងការវិនិយោគក្នុងស្រុក បានធ្វើឱ្យកំណើនសេដ្ឋកិច្ចរំពឹងថានឹងបន្តកើនឡើងក្នុងរង្វង់ ៧% ក្នុងរយៈកាលមធ្យម ជាមួយនឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរឹងមាំ ។

ទោះជាយ៉ាងណា សេដ្ឋកិច្ចកម្ពុជាក៏អាចទទួលរងឥទ្ធិពលនៃការប្រែប្រួលសេដ្ឋកិច្ចពិភពលោកផងដែរ ដោយសារកម្ពុជាមានកម្រិតបើកចំហខ្ពស់ និងពឹងផ្អែកលើវិស័យខាងក្រៅដើម្បីជំរុញកំណើន ទន្ទឹមនឹងកម្លាំងជំរុញនៃតម្រូវការក្នុងស្រុក ។ ក្នុងស្ថានភាពនេះ ភាពមិនច្បាស់លាស់នៃកំណើនសេដ្ឋកិច្ចពិភពលោក និងស្ថានភាពទីផ្សារហិរញ្ញវត្ថុអន្តរជាតិអាចធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាប្រឈមនឹងហានិភ័យចម្បងៗមួយចំនួន រួមមាន ៖

i/-ភាពរឹតត្បិតនៃស្ថានភាពទីផ្សារហិរញ្ញវត្ថុអន្តរជាតិនិងតំបន់ កំណើនយឺតនៃសេដ្ឋកិច្ចសហភាពអឺរ៉ុបនិងអង់គ្លេស ជាពិសេស ក្រោយពីការប្រកាសចាកចេញរបស់អង់គ្លេសពីសហភាពអឺរ៉ុប (Brexit)

ii/-ឥទ្ធិពលនៃការថមថយល្បឿនកំណើនសេដ្ឋកិច្ចចិន លើកំណើនសេដ្ឋកិច្ចកម្ពុជា ដោយសារកំណើនទំនាក់ទំនងផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ រវាងប្រទេសទាំងពីរ និង

iii/-ការកើនឡើងនៃការប្រកួតប្រជែងលើទីផ្សារនាំចេញ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (TPP) និងការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិក ។

ក្នុងបរិការណ៍នេះ ធនាគារជាតិនៃកម្ពុជានឹងបន្តពង្រឹងគោលនយោបាយនិងវិធានការដែលមានស្រាប់ និងដាក់ចេញនូវវិធានថ្មីនានា ដើម្បីបន្តរួមចំណែកពង្រឹងភាពធន់នៃមូលដ្ឋានម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍវិស័យធនាគារនិងស្ថិរភាពហិរញ្ញវត្ថុ សំដៅគាំទ្រការរីកចម្រើនសេដ្ឋកិច្ចប្រកបដោយចីរភាព បរិយាប័ន្ន និងសមធម៌ ស្របតាមគោលនយោបាយចតុកោណដំណាក់កាលទី៣ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ របស់រាជរដ្ឋាភិបាល ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ក្នុងស្មារតីនេះ ខ្ញុំសូមផ្តាំផ្ញើមតិមួយចំនួន ដើម្បីបន្តសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀត នៅឆមាសទី២ ឆ្នាំ២០១៦នេះ និងនៅក្នុងរយៈកាលមធ្យមខាងមុខ ដូចខាងក្រោម ៖

- បន្តអនុវត្តគោលនយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់ប្រកបដោយភាពទន់ភ្លន់ស្របតាមការរីកចម្រើនសេដ្ឋកិច្ច

- អភិវឌ្ឍទីផ្សារអន្តរធនាគារនិងរូបិយវត្ថុ និងទីផ្សារប្តូរប្រាក់ និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយ

- អភិវឌ្ឍឧបករណ៍គោលនយោបាយរូបិយវត្ថុថ្មីៗ ដែលរួមចំណែកបង្កើនប្រសិទ្ធភាពការអនុវត្តគោលនយោបាយរូបិយវត្ថុ

- អភិវឌ្ឍប្រព័ន្ធទូទាត់ឱ្យកាន់តែមានប្រសិទ្ធភាព សុវត្ថិភាព ឆាប់រហ័សនិង តម្លៃសមរម្យ

- បញ្ចប់ការចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជាចំពោះគ្រឹះស្ថាននិងអង្គការក្រៅរដ្ឋាភិបាល ដែលផ្តល់សេវាមីក្រូហិរញ្ញវត្ថុក្រៅប្រព័ន្ធឱ្យចប់សព្វគ្រប់មុនដំណាច់ឆ្នាំ២០១៦

- អនុវត្តតាមអនុសាសន៍ទាំង ៥ ចំណុចដែល **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានលើកឡើងក្នុងសន្និសីទជាតិ ស្តីពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦កន្លងមក ក្នុងគោលបំណងអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ ដើម្បីគាំទ្របរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជាសំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រនិងបង្កើនជីវភាពរស់នៅរបស់ប្រជាជន

- បន្តសហការជាមួយភាគីពាក់ព័ន្ធ ក្នុងការរៀបចំយុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុ ហើយបន្តពង្រឹងការអនុវត្តកិច្ចការពារអតិថិជន និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ

- បន្តផ្សព្វផ្សាយសេចក្តីថ្លែងការណ៍រួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងតួនាទីរបស់វិស័យមីក្រូហិរញ្ញវត្ថុ

- ពង្រឹងប្រសិទ្ធភាពទប់ស្កាត់ និងប្រឆាំងរាល់សកម្មភាពនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅក្នុងប្រព័ន្ធធនាគារ

- បន្តអភិវឌ្ឍធនធានមនុស្សលើឯកទេសកម្មចំណេះដឹងជំនាញ ដោយផ្តោតលើការងារអាទិភាពជាក់ស្តែង

- ពង្រឹងនិងពង្រីកសហប្រតិបត្តិការអន្តរជាតិជាមួយស្ថាប័នហិរញ្ញវត្ថុ ធនាគារកណ្តាល និងភាគីពាក់ព័ន្ធនានា ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរព័ត៌មាននិងបទពិសោធន៍ និងទទួលបានជំនួយបច្ចេកទេសអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្ស និង

- ពង្រឹងការងារទំនាក់ទំនងរបស់ធនាគារជាតិនៃកម្ពុជា ជាមួយភាគីពាក់ព័ន្ធដើម្បីបង្កើនការយល់ដឹងរបស់សាធារណជនក៏ដូចជាស្ថាប័នជំនាញនានា ពីតួនាទីគោលនយោបាយ និងវិធានការនានារបស់ធនាគារជាតិនៃកម្ពុជា ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ខ្ញុំជឿជាក់ថា សមាជិក-សមាជិកាអង្គសន្និបាតរបស់យើងពិតជាក្តាប់បាននូវខ្លឹមសារសំខាន់ៗនៃសមិទ្ធផលការងារនិងទិសដៅ ដែលលើកឡើងក្នុងអង្គសន្និបាតនាថ្ងៃនេះ និងបន្តយកទៅផ្សព្វផ្សាយនៅក្នុងនាយកដ្ឋាននិងអង្គភាពរបស់ខ្លួន ដើម្បីរួមចំណែកសម្រេចបាននូវសមិទ្ធផលបន្ថែមទៀតក្នុងឆមាសទី២ នៅឆ្នាំ២០១៦ និងនាពេលខាងមុខ ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ ដែលបានខិតខំរួមចំណែកកសាងសមិទ្ធផលយ៉ាងច្រើនសម្រាប់ធនា-

គារជាតិនៃកម្ពុជា និងកសាងប្រព័ន្ធធនាគារឱ្យកាន់តែទទួលបានជំនឿទុកចិត្តពីសាធារណជនជាតិនិងអន្តរជាតិ ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាតតាំងពីដើមរហូតដល់ចប់ និងសូមជូនពរឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**ខ្ញុំសូមប្រកាសបិទអង្គសន្និបាតរបស់យើងជាស្ថាពរ ។**

**សូមអរគុណ!**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

# សុន្ទរកថា
## ឯកឧត្តម ទេសាភិបាលនិងជាប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ក្នុងពិធីបើកកិច្ចប្រជុំជាមួយក្រុមការងារវាយតម្លៃអញ្ញមញ្ញរបស់ APG
## នៅថ្ងៃទី២៣-២៥ ខែសីហា ឆ្នាំ២០១៦

ខ្ញុំសូមគោរព!

- លោក Eliot Kennedy ឧបការីលេខាធិការដ្ឋាន APG ជាទីគោរព!
- លោកស្រី Mitali Tyagi នាយកផ្នែកជំនួយបច្ចេកទេសនិងការបណ្តុះបណ្តាលនៃ APG!
- ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសមាជិកនៃអង្គប្រជុំជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានចូលរួមក្នុងពិធីបើកកិច្ចប្រជុំដំបូងរវាងក្រុមការងារចម្រុះវាយតម្លៃអញ្ញមញ្ញ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មជាមួយក្រុមការងារវាយតម្លៃរបស់ APG។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលេខាធិការដ្ឋាន APG ដែលបានផ្តល់ការគាំទ្រយ៉ាងច្រើនមកដល់កម្ពុជានាពេលកន្លងមក និងសូមអរគុណចំពោះអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលបានខិតខំពុះពារជំរុញការងារ និងក្រុមការងារចម្រុះអន្តរក្រសួងដែលបានសហការគ្នាយ៉ាងល្អក្នុងការបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!**

មុននឹងចាប់ផ្តើមពិធីបើកកិច្ចប្រជុំរបស់យើង ខ្ញុំសូមបញ្ជាក់ជូន ឯកឧត្តម លោកជំទាវ លោក លោកស្រីថា រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់និងប្តេជ្ញាចិត្តខ្ពស់ក្នុងការបំពេញតាមឧត្តមានុវត្តប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម រហូតសម្រេចបានសមិទ្ធផលការងារជាច្រើនគួរឱ្យកត់សម្គាល់ ហើយខ្ញុំសូមការអនុញ្ញាតពីអង្គប្រជុំជម្រាបជូនអំពីសាវតា និងសមិទ្ធផលការងារទាំងនេះ។

ប្រទេសកម្ពុជាយើងធ្លាប់ទទួលរងការវាយតម្លៃអញ្ញមញ្ញពី APG ម្តងរួចហើយកាលពីដើមឆ្នាំ២០០៧ ហើយនៅពេលនោះ គឺយើងពុំទទួលបានលទ្ធផលល្អទេ ដោយសារខ្វះខាតមូលដ្ឋានច្បាប់និងយន្តការអនុវត្តច្បាប់គ្រប់គ្រាន់សម្រាប់ប្រឆាំងនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មស្របតាមស្តង់ដាររបស់ក្រុមការងារហិរញ្ញវត្ថុ (FATF)។

ចាប់តាំងពីពេលនោះមក រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការរៀបចំឱ្យមានយុទ្ធសាស្ត្រជាតិ ក៏ដូចជា ពង្រឹងក្របខ័ណ្ឌគតិយុត្តិ ដោយបានដាក់ឱ្យប្រើប្រាស់និងធ្វើវិសោធនកម្មច្បាប់គោលសំខាន់ៗ និងដាក់ចេញលិខិតបទដ្ឋានគតិយុត្តិព្រមទាំងបាន

ប្រគល់ភារកិច្ចជូនគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឱ្យតាមដានការអនុវត្តច្បាប់និងបទប្បញ្ញត្តិទាំងនេះ និងកិច្ចសហប្រតិបត្តិការក្នុងស្រុក និងអន្តរជាតិ ឱ្យមានប្រសិទ្ធភាពខ្ពស់។ សមិទ្ធផលការងារខាងលើនេះ បានឆ្លើយតបនឹងតម្រូវការជាមូលដ្ឋានរបស់ FATF រហូតធ្វើឱ្យអង្គការអន្តរជាតិនេះដកប្រទេសកម្ពុជាចេញពីបញ្ជីប្រផេះនិងបានធ្វើឱ្យប្រទេសកម្ពុជាយើងក្លាយជាសមាជិករបស់ក្រុម Egmont ថែមទៀត។ ទោះបីជា សម្រេចបានសមិទ្ធផលការងារជាទីមោទនៈទាំងនេះក៏ដោយក៏រាជរដ្ឋាភិបាលនៅតែបន្តការយកចិត្តទុកដាក់និងខិតខំប្រឹងប្រែងបន្តទៀត ជាពិសេសលើការងារកិច្ចសហការជាមួយសហគមន៍អន្តរជាតិក្នុងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ទាំងទ្វេភាគី និងពហុភាគី។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!**

ជាការកត់សម្គាល់ ការវាយតម្លៃលើកនេះនឹងផ្តោតលើការអនុវត្តតាមបច្ចេកទេស (Technical Compliance) ផង និងប្រសិទ្ធភាពនៃការអនុវត្ត (Effectiveness) ផង ដែលមានការលំបាកនិងប្រទាក់ក្រឡាជាងការវាយតម្លៃលើកមុន ដែលតម្រូវឱ្យយើងត្រូវបង្កើនការយកចិត្តទុកដាក់ខ្ពស់។ ដូច្នេះ កិច្ចប្រជុំរយៈពេល ៣ ថ្ងៃនេះ ក្រុមវាយតម្លៃនឹងប្រមូលព័ត៌មាន និងពិភាក្សាបន្ថែមលើចម្លើយដែលយើងបានផ្តល់ឱ្យនាពេលកន្លងមក។

ដូច្នេះខ្ញុំសូមស្នើឱ្យ ឯកឧត្តម លោកជំទាវ លោក លោកស្រី មេត្តាបន្តកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីសម្រេចតាមយុទ្ធសាស្ត្រ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការរួមចំណែកទប់ស្កាត់សកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ព្រមទាំងផ្តល់កិច្ចសហការល្អដល់ក្រុមវាយតម្លៃរបស់ APG ដើម្បីឱ្យដំណើរការវាយតម្លៃនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរចំពោះគណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ សូមជួបនូវពុទ្ធពរទាំង ៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបើកកិច្ចប្រជុំជាមួយក្រុមវាយតម្លៃអញ្ញមញ្ញចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបើកវគ្គគ្រូលែនលើកទី ៤ កម្រិតមូលដ្ឋាន ស្ដីពី "ភាពជាអ្នកដឹកនាំ"
## នៅធនាគារជាតិនៃកម្ពុជា ថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១៦

**សូមគោរព ៖**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីឧទ្ទេសនាម និងក្មួយៗសិក្ខាកាមជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្ដីសោមនស្សរីករាយជាអតិបរមា ដោយបានចូលរួមក្នុងពិធីបើកវគ្គគ្រូលែនលើកទី៤ បណ្ដុះបណ្ដាលកម្រិតមូលដ្ឋានស្ដីពី "**ភាពជាអ្នកដឹកនាំ**" សម្រាប់មន្ត្រី បុគ្គលិកធនាគារជាតិនៃកម្ពុជារបស់យើង ។ វគ្គនេះ គឺជាយន្តការបណ្ដុះបណ្ដាលផ្ទៃក្នុងមួយលើជំនាញផ្នែកទន់ (Soft skills) ដែលធនាគារជាតិនៃកម្ពុជាយើងបានផ្ដួចផ្ដើមបង្កើត និងអនុវត្តឡើងក្រោមរូបភាពជាការបណ្ដុះបណ្ដាលនៅនឹងកន្លែង ដោយប្រើប្រាស់ធនធានផ្ទាល់របស់យើង ទាំងផ្នែកប្រាជ្ញា និងផ្នែកសម្ភារៈ ក្នុងគោលបំណង ដើម្បីចែករំលែកព័ត៌មាននិងផ្ទេរចំណេះដឹងចំណេះធ្វើ និងបទពិសោធន៍អនុវត្តការងារជាក់ស្ដែង ជាពិសេសផ្នែកទ្រឹស្ដីនិងការអនុវត្តក្របខ័ណ្ឌភាពជាអ្នកដឹកនាំ ជូនមន្ត្រីបុគ្គលិកជាអ្នកបន្តវេនជំនាន់ក្រោយ ដើម្បីបន្តនិរន្តរភាពការងាររបស់យើង ឆ្ពោះទៅរកការអភិវឌ្ឍក្នុងក្របខ័ណ្ឌនៃសមាហរណកម្ម និងសេរីភាវូបនីយកម្មនៅក្នុងតំបន់ និងពិភពលោកនាពេលបច្ចុប្បន្ន ។

ដើម្បីជំរុញការអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុ ការអភិវឌ្ឍធនធានមនុស្សត្រូវបានចាត់ទុកជាកត្តាគន្លឹះនៅក្នុងការងារប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា ក្រោយពេលដែលកម្ពុជាធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់អាស៊ាន និងពិភពលោក ។ ការបណ្ដុះបណ្ដាលធនធានមនុស្ស គឺត្រូវធ្វើឡើងទាំងផ្នែកកម្លាំងកាយនិងកម្លាំងប្រាជ្ញា ស្មារតី សំដៅដល់ការអភិវឌ្ឍចំណេះដឹងផ្នែកទ្រឹស្ដីនិងការអនុវត្ត (IQ) ព្រមទាំងសីលធម៌និងចរិយាធម៌ (EQ) ។

ការកសាងសមត្ថភាពធនធានមនុស្សល្អ ការគ្រប់គ្រង និងចាត់ចែងធនធានមនុស្សប្រកបដោយប្រសិទ្ធភាព គួបផ្សំនិងមានធនធានធម្មជាតិ ធនធានហិរញ្ញវត្ថុ និងស្ថិរភាពនយោបាយផងនោះ នឹងធ្វើឱ្យប្រទេសជាតិមានការអភិវឌ្ឍយ៉ាងឆាប់រហ័ស ។ ការណ៍នេះ ធនាគារជាតិនៃកម្ពុជា បានខិតខំពង្រឹងការអភិវឌ្ឍធនធានមនុស្សរបស់ខ្លួនជាប់ជាប្រចាំដូចភ្លៀងរលឹម តាមរយៈការធ្វើឯកទេសកម្មទៅលើមុខជំនាញសំខាន់ៗជាច្រើន រួមមាន ការត្រួតពិនិត្យធនាគារ បញ្ញត្តិកម្ម សវនកម្ម គណនេយ្យ ការរៀបចំគោលនយោបាយរូបិយវត្ថុ និងការគ្រប់គ្រងទុនបម្រុងអន្តរជាតិជាដើម ស្របតាមនិន្នាការសេដ្ឋកិច្ចពឹង

ផ្អែកលើចំណេះដឹង ។ នៅពេលដែលកម្ពុជាសម្បូរធនធានមនុស្សល្អ មានភាពឆ្នៃប្រឌិតខ្ពស់ និងមានជំនាញបច្ចេកទេសច្បាស់លាស់ច្រើននោះ គឺជាឧត្តមភាពប្រកួតប្រជែងមួយក្នុងការធ្វើសមាហរណកម្មដោយស្មើភាព និងស្មើសិទ្ធិក្នុងតំបន់និងពិភពលោក ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីឧទ្ទេសនាម និងក្មួយៗសិក្ខាកាមជាទីមេត្រី!**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបអំពីអត្ថប្រយោជន៍នៃចំណេះដឹងទាក់ទងនិងប្រធានបទ ភាពជាអ្នកដឹកនាំនៅក្នុងស្ថាប័នធនាគារកណ្តាលខ្លះសម្រាប់មន្ត្រីដឹកនាំនិងសិក្ខាកាមនៃវគ្គនេះ ដូចតទៅ ៖ បើយើងក្រឡេកមើលពីបទពិសោធន៍កន្លងមកក្នុងដំណាក់កាលនៃវិបត្តិសេដ្ឋកិច្ច ការរៀបចំនិងអនុវត្តយុទ្ធសាស្ត្រនានាសម្រាប់ដោះស្រាយវិបត្តិកុំឱ្យមានឥទ្ធិពលខ្លាំងក្លាមកលើសេដ្ឋកិច្ច និងសង្គមនោះបានបង្ហាញយ៉ាងជាក់ច្បាស់អំពីសមត្ថភាពជាអ្នកដឹកនាំ និងម្ចាស់ការលើសភាពការណ៍របស់ថ្នាក់ដឹកនាំនៃធនាគារកណ្តាល។ ដោយឃើញពីសារៈសំខាន់នៃចំណេះដឹងទាក់ទងនឹងភាពជាអ្នកដឹកនាំនេះហើយ ទើបបណ្តាធនាគារកណ្តាលនិងអង្គការអន្តរជាតិនានា តួយ៉ាងដូចជាមជ្ឈមណ្ឌលស៊ាសិនជាដើម បានចាប់ផ្តើមយកចិត្តទុកដាក់ និងរៀបចំវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំនៅក្នុងធនាគារកណ្តាល និងប្រធានបទពាក់ព័ន្ធផ្សេងទៀតជារៀងរាល់ឆ្នាំ ក្នុងគោលបំណងពង្រឹងសមត្ថភាពនិងប្រសិទ្ធភាពការងារតាមរយៈការសិក្សាស្វែងយល់លើបញ្ហាប្រឈមនានាក្នុងការដឹកនាំ សមត្ថភាពដឹកនាំ និងនិន្នាការវិវត្តថ្មីៗលើការកសាងសមត្ថភាពសម្រាប់អ្នកដឹកនាំទាំងក្នុងនាមជាបុគ្គល និងស្ថាប័ន ។

ចំពោះធនាគារជាតិនៃកម្ពុជាយើងវិញ ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំត្រូវបានធ្វើឡើងក្រោមរូបភាពជាការចាត់បញ្ជូនមន្ត្រីបុគ្គលិកចូលរួមវគ្គសិក្សា និងសិក្ខាសាលាជាមួយធនាគារកណ្តាលជាដៃគូនិងស្ថាប័នអន្តរជាតិផ្សេងៗ ។ ប៉ុន្តែ បើទោះបីជាយើងខិតខំបណ្តុះបណ្តាលមន្ត្រីយើងយ៉ាងច្រើនក៏ដោយ ក៏យើងនៅតែទទួលស្គាល់ថា សមត្ថភាពធនធានមនុស្សក្នុងជំនាញភាពជាអ្នកដឹកនាំនេះមិនទាន់គ្រប់គ្រាន់នៅឡើយ។ ហេតុដូចនេះហើយ ទើបធនាគារជាតិនៃកម្ពុជាបានរៀបចំវគ្គគូលែនបណ្តុះបណ្តាលកម្រិតមូលដ្ឋានស្តីពីភាពជាអ្នកដឹកនាំនេះឡើង ដោយមានការចូលរួមធ្វើបទឧទ្ទេសនាមពីមន្ត្រីដែលមានបទពិសោធន៍ក្នុងការដឹកនាំអនុវត្តការងារប្រចាំថ្ងៃ ធ្លាប់ឆ្លងកាត់វគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំនៅឯបរទេស ។ ជាពិសេសវគ្គគូលែន តែងតែត្រូវបានថ្នាក់ដឹកនាំជាន់ខ្ពស់ និងជំនាញការប្រចាំធនាគារជាតិនៃកម្ពុជា ចូលរួមចែករំលែកបទពិសោធន៍ភាពជាអ្នកដឹកនាំផ្ទាល់ខ្លួនផងដែរ ចំនួនបីលើករួចមកហើយ ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីឧទ្ទេសនាម និងក្មួយៗសិក្ខាកាមជាទីមេត្រី!**

សរុបមក ផ្អែកលើកិច្ចខិតខំប្រឹងប្រែងនាពេលកន្លងមក និងបន្តខិតខំប្រឹងប្រែងបន្ថែមទៀតរបស់មន្ត្រីបុគ្គលិកយើង ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា ធនាគារជាតិនៃកម្ពុជានឹងសម្រេចបាននូវសមិទ្ធផលថ្មីៗច្រើនទៀតឈានទៅសម្រេចបាននូវចក្ខុវិស័យរយៈពេលវែងរបស់ខ្លួនគឺ អភិវឌ្ឍធនាគារជាតិនៃកម្ពុជាឱ្យរឹងមាំ ដើម្បីរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច លើកកម្ពស់ជីវភាពប្រជាពលរដ្ឋ។ ការគ្រប់គ្រងបែងចែកធនធានមនុស្សប្រកបដោយប្រសិទ្ធភាពនាំមកនូវនិរន្តរភាពការងាររបស់ស្ថាប័ន ។ សមត្ថភាពធនធានមនុស្សភាពជា

អ្នកដឹកនាំនេះ ត្រូវបានលើកកម្ពស់ និងពង្រឹងជាប្រចាំ សំដៅធ្វើយ៉ាងណាឱ្យក្មួយៗដែលជាកម្លាំងបន្តវេនរបស់ធនាគារជាតិនៃកម្ពុជាសម្រាប់ពេលបច្ចុប្បន្ន និងទៅអនាគតមានទស្សនាទានភាពជាអ្នកដឹកនាំផ្លាស់ប្តូរផ្នត់គំនិតនិងឥរិយាបថហ៊ានតស៊ូលះបង់នឹងការលំបាកដើម្បីបុព្វហេតុស្ថាប័ន ។

មុននឹងបញ្ចប់ ខ្ញុំសូមផ្តាំផ្ញើដល់ក្មួយៗជាសិក្ខាកាមទាំងអស់ថា ក្មួយៗត្រូវប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវសីលធម៌និងគុណធម៌ ភាពអំណត់អត់ធ្មត់និងស្មោះត្រង់បន្ថែមលើសពីចំណេះដឹងជំនាញបច្ចេកទេសដែលខ្លួនមាន ដែលទាំងនេះជាកត្តាមិនអាចខ្វះបានដើម្បីឈានទៅរកភាពជោគជ័យទាំងការងារនិងបុគ្គល។

ជាទីបញ្ចប់ ខ្ញុំសូមឱ្យក្មួយៗជាសិក្ខាកាមខិតខំយកចិត្តទុកដាក់ស្តាប់ការឧទ្ទេសនាមរបស់មន្ត្រីឧទ្ទេសនាម ដើម្បីទទួលយកចំណេះដឹងពីវគ្គនេះទៅអនុវត្តការងារប្រកបដោយប្រសិទ្ធភាពនិងសូមជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីឧទ្ទេសនាម និងក្មួយៗទាំងអស់ដែលមានវត្តមាននៅទីនេះសូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសបើកវគ្គគូលែនលើកទី៤ កម្រិតមូលដ្ឋានស្តីពី "ភាពជាអ្នកដឹកនាំ" ចាប់ពីពេលនេះតទៅ។

**សូមអរគុណ**!

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

# សុន្ទរកថា
# ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់ប្រកាសនីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារ ជំនាន់ទី២១ ២២ និង២៣

នៅសាលមហោស្រពកោះពេជ្រ ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៦

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ាលោក លោកស្រី សាស្ត្រាចារ្យ និងក្មួយៗនិស្សិត ជាទីមេត្រី !**

ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ដោយបានចូលរួមពិធីប្រគល់សញ្ញាបត្រថ្នាក់ប្រកាសនីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារ ជូនដល់និស្សិតជ័យលាភីជំនាន់ទី២១ ២២ និង ២៣ សរុបចំនួន ៣២២នាក់ ដែលបានបញ្ចប់ការសិក្សាដោយជោគជ័យពីមណ្ឌលសិក្សាបច្ចេកទេសធនាគារនាពេលនេះ ។ ខ្ញុំសូមអបអរសាទរ និងសូមកោតសរសើរយ៉ាងខ្លាំងចំពោះស្មារតីខិតខំសិក្សាបញ្ចប់មុខជំនាញធនាគារ និងហិរញ្ញវត្ថុក្នុងរយៈពេល២ឆ្នាំ កន្លងមក ។ ពេលនេះ ខ្ញុំសង្កេតឃើញក្មួយៗនិស្សិតជ័យលាភីទាំងអស់មានទឹកមុខរួសរាយ ញញឹមញញែមស្រស់ស្រាយ សប្បាយរីករាយយ៉ាងខ្លាំង ប្រកបដោយក្តីសង្ឃឹមមុតមាំ និងជឿជាក់ទៅអនាគត ។

ខ្ញុំសូមចូលរួមអបអរសាទរជាមួយ ឪពុកម្តាយ អាណាព្យាបាល សាស្ត្រាចារ្យ និងបុគ្គលិកសិក្សារបស់ក្មួយៗ ចំពោះលទ្ធផលដ៏ល្អប្រសើរ ដែលបានឆ្លុះបញ្ចាំងតាមរយៈរបាយការណ៍ របស់លោកនាយកមណ្ឌលសិក្សាបច្ចេកទេសធនាគារមុននេះ ។ ខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ថាលទ្ធផលនេះគឺជាមោទនភាពរួមរបស់យើងទាំងអស់គ្នា របស់ក្មួយៗផ្ទាល់ផង របស់ឪពុកម្តាយផងរបស់សាស្ត្រាចារ្យផងរបស់សាលាផង និងជាមោទនភាពរបស់ប្រទេសជាតិយើងផងដែរ ដែលបានទទួលពលរដ្ឋល្អមានការអប់រំ ហើយបានក្លាយជាគ្រាប់ពូជប្រកបដោយសក្តានុពល និងសមត្ថភាពថ្មីចូលមកបម្រើការងារ ដើម្បីរួមចំណែកអភិវឌ្ឍសង្គមជាតិមាតុភូមិយើងបន្ថែមទៀត។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំ ក៏ដូចជាសាស្ត្រាចារ្យ និងបុគ្គលិកសិក្សានៃមណ្ឌលសិក្សាបច្ចេកទេសធនាគារ ដែលបានជួយបណ្តុះបណ្តាល ចែករំលែកចំណេះដឹង និងបទពិសោធន៍ល្អៗជូនដល់ក្មួយៗនិស្សិតកន្លងមក ។ លទ្ធផលដែលក្មួយៗសម្រេចបាននេះ ពិតជាបានរួមចំណែកក្នុងការអនុវត្តគោលនយោបាយ

អភិវឌ្ឍធនធានមនុស្សរបស់រាជរដ្ឋាភិបាល ដើម្បីឆ្លើយតបទៅនឹងទីផ្សារការងារទាំងក្នុងស្រុក ក៏ដូចជានៅក្នុងតំបន់ និងពិភពលោក ស្របតាមចរន្តនៃការអភិវឌ្ឍរីកចម្រើននៃសេដ្ឋកិច្ចជាតិ និងសកលភាវូបនីយកម្ម ។ ការរីកចម្រើននៃធនធានមនុស្ស ជាពិសេស លើជំនាញធនាគារ ក៏ដើរតួនាទីយ៉ាងសំខាន់ផងដែរក្នុងការជំរុញឲ្យវិស័យធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជាអភិវឌ្ឍរីកចម្រើនបានឆាប់រហ័ស និងរឹងមាំស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រាជរដ្ឋាភិបាល ។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ាលោក លោកស្រី សាស្ត្រាចារ្យ និងក្មួយៗនិស្សិត ជាទីមេត្រី !**

ខ្ញុំសូមជម្រាបថា សសរស្តម្ភសំខាន់ទាំងបួនរបស់រាជរដ្ឋាភិបាលសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បីកំណើនការងារសមធម៌ និងប្រសិទ្ធភាពនៅកម្ពុជាបាន និងកំពុងដើរតួជាត្រីវិស័យសំខាន់សម្រាប់គាំទ្រដំណើរការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមលើគ្រប់វិស័យ ហើយមានលក្ខណៈសមាហរណកម្មជាមួយនឹងប្រទេសក្នុងតំបន់ ក្នុងនោះ កត្តាសុខសន្តិភាព ស្ថិរភាពនយោបាយ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយសង្គម គឺជាបុរេល័ក្ខខ័ណ្ឌដ៏សំខាន់ចាំបាច់មិនអាចខ្វះបានសម្រាប់គាំទ្រការអភិវឌ្ឍប្រទេសជាតិ ។

ឈរលើទស្សនវិស័យនេះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់អាទិភាពចំនួន ៤ គឺ **ផ្លូវ ទឹក ភ្លើង និងមនុស្ស** សម្រាប់ស្ថានភាពសេដ្ឋកិច្ចសង្គមនៅកម្ពុជា។ ក្នុងយុគសម័យសេដ្ឋកិច្ចពុទ្ធិខាងបច្ចេកវិទ្យាព័ត៌មាន ឧត្តមភាពប្រកួតប្រជែងរបស់ប្រជាជាតិមួយ អាស្រ័យជាសំខាន់លើកត្តាធនធានមនុស្ស ដែលមានមូលដ្ឋានចំណេះដឹងខ្ពស់ ទូលំទូលាយសម្បូរបែប មានភាពឆ្នៃប្រឌិតខ្ពស់និងមានជំនាញច្បាស់លាស់ឆ្លើយតបចំពោះតម្រូវការជាក់ស្តែង។ ប្រការនេះ តម្រូវឲ្យរាជរដ្ឋាភិបាលយកចិត្តទុកដាក់ខ្ពស់
លើការអភិវឌ្ឍធនធានមនុស្សក្នុងបរិបទដែលកម្ពុជាកំពុងធ្វើសមាហរណកម្មខ្លួន
ក្នុងសហគមន៍សេដ្ឋកិច្ចតំបន់ ទន្ទឹមនឹងការបង្កើនរបៀបវារៈអាទិភាពវិនិយោគសាធារណៈលើវិស័យ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត **ផ្លូវ ទឹក និងភ្លើង** ដែលជាឆ្អឹងខ្នងនៃការអភិវឌ្ឍជាតិផងដែរ ។

អនុវត្តតាមស្មារតីនេះ កន្លងមកធនាគារជាតិនៃកម្ពុជាបានខិតខំរួមចំណែកបណ្តុះបណ្តាលធនធានមនុស្សយ៉ាងច្រើនលើគ្រប់រូបភាព តាមរយៈពេលខ្លីនិងវែង ទាំងនៅក្នុងស្រុក និងនៅបរទេស ។ នៅក្នុងស្រុក យើងបានបង្កើតមណ្ឌលសិក្សាបច្ចេកទេសធនាគារបញ្ជូនមន្ត្រី បុគ្គលិកទៅសិក្សានៅតាមមហាវិទ្យាល័យនានា និងបង្កើតកម្មវិធីសិក្សាប្រចាំឆ្នាំនៅទីស្នាក់ការកណ្តាល។ នៅបរទេស យើងបញ្ជូនមន្ត្រីបុគ្គលិកយើងទៅសិក្សារយៈពេលខ្លី និងវែង ថ្នាក់បរិញ្ញាបត្រ និងអនុបណ្ឌិត ក្រោមកិច្ចឧបត្ថម្ភគាំទ្រពីកម្មវិធីអាហារូបករណ៍នៃបណ្តាប្រទេសជាមិត្ត និងជំនួយបច្ចេកទេសរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដូចជា IMF, WB, ADB, JICE, JICA និង KOICA ជាដើម។

ការបណ្តុះបណ្តាលត្រូវបានធ្វើឡើងស្របតាមការវិវត្តនៃវិស័យសេដ្ឋកិច្ចជាតិ និងអន្តរជាតិ ហើយការពង្រឹងសមត្ថភាព និងការគ្រប់គ្រងធនធានមនុស្សត្រូវបានយកចិត្តទុកដាក់ជាប្រចាំ តាមរយៈការបណ្តុះបណ្តាលទាំងក្នុងនិងក្រៅប្រទេស និងការជ្រើសរើសមន្ត្រីចូលបម្រើការងារប្រកបដោយគុណវុឌ្ឍិ ។ ធនាគារជាតិនៃកម្ពុជាបានរៀបចំការបណ្តុះបណ្តាលផ្ទៃក្នុងនូវជំនាញសំខាន់ៗដូចជា ភាពជាអ្នកដឹកនាំ ការវិភាគហិរញ្ញវត្ថុ និងការសិក្សាតាមប្រព័ន្ធអនឡាញក្រោមកម្មវិធី FSI Connect របស់ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) ជាពិសេស ពាក់ព័ន្ធនឹងជំនាញគណនេយ្យ សញ្ញាបត្រ CPA និងជំនាញវិភាគហិរញ្ញវត្ថុ សញ្ញាបត្រ CFA ដើម្បីពង្រឹងសមត្ថភាពមន្ត្រីបុគ្គលិកលើការត្រួតពិនិត្យធនាគារ ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានបន្តបង្កើនសមត្ថភាពនិងអភិវឌ្ឍធនធានមនុស្សនៅក្រៅប្រទេស តាមរយៈការចាត់បញ្ជូនមន្ត្រីបុគ្គលិកឲ្យចូលរួមវគ្គសិក្សារយៈពេលខ្លី-វែង ការប្រជុំ ទស្សនកិច្ច និងសិក្ខាសាលាជាដើមដែលត្រូវបានធ្វើឡើងតាមការអញ្ជើញ ការឧបត្ថម្ភរបស់ស្ថាប័នអន្តរជាតិ និងធនាគារកណ្តាលនានា។

សមិទ្ធផលដែលទទួលបានខាងលើអាស្រ័យដោយការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការដាក់ចេញគោលនយោបាយប្រកបដោយប្រសិទ្ធភាព ធានាបាននូវសន្តិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ និងធ្វើកំណែទម្រង់លើគ្រប់វិស័យធ្វើពិពិធកម្មលើមូលដ្ឋានសេដ្ឋកិច្ចស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ឆ្នាំ២០១៣-២០១៨ ដើម្បីកំណើនការងារសមធម៌និងប្រសិទ្ធភាព ហើយនិងស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០។

គោលដៅរយៈពេលវែងរបស់យើង គឺបន្តបណ្តុះបណ្តាលធនធានមនុស្សលើផ្នែកជំនាញឯកទេស ។ ពេលនេះ ក្មួយៗមានសេចក្តីរីករាយខ្លាំងណាស់ជាមួយនឹងលទ្ធផលដ៏ប្រសើរនេះ ។ បន្ទាប់ពីបានបញ្ចប់ការសិក្សា និងទទួលសញ្ញាបត្រនេះទៅ ដើម្បីឲ្យក្មួយៗទទួលបានជោគជ័យបន្ថែមទៀត សូមក្មួយៗត្រូវខិតខំព្យាយាមរៀនសូត្របន្ថែមលើផ្នែកជំនាញ និងបង្កើននូវ ៖

**១**/- ចំណេះដឹងផ្នែកភាសាបរទេស ព្រោះភាសាបរទេសគឺជាស្ពានសម្រាប់ចម្លងចំណេះដឹងការងារ និងការប្រាស្រ័យទាក់ទង ខណៈពេលដែលកម្ពុជាយើងធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងតំបន់និងពិភពលោក ។

**២**/- ចំណេះដឹងផ្នែកព័ត៌មានវិទ្យា នឹងជួយសម្រួលយ៉ាងច្រើនដល់ការប្រើប្រាស់នូវមូលធនបញ្ញាសម្រាប់ការងារប្រចាំថ្ងៃ ។ និយាយឲ្យខ្លី ដោយសារតែបច្ចេកវិទ្យាទំនើបទើបមូលធនបញ្ញាបានរីកធំធាត់យ៉ាងឆាប់រហ័ស និងសេដ្ឋកិច្ចមានការអភិវឌ្ឍ ។ បច្ចុប្បន្ននេះ ជំនាញកុំព្យូទ័រ គឺជាមធ្យោបាយយ៉ាងសំខាន់សម្រាប់ការប្រាស្រ័យទាក់ទង និងធ្វើការគ្រប់សកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្មនិងវិនិយោគនៅក្នុងប្រទេស និងអន្តរជាតិ ។

**៣**/- ការគោរពវិន័យការងារនិងស្មារតីអភិវឌ្ឍខ្លួនឯងគឺជាកត្តាផ្ទៃក្នុងយ៉ាងសំខាន់របស់ក្មួយៗផ្ទាល់ ។ ភាពជោគជ័យនៃជីវិតការងាររបស់យើងបន្ទាប់ពីមានសញ្ញាបត្រ គឺត្រូវខិតខំធ្វើ

ការងារប្រកបដោយគុណធម៌ ភាពអំណត់ ភាពស្មោះត្រង់ មានស្មារតីទទួលខុសត្រូវខ្ពស់ និងគោរពវិន័យការងារ ទើបអនាគតរបស់ក្មួយៗបានទទួលជោគជ័យទាំងក្នុងការងារនិងជីវិតផ្ទាល់ខ្លួនផងដែរ ។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ាលោក លោកស្រី សាស្ត្រាចារ្យ និងក្មួយៗនិស្សិត ជាទីមេត្រី !**

សរុបមក ប្រទេសជាតិមួយមានការអភិវឌ្ឍ និងរីកចម្រើនទៅបាន គឺអាស្រ័យនឹងការគ្រប់គ្រង ការបែងចែកធនធានមនុស្សបានល្អស្របតាមជំនាញ និងសមត្ថភាព ។

ពេលនេះ គឺចំពេលដែលក្មួយៗត្រូវចាប់ផ្តើមចូលទៅក្នុងសមរភូមិការងារហើយ ។ ក្មួយៗត្រូវយល់ថាក្មួយៗនេះហើយជាកម្លាំងចលករចូលរួមជំរុញឲ្យមានកំណើនសេដ្ឋកិច្ច ដែលជាដង្ហើមរបស់ជាតិយើង។ ការបញ្ចប់ការសិក្សារបស់ក្មួយៗនៅពេលនេះ កំពុងរួមចំណែកយ៉ាងសំខាន់ក្នុងការអនុវត្តគោលនយោបាយរបស់ជាតិ អំពីការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា និងកិច្ចខិតខំប្រឹងប្រែងឈានទៅរកការរីកលូតលាស់កាន់តែទូលំទូលាយនៃសេដ្ឋកិច្ចកម្ពុជានៅថ្ងៃអនាគត ។

ក្មួយៗត្រូវចាំថា មនុស្សម្នាក់ៗមានសិល្បៈសម្រាប់ជីវិតនិងការងារផ្សេងៗគ្នា ឬនិយាយម្យ៉ាងទៀតថា មនុស្សម្នាក់ៗនាំមកនូវសមិទ្ធផលផ្សេងៗគ្នា ទោះបីជាបងប្អូនបង្កើត សិស្សរួមគ្រូ រួមគម្ពីរក៏ដោយ ហេតុនេះលទ្ធផលល្អយ៉ាងណា ពូកែយ៉ាងណា គឺអាស្រ័យលើក្មួយៗ និងសិល្បៈរបស់ក្មួយៗហើយ ។ ប៉ុន្តែ ទោះបីសមត្ថភាពពូកែយ៉ាងណាក៏ដោយក្មួយៗត្រូវប្រកាន់ខ្ជាប់នូវវិន័យ សីលធម៌ គុណធម៌ក្នុងការរស់នៅ និងក្នុងការងាររបស់ខ្លួនជានិច្ច ។ ជាមួយគ្នានេះក្មួយៗត្រូវដឹងទៀតថា សមត្ថភាពតាមចំណេះដឹងតែមួយមុខគត់ពិតជាមិនគ្រប់គ្រាន់ឡើយ គឺក្មួយៗត្រូវមានការវាងវៃ មានការខិតខំតស៊ូប្រឹងប្រែង មានគំនិតច្នៃប្រឌិត មានការទទួលខុសត្រូវពិតប្រាកដនិងសុចរិត ទើបយើងអាចមានជោគជ័យបន្ថែមទៀតនៅក្នុងអាជីពនាអនាគត ។ ជារួម គឺក្មួយៗត្រូវមានបុគ្គលិកលក្ខណៈសម្បត្តិល្អប្រពៃជាប្រចាំ ទើបផលនោះនឹងជួយឲ្យឆាកជីវិតរបស់ក្មួយជួបប្រទះនូវជោគជ័យ និងសុខដុមរមនា ។

ខ្ញុំសូមឆ្លៀតឱកាសនេះ ថ្លែងអំណរគុណដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងភ្ញៀវកិត្តិយសទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងពិធីនេះ ហើយសូមថ្លែងអំណរគុណផងដែរ ចំពោះ លោក លោកស្រីជាសាស្ត្រាចារ្យ និងគ្រូឧទ្ទេសនាមទាំងអស់ ដែលបានចែករំលែកចំណេះដឹង បទពិសោធន៍ និងការអនុវត្តជាក់ស្តែងដល់ក្មួយៗនិស្សិតឲ្យទទួលបានជោគជ័យគួរជាទីមោទនៈ។

ទន្ទឹមនឹងនេះ ខ្ញុំសូមលើកទឹកចិត្តនិងជំរុញឲ្យគណៈគ្រប់គ្រង សាស្ត្រាចារ្យ និងបុគ្គលិកនៃមណ្ឌលសិក្សាបច្ចេកទេសធនាគារទាំងអស់ បន្តយកចិត្តទុកដាក់អភិវឌ្ឍធនធានមនុស្ស និងអង្គភាពរបស់ខ្លួនឲ្យកាន់តែមានការអភិវឌ្ឍរីកចម្រើនបន្ថែមទៀត ។

ជាថ្មីម្តងទៀត ខ្ញុំសូមផ្តាំផ្ញើដល់ក្មួយៗនិស្សិតទាំងអស់ ក្នុងនាមក្មួយៗជាទំពាំងស្នងឬស្សី ចូរក្មួយៗយកសមត្ថភាពនិងចំណេះដឹងដែលក្មួយៗទទួលបានទៅប្រើប្រាស់ឲ្យអស់សមត្ថភាព និងបង្កើនតម្លៃក្នុងការរួមចំណែកការពារនិងកសាងមាតុភូមិជាទីស្នេហារបស់យើង ។ សូមក្មួយៗ បន្តការសិក្សាស្រាវជ្រាវ ហើយត្រូវចាត់ទុកថាការរៀនសូត្រ គឺជាដំណើរការមួយដែលមិនចេះចប់ ដើម្បីដុសខាត់ចំណេះដឹង និងចំណេះធ្វើរបស់ខ្លួនម្នាក់ៗឲ្យកាន់តែប្រសើរថែមទៀត ។ ចំណេះដឹងទាំងនេះ គួបផ្សំនឹងគុណធម៌ សីលធម៌ ភាពស្មោះត្រង់និងទំនួលខុសត្រូវក្នុងការងារនឹងដឹកនាំក្មួយៗទៅរកភាពជោគជ័យក្នុងជីវិត និងជាចលករអភិវឌ្ឍនិងដឹកនាំសង្គមជាតិរបស់យើងឲ្យមានការរីកចម្រើនដូចបណ្តាប្រទេសជឿនលឿនក្នុងពិភពលោក ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និង ក្មួយៗនិស្សិតទាំងអស់ទទួលបានជោគជ័យ ជាលទ្ធផលប្រកបដោយផ្លែផ្កា សូមមានជ័យជម្នះ ត្រចះត្រចង់គ្រប់ភារកិច្ច និងជួបប្រទះតែពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ៕

**សូមអរគុណ** !

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

**សុន្ទរកថា**
**ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា**
**ថ្លែងក្នុងពិធីសម្ពោធទីស្នាក់ការកណ្តាលថ្មី**
**ធនាគារ សៃហ្គន - ហាណូយ កម្ពុជា លីមីតធីត**
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦

សូមគោរព ៖

- **លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច**
- ឯកឧត្តម Dao Minh Tu ទេសាភិបាលរង ធនាគារកណ្តាលនៃប្រទេសវៀតណាម
- លោក Do Quang Hien ប្រធានអគ្គនាយក ធនាគារ អេស ហេច ប៊ី វៀតណាម
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញានិងភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក ដែលបានចូលរួមក្នុងពិធីសម្ពោធទីស្នាក់ការកណ្តាលថ្មីរបស់ធនាគារ សៃហ្គន ហាណូយ កម្ពុជា លីមីតធីត នាពេលនេះ ។ ការសម្ពោធដាក់ឱ្យដំណើរការទីស្នាក់ការថ្មីប្រកបដោយសោភ័ណភាពនិងបំពាក់ទៅដោយបច្ចេកទេសទំនើបនេះ បានឆ្លុះបញ្ចាំងឱ្យឃើញពីវឌ្ឍនភាពរបស់ធនាគារជាបន្តបន្ទាប់ ការផ្តល់ភាពងាយស្រួលដល់ការបម្រើសេវាកម្មធនាគារជូនអតិថិជន ការធ្វើពិពិធកម្មផលិតផលហិរញ្ញវត្ថុ និងការពង្រឹងសក្តានុពលប្រកួតប្រជែង ស្របតាមយន្តការទីផ្សារដើម្បីចូលរួមចំណែកក្នុងការបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពអាជីវកម្មធនាគារ និងបង្កើនជំនឿទុកចិត្តរបស់សាធារណជនមកលើវិស័យធនាគារនៅកម្ពុជា ។ ជាមួយគ្នានេះ វត្តមានរបស់វិនិយោគវៀតណាមនៅកម្ពុជា ក៏បានសបញ្ជាក់ឱ្យឃើញផងដែរពីកិច្ចសហប្រតិបត្តិការជាមិត្តភាពរវាងប្រជាជននិងប្រទេសយើងទាំងពីរកម្ពុជា-វៀតណាម ដែលបានរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាឱ្យកាន់តែរីកចម្រើន។

ខ្ញុំសូមសម្តែងការអបអរសាទរ និងកោតសរសើរចំពោះការខិតខំប្រឹងប្រែងនិងឆន្ទៈដ៏មុះមុតរបស់ភាគទុនិក គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់របស់ធនាគារសៃហ្គន ហាណូយ កម្ពុជា លីមីតធីត ក្នុងការទទួលបាននូវសមិទ្ធផលល្អៗ នាពេលកន្លងមកជាពិសេស ការបើកដំណើរការទីតាំងថ្មីនេះ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបដោយសង្ខេបអំពីស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ននិងវិស័យធនាគារនៅប្រទេសកម្ពុជា ។ កម្ពុជារក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចល្អប្រសើរ ហើយមូលដ្ឋានសេដ្ឋកិច្ចកំពុងត្រូវបានធ្វើពិពិធកម្មដើម្បីសម្រេចបានកំណើនរឹងមាំ និងប្រកបដោយចីរភាព ។ ជាក់ស្តែងក្នុងឆ្នាំ២០១៥ កម្ពុជាសម្រេចបានអត្រាកំណើនសេដ្ឋកិច្ច ៧% ដែលគាំទ្រដោយកំណើនវិស័យសំណង់ ការនាំចេញផលិតផលវាយនភ័ណ្ឌនិងទេសចរណ៍ហើយនៅឆ្នាំ២០១៦នេះ សេដ្ឋកិច្ចកម្ពុជារំពឹងថា កើនឡើងប្រមាណ ៧,១% ។ ខណ:អត្រាអតិផរណាបន្តស្ថិតនៅកម្រិតអាចគ្រប់គ្រងបានក្នុងរង្វង់ ៣% ។ សមិទ្ធផលដ៏គួរឱ្យកត់សម្គាល់ទាំងអស់នេះ អាចសម្រេចទៅបានដោយសារកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងការរក្សាបានសន្តិសុខនយោបាយនិងសុខដុមរមនាសង្គម។

ដោយឡែក ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជានៅតែបន្តតាមដានអនុវត្តការត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុជាប្រចាំ និងធ្វើបច្ចុប្បន្នកម្មបទប្បញ្ញត្តិឱ្យបានទាន់ពេលវេលា ដើម្បីឆ្លើយតបតាមការវិវឌ្ឍយ៉ាងឆាប់រហ័សនៃវិស័យធនាគារនិងហិរញ្ញវត្ថុ និងស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០ របស់រាជរដ្ឋាភិបាល ។ ជាក់ស្តែងនាពេលថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាបានចេញផ្សាយនូវប្រកាសស្តីពីអនុបាតក្របខណ្ឌសន្ទនីយភាព ប្រកាសស្តីពីដើមទុនចុះបញ្ជីអប្បបរមា និងប្រកាសស្តីពីអនុបាតប្រុងប្រយ័ត្នមួយចំនួនទៀត ដើម្បីពង្រឹងមូលដ្ឋានដើមទុនឱ្យកាន់តែរឹងមាំ និងបង្កើនភាពធន់រយ:ពេលខ្លីទៅនឹងហានិភ័យសន្ទនីយភាពក្នុងអំឡុងពេលមានវិបត្តិ ។ គិតត្រឹមខែមិថុនា ឆ្នាំ២០១៦ វិស័យធនាគារមានការអភិវឌ្ឍរីកចម្រើនគួរឱ្យកត់សម្គាល់ តាមរយ:ការកើនឡើងនៃទ្រព្យសកម្ម ចំនួន ២២,១៦% ឥណទាន ២៣,៩២% និងប្រាក់បញ្ញើ ២០,១៨% ធៀបនឹងរយ:ពេលដូចគ្នាឆ្នាំមុន ស្របពេលដែលឥណទានមិនដំណើរការ (NPL) នៅតែស្ថិតក្នុងកម្រិតទាបប្រមាណ ៣,០៨% ។ ទន្ទឹមនឹងនេះ វិស័យធនាគារក៏កំពុងចូលរួមចំណែកយ៉ាងខ្លាំងក្លាក្នុងការជំរុញបរិយាប័ន្នហិរញ្ញវត្ថុ ដើម្បីបង្កើនប្រសិទ្ធភាពអាជីវកម្ម បង្កើតឱកាសការងារដល់ប្រជាពលរដ្ឋនៅតាមជនបទ កាត់បន្ថយគម្លាតចំណូលនិងភាពក្រីក្រ ដែលមានសារ:សំខាន់ក្នុងការគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងសមភាព។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!**

ជាថ្មីម្តងទៀត ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ដល់ការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំបុគ្គលិកធនាគារ សៃហ្គន ហាណូយ កម្ពុជា លីមីតធីត ក្នុងការចូលរួមចំណែកពង្រីកសេវាធនាគារឱ្យកាន់តែទូលំទូលាយតាមរយ:ការនាំមកនូវបទពិសោធន៍បច្ចេកទេស និងផលិតផលហិរញ្ញវត្ថុថ្មីៗ ដើម្បីបំពេញសេចក្តីត្រូវការរបស់អតិថិជនបន្ថែមទៀតនៅពេលបច្ចុប្បន្ន ក៏ដូចជានៅពេលអនាគត។ ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថាធនាគារ សៃហ្គន ហាណូយ កម្ពុជា លីមីតធីត នឹងបន្តរក្សាកិច្ចសហប្រតិបត្តិការល្អជាមួយធនាគារជាតិនៃកម្ពុជាក្នុងការអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយឱ្យបានខ្ជាប់ខ្ជួន និងពង្រឹងស្មារតីប្រុងប្រយ័ត្នក្នុងការកាត់បន្ថយហានិភ័យប្រតិបត្តិការរបស់ធនាគារផ្ទាល់ ដើម្បីរក្សាបាននូវប្រសិទ្ធភាព និង

សុវត្ថិភាពក្នុងប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។

ជាទីបញ្ចប់ខ្ញុំសូមឆ្លៀតឱកាសនេះ ប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់ ដែលបានអញ្ជើញចូលរួម សូមជួបតែអាយុយឺនយូរ សុខភាពល្អ កម្លាំងមាំមួន ប្រាជ្ញាវាងវៃ និងជ័យជម្នះគ្រប់ភារកិច្ចកុំបីឃ្លៀងឃ្លាតឡើយ និងសូមជូនពរថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកទាំងអស់របស់ធនាគារ សៃហ្គន ហាណូយ កម្ពុជា លីមីតធីត ទទួលបានជោគជ័យក្នុងប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ជានិរន្តរ៍។

**សូមអរគុណ** !

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

ធនាគារជាតិ នៃ កម្ពុជា

## សេចក្តីថ្លែងការណ៍រួម
## រវាង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ធនាគារជាតិនៃកម្ពុជា

នាពេលថ្មីៗកន្លងមកនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញថា ប្រជាកសិករបានជួបប្រទះបញ្ហាប្រឈម និងមានការលំបាកក្នុងការលក់ផលិតផលរបស់ខ្លួន ព្រមទាំងទទួលរងសម្ពាធហិរញ្ញវត្ថុ ដោយសារតម្លៃកសិផល បាននឹងបន្តធ្លាក់ចុះជាបន្តបន្ទាប់ ជាពិសេសថ្លៃស្រូវនៅដើមរដូវកាលនៃការប្រមូលផលស្រូវក្រអូប ដែលការធ្លាក់ថ្លៃនេះ បណ្តាលមកពីកត្តាសត្យានុម័តជាច្រើន រួមមានអស្ថិរភាពថ្លៃនៅលើទីផ្សារអន្តរជាតិ ។ ទន្ទឹមនោះ ការធ្លាក់ភ្លៀងយ៉ាងគំហុកនារយៈពេលជិតពីរសប្តាហ៍កន្លងមកនេះ ក៏អាចធ្វើឱ្យមានផលប៉ះពាល់ដល់គុណភាពផលិតផល និងការនាំចេញផងដែរ ប្រសិនបើកសិករ និងអាជីវករក្នុងវិស័យកសិកម្មមិនមានទុនសមស្របសម្រាប់ប្រើប្រាស់គ្រប់គ្រាន់ក្នុងរដូវប្រមូលផលនេះ ។ ដើម្បីជួយដោះស្រាយ បញ្ហាសម្ពាធហិរញ្ញវត្ថុនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា អំពាវនាវនិងលើកទឹកចិត្តចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ សូម ៖

១. បន្តការផ្តល់ឥណទាន និងបង្កើនទំហំឥណទានដល់រោងម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុន ឬពាណិជ្ជករប្រមូលទិញស្រូវ តាមលទ្ធភាពជាក់ស្តែង ដើម្បីបង្កើនលទ្ធភាពក្នុងការប្រមូលទិញស្រូវ កសិផល និងការកែច្នៃកសិផលគ្រប់ប្រភេទ សំដៅរួមចំណែករក្សាស្ថិរភាពថ្លៃស្រូវ-អង្ករ កសិផល និងទ្រទ្រង់ការកែច្នៃកសិផលនៅក្នុងប្រទេស ។

២. ពិនិត្យលទ្ធភាពអនុវត្តគោលនយោបាយទន់ភ្លន់ និងអនុគ្រោះ ចំពោះកសិករជួបប្រទះបញ្ហាជាក់ស្តែង ដែលមានឥណទានដល់កាលកំណត់សង ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជាសង្ឃឹមនិងជឿជាក់ថា គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងដៃគូពាក់ព័ន្ធទាំងអស់នឹងចូលរួមសហការ ក្នុងការជួយសម្រាលដល់ទុក្ខលំបាករបស់ប្រជាកសិករ និងសម្រាលសម្ពាធហិរញ្ញវត្ថុក្នុងវិស័យកសិកម្ម ក្នុងកាលៈទេសៈលំបាកនេះ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងពិធីបើកវេទិកាការងារក្នុងវិស័យធនាគារ "Careers in Banking Forum"

នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦

ឲឲឲ✵៚៚៚

**ជាបឋម សូមគោរព ៖**

- លោក Casey Barnett នាយកវិទ្យាស្ថានខេមអែត
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ជាទីមេត្រី!**

ថ្ងៃនេះ ក្នុងនាមធនាគារជាតិនៃកម្ពុជា ខ្ញុំមានកិត្តិយសនិងក្តីសោមនស្សរីករាយជាអនេក ដែលបានចូលរួមបើកវេទិកាស្តីពី **ការងារក្នុងវិស័យធនាគារ** ដែលរៀបចំដោយវិទ្យាស្ថានខេមអែតនាពេលនេះ។ ខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ថា វេទិកានេះមានសារៈសំខាន់ណាស់សម្រាប់យើងទាំងអស់គ្នា និងផ្តល់នូវឱកាសសម្រាប់សិស្ស និស្សិតបញ្ចប់ការសិក្សា អ្នកជំនាញវិជ្ជាជីវៈ អ្នកគ្រប់គ្រង និងអ្នកដឹកនាំវិស័យហិរញ្ញវត្ថុ បញ្ញាប្រឈម និងជាពិសេស លើឱកាសការងារក្នុងវិស័យធនាគារ ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណនិងសូមកោតសរសើរចំពោះវិទ្យាស្ថានខេមអែតដែលបានរៀបចំវេទិកានេះឡើង និងបានដើរតួនាទីយ៉ាងសកម្មក្នុងការរួមចំណែកអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា ជាពិសេស អ្នកជំនាញគណនេយ្យ ដើម្បីបំពេញតម្រូវការអភិវឌ្ឍកម្ពុជាលើគ្រប់វិស័យរួមទាំងវិស័យធនាគារផងដែរ ។ ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលបានខិតខំបំពេញការងារយ៉ាងសកម្ម និងសហការយ៉ាងជិតស្និទ្ធ ក្នុងការចូលរួមចំណែកអភិវឌ្ឍវិស័យធនាគារនៅកម្ពុជា ឱ្យកាន់តែមានបរិយាប័ន្ន និងសមាហរណកម្មជាមួយប្រទេសក្នុងតំបន់ ស្របតាមយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ។

**ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

វេទិកាថ្ងៃនេះ ស្តីពីការងារក្នុងវិស័យធនាគារ មានគោលបំណងសំខាន់ ដើម្បីផ្សព្វផ្សាយដល់និស្សិត បញ្ញវន្ត និងសាធារណជនទូទៅឱ្យយល់ដឹងពីតម្លៃដែលអ្នកជំនាញខាងគណនេយ្យអាចផ្តល់ជូនក្នុងតួនាទីជានាយកប្រតិបត្តិហិរញ្ញវត្ថុ ហិរញ្ញិក អ្នកវិភាគហិរញ្ញវត្ថុ ក្នុងគ្រប់គ្រងគណនេយ្យ និងជាសវនករផ្ទៃក្នុង ។ គណនេយ្យជាភាសាមួយដែលព័ត៌មានហិរញ្ញវត្ថុត្រូវបានប្រាស្រ័យទាក់ទង ដោយ

ធ្វើការកត់ត្រានូវសកម្មភាពសេដ្ឋកិច្ចដែលមានទំនាក់ទំនងគ្នា ហើយមានសារៈសំខាន់សម្រាប់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ក្នុងការធ្វើសេចក្តីសម្រេចចិត្ត ។ គណនេយ្យមិនមែនជារឿងថ្មីទេសម្រាប់សង្គមកម្ពុជា ។ ដូចប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានលើកឡើងពីគោលការណ៍គណនេយ្យក្នុងសន្និសីទជាតិ ស្តីពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាកាលពីពាក់កណ្តាលខែមីនាចេញពី **"ច្បាប់អរិយសត្ថា"** ដែលមានអាយុកាលប្រមាណ ៥០០ឆ្នាំ ក្នុងន័យបង្រៀនយើងឱ្យចេះប្រុងប្រយ័ត្ន ធ្វើខ្លួនឱ្យប្រកបដោយសីលធម៌ល្អ រស់នៅឱ្យមានប្រយោជន៍ និងសិក្សាពីរបៀបនៃការធ្វើពាណិជ្ជកម្មដូចតទៅ ៖

| | | |
|---|---|---|
| **វាយលេខទាត់ក្បាច់** | **សឹងផ្សំសម្រេច** | **ឱ្យបានដឹងដាន** |
| **ដឹងដើមដឹងចុង** | **ដឹងបង់ដឹងបាន** | **ដឹងគិតប្រមាណ** |
| | **កត់ត្រាបញ្ជី ។** | |
| **ឱ្យបានប្រយោជន៍** | **ប្រយ័ត្នអសោច៏** | **ជាអ្នករកស៊ី** |
| **សម្រាប់លោកិយ** | **ប្រក្រតីជាទី** | **សម្គាល់បញ្ជី** |
| | **ស្មៀនត្រាសៀវភៅ។** | |
| **គន់គិតប្រយ័ត្ន** | **អស់ទ្រព្យសម្បត្តិ** | **ឱ្យស្ទាត់ដោយនូវ** |
| **វាយលេខទាត់ក្បាច់** | **ឱ្យស្រេចឃើញផ្លូវ** | **សឹមថយចេញទៅ** |
| | **តាមផ្លូវលោកិយ ។** | |

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមចែករំលែកជាមួយ ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្មួយៗ និស្សិតពីសារៈសំខាន់របស់គណនេយ្យករជំនាញក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុដូចខាងក្រោម ៖

គណនេយ្យករជំនាញជួយធានាពីគុណភាពនៃរបាយការណ៍ហិរញ្ញវត្ថុ និងជារឿយៗដើរតួនាទីជាអ្នកការពារភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ។ ដូច្នេះ គណនេយ្យករជំនាញមានតួនាទីធានាពីគុណភាពនៃរបាយការណ៍ហិរញ្ញវត្ថុគិតពីចំណុចដំបូង ដែលតួលេខត្រូវបានរៀបចំ ។ ដូចគ្នាដែរ គណនេយ្យករជំនាញបានដើរតួនាទីសំខាន់ក្នុងការចូលរួមចំណែករក្សាស្ថិរភាពទូទៅ និងអភិវឌ្ឍសង្គម ដោយការពារវិបត្តិហិរញ្ញវត្ថុ តាមរយៈការធ្វើសំវិធានធន ដើម្បីកាត់បន្ថយហានិភ័យដែលអាចកើតមានជាយថាហេតុ ។

គណនេយ្យករជំនាញជាទ្រព្យដែលមិនអាចកាត់ថ្លៃបានសម្រាប់សហគ្រាស ។ អ្នកទាំងនោះត្រូវបានបណ្តុះបណ្តាលយ៉ាងល្អសម្រាប់ដោះស្រាយបញ្ហាប្រឈម និងការលំបាកនានាដោយប្រើប្រាស់វិធីសាស្ត្រល្អៗ ផ្តោតលើការអនុវត្តជាក់ស្តែង និងចំទិសដៅដើម្បីដោះស្រាយបញ្ហាទាំងនោះ ។ នេះជាទ្រព្យដ៏មានតម្លៃសម្រាប់អ្នកដឹកនាំ ជួយសម្រួលក្នុងការបង្កើតយុទ្ធសាស្ត្រ ផ្តល់មតិយោបល់ ជួយកាត់បន្ថយថ្លៃដើម និងកាត់បន្ថយហានិភ័យ ។

ជំនាញគណនេយ្យ ជួយពង្រឹងក្នុងការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច ដោយលើកកម្ពស់ពាណិជ្ជកម្មអន្តរជាតិ តាមរយៈការបង្កើត និងអនុវត្តតាមស្តង់ដារអន្តរជាតិដែលអនុញ្ញាតឱ្យមានការប្រៀបធៀបព័ត៌មាន បានជំរុញការហូរចូលនូវដើមទុនក្នុងប្រទេស និងបង្កើនចំណូលពន្ធដែលជាប្រភពចំណូល

ដ៏សំខាន់របស់រដ្ឋាភិបាល ។ របាយការណ៍ ហិរញ្ញវត្ថុដែលមានគុណភាពជាគន្លឹះក្នុងការលើកកម្ពស់តម្លាភាព ជួយសម្រួលដល់ការវិនិយោគ ទាំងក្នុងស្រុកនិងអន្តរជាតិ បង្កើតនូវបរិស្ថានវិនិយោគដ៏រឹងមាំ និងបង្កើនជំនឿទុកចិត្តអ្នកវិនិយោគ ដែលជួយពង្រឹងដល់ស្ថិរភាពហិរញ្ញវត្ថុដែលជាកត្តាគន្លឹះក្នុងការស្តារទំនុកចិត្តពីសាធារណជន មកលើគ្រប់វិស័យនៅក្នុងប្រទេសកម្ពុជា ។

**ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ប្រព័ន្ធធនាគារបានរីកចម្រើនគួរឱ្យកត់សម្គាល់ ទាំងវិសាលភាពនិងទំហំប្រតិបត្តិការនៅទូទាំងប្រទេស ហើយដូច្នេះមានភាពចាំបាច់លើតម្រូវការធនធាន ជាពិសេស គឺធនធានមនុស្ស ។ ក្នុងនោះ ជំនាញមួយដែលយើងមិនអាចមើលរំលងបាន គឺជំនាញគណនេយ្យ ។

បច្ចុប្បន្ន វិស័យធនាគារនៅកម្ពុជាបានអភិវឌ្ឍគួរឱ្យកត់សម្គាល់ និងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រកំណើនសេដ្ឋកិច្ច និងលើកកម្ពស់ការអភិវឌ្ឍសង្គម ហើយបាននិងកំពុងធ្វើសមាហរណកម្មចូលទៅក្នុងតំបន់ និងក្នុងពិភពលោកទៀត ។ ក្នុងបរិបទនេះ ស្របតាមទស្សនវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាលកម្ពុជា ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់លើការអភិវឌ្ឍជំនាញផ្សេងៗ តាមរយៈការធ្វើឯកទេសកម្មមុខវិជ្ជាមួយចំនួន ដូចជា ជំនាញគណនេយ្យ ហិរញ្ញវត្ថុ ការត្រួតពិនិត្យធនាគារ សវនកម្មនិងការគ្រប់គ្រងទុនបម្រុង ។ គិតមកដល់ពេលបច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាមានមន្ត្រីចំនួនបីរូប ដែលទទួលបានសញ្ញាបត្រ ACCA ហើយយើងបានទទួលអត្ថប្រយោជន៍ច្រើនពីជំនាញនេះហើយក៏មានមន្ត្រីផ្សេងៗទៀត ដែលកំពុងបន្តខិតខំរៀនសូត្រ ដើម្បីក្លាយខ្លួនជាអ្នកជំនាញក្នុងវិស័យផ្សេងៗទៀតក្នុងរយៈពេលដ៏ខ្លីខាងមុខ ។

ធនាគារជាតិនៃកម្ពុជាទទួលបានអត្ថប្រយោជន៍រួមគ្នា ជាមួយអង្គភាពគណនេយ្យជំនាញក៏ដូចជាគណនេយ្យកររបស់ស្ថាប័នហិរញ្ញវត្ថុ តាមរយៈការត្រួតពិនិត្យដល់ទីកន្លែងនិងលើឯកសារដើម្បីធានាពីសុខភាពរឹងមាំរបស់ធនាគារ ។ ការងារនេះ ផ្អែកជាសំខាន់លើការងាររបស់គណនេយ្យករ ដើម្បីធានាពីការអនុវត្តតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ និងវិធានប្រុងប្រយ័ត្នដូចមានចែងក្នុងច្បាប់ ។ ប្រការនេះ ធនាគារជាតិនៃកម្ពុជាទទួលបាននូវព័ត៌មានពីការអនុវត្តរបស់ធនាគារ ដែលអាចប្រើប្រាស់ជាវិធានក្នុងការកែលម្អស្ថាប័នទាំងនោះ និងប្រើប្រាស់ជាប្រព័ន្ធជូនដំណឹងជាមុន ដើម្បីការពារប្រព័ន្ធធនាគារទាំងមូល ។

**ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

គណនេយ្យករក្នុងវិស័យអប់រំ មានតួនាទីយ៉ាងសំខាន់ក្នុងការបង្ហាត់បង្រៀនចំណេះដឹងបច្ចេកទេសវិធីសាស្ត្រជំនាញនិងពង្រឹងការទទួលខុសត្រូវក្នុងអាជីពទៅអ្នកជំនាន់ក្រោយ ដូចដែលវិទ្យាស្ថានខេមអែតបានបំពេញក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ។

ដូចសុភាសិតមួយបានចែងថា "**ការសិក្សារៀនសូត្រ ដូចជាការទទួលទានបាយ ពុំមានទីបញ្ចប់សម្រាប់ការរៀនសូត្រទេ**" ។ មេរៀននិងបទពិសោធន៍នៃវិបត្តិហិរញ្ញវត្ថុជាច្រើនបានបញ្ជាក់ថា កិច្ចខិតខំ

ប្រឹងប្រែងក្នុងការពិនិត្យឡើងវិញលើស្តង់ដារ ការកែលម្អគុណភាពនៃការរាយការណ៍ និងធ្វើបច្ចុប្បន្នកម្ម ចំណេះនិងជំនាញចាំបាច់ត្រូវធ្វើជាបន្តបន្ទាប់ ដែលជាផ្នែកមួយយ៉ាងសំខាន់ដើម្បីពង្រឹងស្ថាបត្យកម្ម ហិរញ្ញវត្ថុអន្តរជាតិ ។ យើងចាំបាច់ត្រូវរៀនសូត្រពីកំហុសឆ្គងដែលមានកន្លងមកដើម្បីជៀសវាងពីការ ដើរជាន់ដានប្រវត្តិសាស្ត្រ ។

បើទោះបីជាយើងខិតខំប្រឹងប្រែងទទួលបានលទ្ធផលល្អដូចសព្វថ្ងៃក៏ដោយ ក៏អនុវត្តស្តង់ដារនិង ក្រមសីលធម៌ឱ្យមានប្រសិទ្ធភាពនៅតែជាកត្តាប្រឈមសម្រាប់កម្ពុជា ដោយសារភាពខ្វះចន្លោះនៃហេដ្ឋារចនា សម្ព័ន្ធ ដោយរាប់ចាប់ពីការខ្វះខាតក្នុងក្របខ័ណ្ឌច្បាប់ កង្វះធនធានមនុស្ស និងស្ថាប័នទ្រទ្រង់ផ្សេងៗ ទៀតដែលពាក់ព័ន្ធ ។ ដោយមើលឃើញពីបញ្ហាប្រឈមនេះ ចាំបាច់ត្រូវមានយន្តការច្បាស់លាស់ក្នុង ការពង្រឹងសមត្ថភាពក្នុងវិស័យនេះ ក៏ដូចជាវិធានចាស់វែងផ្សេងៗទៀតនិងត្រូវកំណត់ចំណុចអាទិភាព សម្រាប់កិច្ចការចំពោះមុខ ។ ខ្ញុំសូមថ្លែងអំណរគុណជាថ្មីចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថាប័ន ពាក់ព័ន្ធ KICPAA វិទ្យាស្ថានខេមអែតនិងវិស័យដទៃទៀតដែលបានជួយសម្រួលចូលរួមចំណែក និង ផ្គត់ផ្គង់គណនេយ្យករជំនាញដល់សេដ្ឋកិច្ចកម្ពុជាដោយរាប់ចាប់ពីពេលអតីតកាល បច្ចុប្បន្នកាល និង ទៅអនាគត។ គិតមកដល់បច្ចុប្បន្ន យើងទទួលបានសមាជិក ACCA ច្រើនជាង១៩០រូបនៅកម្ពុជា ។ នេះជាជោគជ័យដ៏ត្រចះត្រចង់ ហើយយើងរំពឹងថា នឹងទទួលបានសមាជិកច្រើនជាបន្តបន្ទាប់ទៀត ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អ្នកជំនាញទាំងអស់ ជាពិសេស គណនេយ្យករនឹងរក្សានូវវិជ្ជាជីវៈរបស់ខ្លួនស្រប ទៅតាមស្តង់ដារ ក្រមសីលធម៌ និងជំនាញឱ្យបានល្អ ដើម្បីឱ្យការអនុវត្តការងាររបស់ខ្លួនទទួលបាន លទ្ធផលល្អសម្រាប់ជាប្រយោជន៍ជូនសង្គម និងរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចកម្ពុជា ។

ជាបរិយោសាន ខ្ញុំសូមថ្លែងអំណរគុណជាថ្មីម្តងទៀតជូនចំពោះ ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស លោក លោកស្រី នាងកញ្ញា ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងវេទិកានេះ និងសូម ជូនពរឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ សូមឱ្យមានសុខភាពល្អនិងជោគជ័យគ្រប់ភារកិច្ច ។

ខ្ញុំសូមប្រកាសបើកវេទិកាការងារក្នុងវិស័យធនាគារចាប់ពីពេលនេះតទៅ ៕

**សូមអរគុណ**!

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបិទវគ្គគូលៃនលើកទី ៤ កម្រិតមូលដ្ឋាន ស្តីពី "ភាពជាអ្នកដឹកនាំ"
## នៅធនាគារជាតិនៃកម្ពុជា ថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០១៦

**សូមគោរព ៖**

**លោកជំទាវ ទេសាភិបាលរង**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីឧទ្ទេសនាម និងក្មួយៗសិក្ខាកាម ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអតិបរមា ដោយបានចូលរួមក្នុងពិធីបិទវគ្គគូលៃនលើកទី៤ កម្រិតមូលដ្ឋាន ស្តីពីភាពជាអ្នកដឹកនាំ ជាមួយ លោកជំទាវ ឯកឧត្តម លោក លោកស្រី មន្ត្រីឧទ្ទេសនាមនិងក្មួយៗសិក្ខាកាមទាំងអស់នាពេលនេះ ។ ជារួម ខ្ញុំសូមវាយតម្លៃខ្ពស់ថា វគ្គគូលៃនលើកទី៤ កម្រិតមូលដ្ឋានបានប្រព្រឹត្តទៅប្រកបដោយជោគជ័យ។ ខ្ញុំជឿជាក់ថា ក្មួយៗសិក្ខាកាមនៃវគ្គគូលៃនទាំងអស់ ពិតជាទទួលបាននូវចំណេះដឹងទាំងនេះទៅអភិវឌ្ឍខ្លួនតាមរយៈការរួមចំណែកបំពេញមុខងារ និងភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវនិងអភិវឌ្ឍធនាគារជាតិនៃកម្ពុជាឲ្យកាន់តែរឹងមាំ មានសុវត្ថិភាព និងប្រសិទ្ធភាពថែមទៀត។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកជំទាវ ទេសាភិបាលរង ថ្នាក់ដឹកនាំនិងមន្ត្រីឧទ្ទេសនាមរបស់យើងទាំងអស់ ដែលបានអញ្ជើញមកចែករំលែកចំណេះដឹងនិងបទពិសោធន៍ល្អៗជូនដល់សិក្ខាកាម។ ចំណេះដឹងនិងបទពិសោធន៍ទាំងនេះ ជាធាតុចូលយ៉ាងសំខាន់ សម្រាប់មន្ត្រីបុគ្គលិកយើងយកទៅអនុវត្តការងារប្រចាំថ្ងៃប្រកបដោយស្មារតីច្នៃប្រឌិត ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី មន្ត្រីឧទ្ទេសនាម និងក្មួយៗសិក្ខាកាម ជាទីមេត្រី !**

ខ្ញុំសូមជម្រាបថា ការងារបណ្តុះបណ្តាលនិងគ្រប់គ្រងធនធានមនុស្សនេះ ជាគោលនយោបាយបច្ចុប្បន្នរបស់រាជរដ្ឋាភិបាល ធ្វើឡើងក្នុងក្របខ័ណ្ឌសមាហរណកម្មតំបន់អាស៊ាន ហើយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

បាននិងកំពុងយកចិត្តទុកដាក់កាន់តែខ្លាំងឡើងទៅលើការអភិវឌ្ឍ "មូលធនមនុស្ស" ដែលជាកត្តាមុតស្រួចក្នុងការជួយទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចកម្ពុជា ទាំងក្នុងពេលចំពោះមុខ ទាំងសម្រាប់អនាគត ជាពិសេស ក្នុងពេលដែលកម្ពុជាមានចក្ខុវិស័យចង់ក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០ ។

"ការអភិវឌ្ឍធនធានមនុស្ស គឺជាកូនសោសម្រាប់ដោះស្រាយនូវរាល់បញ្ហាសង្គម និងសេដ្ឋកិច្ចជាតិ"។ នៅក្នុងយុគសម័យសេដ្ឋកិច្ចពុទ្ធិ និងបច្ចេកវិទ្យាព័ត៌មាននេះ ឧត្តមភាពប្រកួតប្រជែងរបស់ប្រជាជាតិមួយ អាស្រ័យជាសំខាន់លើកត្តាធនធានមនុស្សដែលមានចំណេះដឹងចំណេះធ្វើទូលំទូលាយ មានភាពច្នៃប្រឌិតនិងមានជំនាញច្បាស់លាស់។ យើងត្រូវឲ្យតម្លៃខ្ពស់ទៅលើការសិក្សារៀនសូត្រ និងស្រាវជ្រាវពីព្រោះថាកិច្ចការនេះនឹងជួយអភិវឌ្ឍបានលើគ្រប់វិស័យ និងជួយពន្លឿនសមាហរណកម្មកម្ពុជាឲ្យប្រកបដោយស្មើភាព និងស្មើសិទ្ធិក្នុងតំបន់ និងពិភពលោក និងសម្រេចបានយ៉ាងពិតប្រាកដនូវកំណើនសេដ្ឋកិច្ចមួយ ដែលពឹងផ្អែកលើចំណេះដឹងនិងធានាបាននូវឧត្តមភាពដណ្តើមឈ្នះរបស់ប្រទេសជាតិយើងផងដែរ។ វគ្គ"ភាពជាអ្នកដឹកនាំ"នេះ មានសារៈសំខាន់ណាស់ត្រូវបានគេយកចិត្តទុកដាក់ ដើម្បីបណ្តុះបណ្តាលមន្ត្រីរបស់ខ្លួនឲ្យក្លាយជាកម្លាំងបន្តវេនសម្រាប់ស្ថាប័នប្រកបដោយប្រសិទ្ធភាព ដែលហ៊ានតស៊ូលះបង់ជម្នះនឹងការលំបាកគ្រប់បែបយ៉ាង ដើម្បីបុព្វហេតុ និងអាយុជីវិតស្ថាប័ន ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ធនាគារជាតិនៃកម្ពុជាបានខិតខំបណ្តុះបណ្តាលមន្ត្រីជំនាញបានយ៉ាងច្រើនលើគ្រប់ផ្នែកនិងគ្រប់រូបភាព ប៉ុន្តែទោះបីជាយើងបានខិតខំបណ្តុះបណ្តាលមន្ត្រីបុគ្គលិកជាប់ជាប្រចាំក៏ដោយ ក៏ធនាគារជាតិនៃកម្ពុជាយើងមិនទាន់មានធនធានមនុស្សគ្រប់គ្រាន់នៅឡើយទេបើប្រៀបធៀបនឹងទំហំការងាររបស់យើងកំពុងអភិវឌ្ឍរីកចម្រើនសព្វថ្ងៃនេះ ។ នៅឆ្នាំ២០១៦នេះ មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាបានទទួលអាហារូបករណ៍ទៅសិក្សានៅបរទេស ដូចជា ប្រទេសជប៉ុន សហរដ្ឋអាមេរិក លុចហ្សំបួរ អូស្ត្រាលី ចិន និងថៃ ប្រមាណ២០នាក់ហើយ ទន្ទឹមនេះក៏មានមន្ត្រីបុគ្គលិកបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតមកពីបរទេសត្រឡប់មកបម្រើការងារវិញនៅតាមនាយកដ្ឋាននានា ។ ការរីកចម្រើននេះ ពិតជាបានរួមចំណែកយ៉ាងសំខាន់ដល់ការលើកកម្ពស់ប្រសិទ្ធភាពការងារធនាគារជាតិនៃកម្ពុជា ឲ្យឆ្លើយតបទៅនឹងយន្តការទីផ្សារបច្ចុប្បន្ន ។

កន្លងមក យើងបាននិងកំពុងបណ្តុះបណ្តាលមន្ត្រីបុគ្គលិកលើជំនាញឯកទេសកម្មខាងត្រួតពិនិត្យ បញ្ញត្តិកម្ម សវនកម្ម គណនេយ្យ ការរៀបចំគោលនយោបាយរូបិយវត្ថុ ការវិភាគសេដ្ឋកិច្ចនិងការគ្រប់គ្រងទុនបម្រុងអន្តរជាតិជាដើម ក្រោមរូបភាពជា In-house training របស់

ធនាគារសម្រាប់ទូទាត់អន្តរជាតិនិងនៅក្រៅប្រទេសជាមួយមជ្ឈមណ្ឌល SEACEN និងកម្មវិធី E-learning ជាមួយវិទ្យាស្ថាន FSI Connect រៀន online ដោយទទួលបានអ្នកសិក្សាចំនួន ១៨៧រូប ដើម្បីពង្រឹងសមត្ថភាពមន្ត្រីរបស់យើង ស្របតាមសភាពការណ៍វិវត្តនៃសេដ្ឋកិច្ច ខណៈពេលដែលកម្ពុជាកំពុងអភិវឌ្ឍខ្លួន ដើម្បីធ្វើសមាហរណកម្មចូលទៅក្នុងតំបន់ និងពិភពលោក។ ការកសាងធនធានមនុស្ស គឺជាគន្លឹះយ៉ាងសំខាន់សម្រាប់ធានានិរន្តរភាពស្ថាប័ននិងអភិវឌ្ឍប្រទេសជាតិឲ្យមានការរីកចម្រើនឈានឡើង។ ដូច្នេះការអភិវឌ្ឍធនធានមនុស្សចាំបាច់ត្រូវ ធ្វើជាប់ជាប្រចាំសម្រាប់ធានានូវនិរន្តរភាពការងាររបស់យើង ។ ជាទិសដៅសម្រាប់ធនាគារជាតិនៃកម្ពុជា យើងត្រូវបន្តលើកកម្ពស់ចំណេះដឹងបច្ចេកទេស (Technical Competencies) តាមរយៈ ការធ្វើឯកទេសកម្មមុខជំនាញផ្នែកត្រួតពិនិត្យនិងការគ្រប់គ្រងទុនបម្រុងអន្តរជាតិបន្ថែមទៀត។

ឈរលើកិច្ចខិតខំប្រឹងប្រែងនាពេលកន្លងមក និងកិច្ចខិតខំប្រឹងប្រែងបន្តទៀតរបស់យើងទាំងអស់គ្នាចាប់ពីពេលនេះទៅ ខ្ញុំមានសង្ឃឹមថា ធនាគារជាតិនៃកម្ពុជានឹងអាចសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀត ទាំងបរិមាណនិងគុណភាព ដែលជាធាតុផ្សំដ៏ចាំបាច់សម្រាប់សម្រេចបាននូវចក្ខុវិស័យរយៈពេលវែងរបស់ខ្លួន គឺកសាងនិងអភិវឌ្ឍធនាគារជាតិនៃកម្ពុជា ដែលជាអាជ្ញាធររូបិយវត្ថុជាតិឲ្យមានសុវត្ថិភាព និងលើកស្ទួយអត្តសញ្ញាណជាតិក្នុងតំបន់ ជាពិសេសអភិវឌ្ឍធនាគារជាតិនៃកម្ពុជាឲ្យរឹងមាំ ដើម្បីរួមចំណែកកសាងសង្គមកម្ពុជាមួយដែលមានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់សង្គម កំណើនសេដ្ឋកិច្ចរយៈពេលវែង ការកែលម្អជីវភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងមានមនសិការស្នេហាជាតិផ្សារភ្ជាប់គ្នា មានប្រជាជនប្រកបដោយចំណេះដឹងខ្ពស់និងវប្បធម៌ជ្រៅជ្រះ និងមានការរស់នៅប្រកបដោយសុខដុមរមនាទាំងក្នុងសង្គមជាតិ ទាំងក្នុងក្រុមគ្រួសារ ព្រមទាំងមានកិត្យានុភាពខ្ពស់លើឆាកអន្តរជាតិ ។

## លោកជំទាវ ឯកឧត្តម លោក លោកស្រី មន្ត្រីឧទ្ទេសនាម និងក្មួយៗសិក្ខាកាម ជាទីមេត្រី !

សរុបមក ដើម្បីរក្សានិរន្តរភាពរបស់ក្រសួងស្ថាប័នមួយឲ្យប្រព្រឹត្តទៅដោយសុវត្ថិភាព និងជោគជ័យ គឺអាស្រ័យលើការគ្រប់គ្រងនិងបែងចែកធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ។ ធនធានមនុស្សត្រូវបានលើកកម្ពស់និងពង្រឹងជាប់ជាប្រចាំ ដោយមន្ត្រីខ្លះត្រូវបានចាត់តាំងឲ្យទៅបំពេញភារកិច្ចស្នូលនិងការងារសំខាន់នៅតាមនាយកដ្ឋាននិងអង្គភាព ។ ដោយយល់ឃើញពីសារៈសំខាន់នៃកម្លាំងបន្តវេនរបស់ធនាគារជាតិនៃកម្ពុជា សម្រាប់ពេលបច្ចុប្បន្ននិងទៅអនាគត ខ្ញុំសូមឲ្យគណៈរៀបចំវគ្គសិក្សា ជាពិសេស នាយកដ្ឋានបុគ្គលិកបន្តរៀបចំវគ្គនេះជារៀងរាល់ឆ្នាំ និងរៀបចំបើកវគ្គបាគង ស្តីពីការត្រួតពិនិត្យធនាគារបន្តទៀត ដើម្បីឲ្យមន្ត្រីវ័យក្មេងរបស់យើង

បានសិក្សាស្វែងយល់ពីតួនាទីធនាគារជាតិនៃកម្ពុជា និងការប្រែប្រួលថ្មីៗនៃនិម្មាបនកម្មហិរញ្ញវត្ថុអន្តរជាតិ និងគោលការណ៍ត្រួតពិនិត្យថ្មីៗរបស់គណៈកម្មាធិការទីក្រុងបាសែលជាដើម ។

មុននឹងបញ្ចប់ ខ្ញុំសូមផ្តាំផ្ញើដល់ក្មួយៗទាំងអស់ថា ដើម្បីជីវិតនិងការងាររបស់ខ្លួនកាន់តែទទួលបានជោគជ័យបន្ថែមទៀត ក្រៅពីចំណេះដឹងដែលមានជាចាំបាច់ ក្មួយៗត្រូវប្រកាន់ខ្ជាប់សីលធម៌និងគុណធម៌ ភាពអំណត់និងភាពស្មោះត្រង់ ហើយប្រកាន់ខ្ជាប់នូវវិន័យការងារ ដែលទាំងនេះជាកត្តាមិនអាចខ្វះបានសម្រាប់កំណត់ជ័យជម្នះ ។ សូម លោក លោកស្រីនិងក្មួយៗទាំងអស់ចងចាំថា Leadership សម្រាប់ស្ថាប័នយើង គឺគ្មានអ្វីក្រៅពីការខិតខំបណ្តុះបណ្តាលកម្លាំងបន្តវេនរបស់យើងដែលមានទាំងចំណេះដឹងនិងចំណេះធ្វើ ឲ្យចេះស្រឡាញ់ស្ថាប័ន បម្រើការងារជាប្រយោជន៍ជូនស្ថាប័ន ចេះការពារស្ថាប័ននៅពេលជួបបញ្ហាប្រឈមនៅគ្រប់កាលៈទេសៈ និងបន្តអភិវឌ្ឍស្ថាប័នឲ្យកាន់តែរីកចម្រើនតទៅទៀត ។ នេះជាអត្ថន័យសំខាន់របស់ពាក្យ Leadership ដែលយើងបាននិងកំពុងធ្វើសព្វថ្ងៃជូនធនាគារជាតិនៃកម្ពុជា ។

ជាទីបញ្ចប់ ខ្ញុំសូមចូលរួមអបអរសាទរចំពោះក្មួយៗសិក្ខាកាមទាំអស់ ដែលបានខិតខំសិក្សាប្រកបដោយជោគជ័យ ។ ខ្ញុំក៏សូមជូនពរដល់ លោកជំទាវ ឯកឧត្តម លោក លោកស្រីមន្ត្រីឧទ្ទេសនាមនិងក្មួយៗទាំងអស់ ដែលមានវត្តមាននៅទីនេះ សូមមានសុខភាពល្អបរិបូរណ៍ និងទទួលបានជ័យជម្នះគ្រប់ភារកិច្ច ។

**ខ្ញុំសូមប្រកាសបិទវគ្គគួលែនលើកទី៤ កម្រិតមូលដ្ឋានស្តីពីភាពជាអ្នកដឹកនាំចាប់ពីពេលនេះតទៅ។**

**សូមអរគុណ** !

# ឯកសារសិក្សាស្រាវជ្រាវ ស្តីពី ការផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្ម

## ១. សេចក្តីផ្តើម

ប្រទេសកម្ពុជា ជាប្រទេសមួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ មានស្ថានភាពដីរាបស្មើនៅកណ្តាល នឹងព័ទ្ធជុំវិញដោយភ្នំនិងខ្ពង់រាប ។ ក្នុងនោះ ផ្ទៃដីប្រមាណ ២៥.០៦៩គម² ជាដីទំនាប ៦៧.៦៦៨គម² ត្រូវបានហ៊ុមព័ទ្ធនៅជុំវិញបឹងទន្លេសាប ដែលជាប្រភពយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់ដីដែលមានជីជាតិសម្រាប់ការប្រកបអាជីវកម្មកសិកម្ម និង ៦៨.០៦១គម² ជាដីខ្ពង់រាបនិងភ្នំ ហើយកំណើនសេដ្ឋកិច្ចមានការរីកចម្រើនគួរឲ្យកត់សម្គាល់ជាមួយអត្រាជាមធ្យមប្រមាណ ៧% ។

**រូបភាព ១៖ ស្ថានភាពទីតាំងប្រទេសកម្ពុជា និង កំណើនផលិតផលជាតិសរុប**







យោងតាមទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការឆ្នាំ២០១៥ សេដ្ឋកិច្ចរបស់កម្ពុជាត្រូវបានរួមចំណែក ដោយវិស័យសំខាន់ចំនួន ៣ រួមមាន ៖ វិស័យកសិកម្ម (២៦,៦%) វិស័យឧស្សាហកម្ម (២៧,៧%) និង វិស័យសេវាកម្ម (៣៩,៨%) ហើយតាមរយៈលទ្ធផលស្ថិតិរបស់អង្គការម្ហូបអាហារនិងកសិកម្មបង្ហាញថា ក្នុងឆ្នាំ២០១៣ វិស័យកសិកម្មបានផ្តល់ការងារដល់ប្រជាជនចំនួន ៦៤,៦% នៃកម្លាំងពលកម្មសរុប ។ ចំពោះវិស័យស្រូវអង្ករ លេខាធិការដ្ឋានច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ (Secretariat of One Window Service for Rice export Formality – SOWS-REF) បានបង្ហាញថាវិស័យស្រូវអង្ករកម្ពុជាមានការរីកចម្រើនយ៉ាងខ្លាំងបើប្រៀបធៀបទៅនឹងមុនឆ្នាំ២០១០ ដែលអាចឆ្លុះបញ្ចាំងតាមរយៈកំណើនបរិមាណនៃការនាំចេញអង្ករពីមួយឆ្នាំទៅមួយឆ្នាំ រួមមាន ៖ ឆ្នាំ២០០៩ (១២.៦១៣ តោន) ឆ្នាំ២០១០ (១០៥.២៦០ តោន) ឆ្នាំ២០១១ (២០១.៨៩៩ តោន) ឆ្នាំ២០១២ (២០២.៧១៧ តោន) ឆ្នាំ២០១៣ (៣៧៩.៨៥៦ តោន) ឆ្នាំ២០១៤ (៣៨៧.០៦១ តោន) និង ឆ្នាំ២០១៥ (៥៣៨.៣៩៦ តោន) ។

ទន្ទឹមនឹងការរីកចម្រើននេះវិស័យកសិកម្មគឺជាវិស័យមួយក្នុងចំណោមវិស័យអាទិភាពទាំង៤ ដែលត្រូវបានយកចិត្តទុកដាក់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៥ (២០១៣) ។ ក្នុងនោះ សកម្មភាពក្នុងការពង្រឹងការបន្តអភិវឌ្ឍនិងបង្កើនតម្លៃបន្ថែមនៃវិស័យកសិកម្ម រួមមាន ៖ (១) ការបង្កើនតម្លៃបន្ថែមនៃការផលិតនិងការនាំចេញអង្ករ ពិសេសការផ្តោតលើអង្ករក្រអូប អង្ករសរីរាង្គ និងកសិផលមានតម្លៃខ្ពស់ (២) ការជំរុញការចិញ្ចឹមសត្វនិងវារីវប្បកម្ម ដែលទីផ្សារត្រូវការ (៣) ការជំរុញលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យកសិ-ឧស្សាហកម្ម និង (៤) ការបង្កើនផលិតភាព ទំនើបកម្មកសិកម្ម និងការលើកកម្ពស់ពាណិជ្ជូបនីយកម្ម ។

**រូបភាព ២៖ ការនាំចេញអង្ករ និង ប្រភេទអង្ករនាំចេញ**




ប្រភព៖ លេខាធិការដ្ឋានច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ (SOWS-REF)

ជាមួយគ្នាដែរ ក្នុងឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ ដោយបានកំណត់យកឆ្នាំ២០១៥ ជាឆ្នាំគោល ក្នុងការសម្រេចឲ្យបាននូវការផលិតស្រូវឲ្យបានច្រើនជាង ៤ លានតោន និងជាអង្ករសម្រាប់នាំចេញជាផ្លូវការឲ្យបានយ៉ាងតិច ១ លានតោន និងការទទួលស្គាល់របស់អន្តរជាតិចំពោះអង្ករកម្ពុជា ។ ទន្ទឹមនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (២០១៣) បានបង្ហាញថា ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ផ្ទៃដីដាំដុះដំណាំស្រូវបានកើនឡើងយ៉ាងឆាប់រហ័សពី ២,៦ លានហិកតា និងមានបរិមាណផលស្រូវប្រមាណ ៧,១៧ លានតោន នៅឆ្នាំ២០០៨ ដល់ជាង ៣ លានហិកតា និងមានបរិមាណផលស្រូវប្រមាណ ៩,២៩ លានតោន នៅឆ្នាំ២០១២ ក្នុងនោះស្បៀងអាហារដែលនៅសល់ពីការហូបចុកនិងអាចនាំចេញបានមានចំនួន ៤,៧៣ លានតោន គិតជាស្រូវ និង ៣ លានតោនគិតជាអង្ករ ។ នេះជាកាលានុវត្តភាពថ្មីមួយ ដែលផ្តល់នូវសក្តានុពលដល់កម្ពុជាក្នុងការវិវត្តខ្លួនទៅជាប្រទេសនាំចេញអង្ករនាំមុខគេក្នុងពេលអនាគតដ៏ខ្លី ។ ប៉ុន្តែសមត្ថភាពក្នុងការនាំចេញនៅមានកម្រិតទាបនៅឡើយ និងទាមទារការយកចិត្តទុកដាក់បន្ថែមពីរាជរដ្ឋាភិបាល ក៏ដូចជាគ្រប់ភាគីពាក់ព័ន្ធ ។

ក្នុងឆ្នាំ២០១៥ គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានផ្តល់ឥណទានចំនួន ១.២២៩ លានដុល្លារអាមេរិក និង ១.០៦៥ លានដុល្លារអាមេរិក រៀងគ្នា ដល់វិស័យកសិកម្ម ដែលបរិមាណនេះស្មើនឹង ១០,២% និង ៣៥,២% នៃសំពៀតឥណទានសរុបរបស់គ្រឹះស្ថាន ។ ឥណទានដល់វិស័យកសិកម្មមានការកើនឡើងជាងឆ្នាំ២០១៤ ដែលឥណទានប្រមាណ ៩៥៣ លានដុល្លារអាមេរិក និង ៧៤៦ លានដុល្លារអាមេរិក ត្រូវបានផ្តល់ដោយគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ បើទោះជាការផ្តល់ឥណទានដល់វិស័យកសិកម្មមានការកើនឡើងក៏ដោយ មានមតិជាច្រើនបានលើកឡើងពីការខ្វះខាតនូវធនធានហិរញ្ញវត្ថុ ក្នុងការអភិវឌ្ឍវិស័យកសិកម្ម ក៏ដូចជាការសម្រេចបាននូវគោលនយោបាយនាំចេញអង្កររបស់រាជរដ្ឋាភិបាល ។ ផ្អែកលើការលើកឡើងខាងលើនេះ ធនាគារជាតិនៃកម្ពុជារៀបចំការសិក្សាស្រាវជ្រាវនេះឡើង ក្នុងគោលបំណងស្វែងយល់ពីស្ថានភាពវិស័យកសិកម្ម និងតម្រូវការធនធានហិរញ្ញវត្ថុ លើការអភិវឌ្ឍវិស័យកសិកម្មនៅក្នុងប្រទេសកម្ពុជា ។ លទ្ធផលដែលទទួលបានពីការសិក្សាស្រាវជ្រាវនេះនឹងត្រូវបានប្រើប្រាស់ដើម្បីជាជំនួយដល់ធនាគារជាតិនៃកម្ពុជា ក្នុងការរៀបចំគោលនយោបាយសកម្មភាព ឲ្យកាន់តែមានប្រសិទ្ធភាព ។ ការសិក្សាស្រាវជ្រាវនេះ បានយកចិត្តទុកដាក់លើខេត្តចំនួន ៨ ដែលមានផលិតកម្មស្រូវ-អង្ករច្រើន ដែលរួមមាន ខេត្តបាត់ដំបង ព្រៃវែង កំពង់ចាម កណ្តាល កំពង់ធំ តាកែវ បន្ទាយមានជ័យ និង សៀមរាប

ដោយបានសាកសួរដល់ប្រជាកសិករចំនួន ៩៩ គ្រួសារ និង រោងម៉ាស៊ីនកិនស្រូវចំនួន ៥៣ រោងម៉ាស៊ីន ព្រមទាំងចុះសាកសួរដល់ទីស្នាក់ការកណ្តាលរបស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុចំនួន ៣០ គ្រឹះស្ថាន ។

អត្ថបទនៃការសិក្សាស្រាវជ្រាវនេះ បែងចែកជា ៤ផ្នែក រួមមានៈ (១) សេចក្តីផ្តើម ដែលបង្ហាញពីគោលបំណង ទំហំ និងវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ (២) ស្ថានភាពវិស័យស្រូវអង្ករនិងវិស័យហិរញ្ញវត្ថុ ដែលឆ្លុះបញ្ចាំងពីការវិវឌ្ឍនៃវិស័យកសិកម្មក្នុងប្រទេសកម្ពុជា និងការចូលរួមរបស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុនៅក្នុងវិស័យនេះ (៣) ការអនុវត្តនិងការប្រឈមរបស់ប្រជាកសិករ រោងម៉ាស៊ីនកិនស្រូវ និង គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុដល់អាជីវកម្មស្រូវ-អង្ករ និង (៤) ការសន្និដ្ឋាននិងផ្តល់យោបល់ ។

## ២. ស្ថានភាពវិស័យស្រូវអង្ករនិងវិស័យហិរញ្ញវត្ថុ

ប្រជាកសិករកម្ពុជាភាគច្រើន យកចិត្តទុកដាក់លើដំណាំស្រូវ ហើយផ្ទៃដីប្រមាណ ៧៥% ត្រូវបានប្រើប្រាស់សម្រាប់ការដាំស្រូវ ។ ផលិតកម្ម ដំណើរការនិងទីផ្សារស្រូវ បានផ្តល់ការងារដល់ប្រជាជនប្រមាណ ៣ លាននាក់ ឬ ២០% នៃប្រជាជនដែលមានវ័យគ្រប់គ្រាន់សម្រាប់បំពេញការងារ ។ ជាមួយគ្នាដែរ មួយផ្នែកធំនៃស្រូវដែលបានផលិតនៅក្នុងប្រទេសកម្ពុជា ត្រូវបាននាំចេញទៅកាន់ប្រទេសថៃនិងវៀតណាមដើម្បីកិន រួចត្រូវបានចែកចាយសម្រាប់បំពេញតម្រូវការនៅក្នុងស្រុក ឬនាំចេញទៅបណ្តាប្រទេសផ្សេងទៀត ។ ការណ៍នេះ បង្កឲ្យបាត់បង់ឱកាសយ៉ាងច្រើនសម្រាប់រោងម៉ាស៊ីនកិនស្រូវនិងពាណិជ្ជករនៅកម្ពុជា ក្នុងការនាំចេញដោយផ្ទាល់ និងការបង្កើតការងារដល់ប្រជាជនក្នុងស្រុក ។ ទន្ទឹមនេះ ការយល់ដឹងរបស់កម្ពុជាអំពីបទដ្ឋាននិងតម្រូវការទីផ្សារអង្ករអន្តរជាតិនៅមានកម្រិត ដោយសារការទទួលព័ត៌មានមិនគ្រប់គ្រាន់ (សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ឆ្នាំ២០១៥) ។

បើទោះជាយ៉ាងនេះក៏ដោយ ការបង្កើតបទដ្ឋានក្នុងការធានាលើគុណភាពសម្រាប់ "អង្ករស" និង "អង្ករក្រអូប" ចាប់តាំងពីឆ្នាំ២០១៣ កាន់តែជំរុញឱ្យមានការទទួលស្គាល់និងជំនឿទុកចិត្តជាអន្តរជាតិពីអ្នកទិញទូទាំងពិភពលោកលើគុណភាពអង្កររបស់កម្ពុជា ។ ការពង្រឹងបច្ចេកទេសកសិកម្មនិងដំណើរការកិន បានជំរុញទិន្នផលនិងប្រាក់ចំណូលដល់ឧស្សាហកម្មអង្ករកម្ពុជា ក៏ដូចជាកេរ្តិ៍ឈ្មោះក្នុងការផលិតអង្ករក្រអូប ។ ជាលទ្ធផលគួរជាទីមោទនៈ អង្ករកម្ពុជាបានទទួលចំណាត់ថ្នាក់ជាអង្ករឆ្ងាញ់បំផុតលើពិភពលោករយៈពេលបីឆ្នាំជាប់គ្នា នៅក្នុងសន្និសីទអង្ករពិភពលោកប្រចាំឆ្នាំដែលរៀបចំដោយ ក្រុមហ៊ុន The Rice Trader (TRT) ។ បើទៅជាយ៉ាងនេះក៏ដោយ អង្គការម្ហូបអាហារនិងកសិកម្ម (២០១៤) បានបង្ហាញថា លទ្ធភាពបង្កបង្កើនផលរបស់កម្ពុជានៅមានកម្រិតទាបធៀបនឹងប្រទេសជិតខាងដែលជាមធ្យមការដាំដំណាំស្រូវទទួលផលបានត្រឹម ៣,៣ តោនក្នុងមួយហិកតា ប៉ុណ្ណោះ ខណៈដែលប្រទេសវៀតណាម **ឥណ្ឌូណេស៊ី** អាចផលិតបានដល់ ៦,២ តោន និង ៥,៧ តោន ក្នុង មួយហិកតា រៀងគ្នា ។

គោលនយោបាយស្តីពី "ការជំរុញផលិតកម្មស្រូវអង្ករ និងការនាំចេញអង្ករ" ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១១ បានរៀបចំនូវផែនការសកម្មភាពសំដៅឆ្លើយតបនិងសម្រេចបាននូវទិសដៅដែលបានកំនត់តាមរយៈការយកចិត្តដាក់លើការបង្កើនផលិតភាព ជាពិសេស ប្រពលវប្បកម្មដំណាំស្រូវ និង ពិពិធភាវូបនីយកម្មកសិកម្ម និងការផ្តោតជាសំខាន់លើការបង្កើនសេវាកម្មនិងកិច្ចអន្តរាគមន៍នានា ដើម្បីជំរុញការបង្កើនផលិតផលស្រូវ ការផ្ទេរបច្ចេកទេសសមស្របដល់កសិករ ការបង្កើនការស្រាវជ្រាវនិងការអភិវឌ្ឍពូជស្រូវដែលស្របនឹងលក្ខណៈដីកត្តាអាកាសធាតុ ពិសេសគឺការកំណត់ប្រភេទពូជស្រូវសំខាន់ៗ ស្របតាមតម្រូវការទីផ្សារ ជាដើម ។ ទន្ទឹមនេះ

ការសម្របសម្រួលនិងគាំទ្រវិស័យឯកជន ក្នុងការបង្កើនសមត្ថភាពម៉ាស៊ីនកែច្នៃ ស្របតាមតម្រូវការស្តង់ដារទីផ្សារអន្តរជាតិ និងការប្រមូលផ្តុំផលិតកម្ម ក៏ជាយន្តការចាំបាច់ផងដែរ ដែលទាមទារឲ្យមានការគាំទ្រនិងយកចិត្តទុកដាក់យ៉ាងខ្លាំង ។

**រូបភាព ៣៖ លទ្ធភាពនៃការបង្កបង្កើនផលស្រូវក្នុងមួយហិកតា (គិតជាតោន)**




ប្រភព៖ អង្គការម្ហូបអាហារនិងកសិកម្ម (FAOSTAT)

វិស័យហិរញ្ញវត្ថុនៅកម្ពុជាគ្របដណ្តប់ដោយវិស័យធនាគារ ដែលក្នុងនោះទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុសរុបក្នុងឆ្នាំ២០១៥ បានកើនឡើងដល់ ២៣,៥ ពាន់លានដុល្លារអាមេរិក ។ ទន្ទឹមនេះ ឥណទានរបស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុសរុបបានកើនឡើងជាលំដាប់ដល់ ១៤,៧ ពាន់លានដុល្លារអាមេរិក ហើយឥណទាននេះត្រូវបានបែងចែកដល់វិស័យជាច្រើននៅក្នុងសេដ្ឋកិច្ច ។ យោងតាមទិន្នន័យរបស់ធនាគារជាតិនៃកម្ពុជាឆ្នាំ២០១៥ ឥណទានរបស់គ្រឹះស្ថានធនាគារភាគច្រើនបានបែងចែកដល់វិស័យពាណិជ្ជកម្មលក់ដុំ (១៧,០១%) ពាណិជ្ជកម្មលក់រាយ (១៥,៧៣%) កសិកម្មរុក្ខាប្រមាញ់និងនេសាទ (១០,១៩%) សេវាផ្សេងៗមិនមែនហិរញ្ញវត្ថុ (៨,៣៧%) កម្មន្តសាលកម្ម (៧,៦១%) និងការខ្ចីទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន (៧,១%) នៃសំពៀតឥណទានសរុប ខណៈដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុយកចិត្តទុកដាក់ផ្តល់ឥណទានដល់វិស័យកសិកម្ម (៣៥,២៤%) ក្រុមគ្រួសារ (២៦,២២%) ការជួញដូរនិងពាណិជ្ជកម្ម (១៩,៣៥%) សេវាកម្ម (១០,៦៦%) និងសំណង់និងដឹកជញ្ជូន (៧,១៧%) នៃសំពៀតឥណទានសរុប ។ នេះបង្ហាញថា ឥណទានសរុបប្រមាណ ២,៣ ពាន់លានដុល្លារអាមេរិក ត្រូវបានផ្តល់ដល់វិស័យកសិកម្ម ដោយគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ។

**រូបភាព ៤៖ ឥណទានរបស់គ្រឹះស្ថានធនាគារ និង មីក្រូហិរញ្ញវត្ថុតាមវិស័យសេដ្ឋកិច្ច**







ប្រភព៖ ធនាគារជាតិនៃកម្ពុជា (ឆ្នាំ២០១៥)

យោងតាមការសិក្សារបស់ធនាគារពិភពលោក ឆ្នាំ២០១៣ ប្រមាណជាពាក់កណ្តាលនៃកសិអាជីវកម្មកម្ពុជា បានប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់ធនាគារពាណិជ្ជ ហើយកម្រិតនៃការប្រើប្រាស់សេវាធនាគារប្រែប្រួលទៅតាមទំហំនៃសហគ្រាស ។ ក្នុងនោះ ប្រមាណ ៨៥% នៃសហគ្រាសដែលប្រើប្រាស់សេវាធនាគារពាណិជ្ជ គឺជាសហគ្រាសខ្នាតធំ ហើយមានតែ ២២% ប៉ុណ្ណោះជាសហគ្រាសខ្នាតតូចបំផុត ។ ការសិក្សាក៏បង្ហាញផងដែរថា ភាគច្រើននៃអ្នកលក់អង្ករនិងអ្នកផ្គត់ផ្គង់វត្ថុធាតុដើម គឺជាសហគ្រាសខ្នាតតូចបំផុតនិងខ្នាតតូច ដែលក្នុងនោះមានអ្នកលក់អង្ករប្រមាណ ៨៦% និង អ្នកផ្គត់ផ្គង់វត្ថុធាតុដើមប្រមាណ ៨៥% ហើយជាសហគ្រាសខ្នាតធំ គឺមានតែអ្នកលក់អង្ករប្រមាណ ៣% និង អ្នកផ្គត់ផ្គង់វត្ថុធាតុដើមប្រមាណ ៥% ប៉ុណ្ណោះ ។

## ៣. ស្ថានភាពអនុវត្តនិងការប្រឈមរបស់ប្រជាកសិករ និងរោងម៉ាស៊ីនកិនស្រូវ និងគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុដល់អាជីវកម្មស្រូវ-អង្ករ

### ៣.១. ការអនុវត្តនិងការប្រឈមរបស់ប្រជាកសិករ

ការដាំដំណាំស្រូវត្រូវបានអនុវត្តជាយូរមកហើយនៅក្នុងប្រទេសកម្ពុជា ដូចមានភស្តុតាងពន្យល់ទុកពីសម័យមុនអង្គរ ។ ហើយសព្វថ្ងៃនេះ ប្រជាជនកម្ពុជាភាគច្រើនប្រកបរបរកសិកម្មដើម្បីចិញ្ចឹមជីវិតដូចជា ការនេសាទ ការដាំដំណាំ ការដាំស្រូវ និង ការចញ្ចឹមសត្វជាដើម ។ យោងតាមទិន្នន័យដែលប្រមូលបានពីការសិក្សាស្រាវជ្រាវ កសិករដាំដំណាំស្រូវភាគច្រើនបានប្រកបមុខរបរនេះជាយូរមកហើយ ដែលភាគច្រើនមានបទពិសោធន៍ប្រមាណ ២០ឆ្នាំ និងមានមួយចំនួនតូចប៉ុណ្ណោះដែលតិចជាង ៥ឆ្នាំ និងភាគច្រើនរស់នៅក្នុងគ្រួសារជាមួយគ្នាដែលមានសមាជិកប្រមាណពី ៣ នាក់ ទៅ ១០ នាក់ ។ ការរស់នៅជាលក្ខណៈគ្រួសារដែលមានសមាជិកច្រើនបែបនេះនាំឲ្យពួកគាត់មានភាពងាយស្រួលក្នុងការជួយគ្នាបង្កបង្កើនផល ហើយជាមួយគ្នានេះ ការស្វែងរកលំនៅស្ថានថ្មីក៏មានការលំបាកផងដែរ ។ ក្នុងការដាំដំណាំស្រូវ កសិករប្រើប្រាស់ដីរបស់ខ្លួនដែលបន្សល់ទុកពីកេរ្តិ៍ដូនតា ដែលជាទូទៅមានដីប្រមាណពី ១ ហិកតា ទៅ ៥ ហិកតា ដោយអាចប្រមូលផលជាមធ្យមប្រមាណ ១ តោន ទៅ ៥ តោន ក្នុងមួយហិកតា ប៉ុន្តែ ដោយសារភាពអំណោយផលនៃតំបន់រស់នៅ ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ និងការយល់ដឹងអំពីវិធីសាស្ត្រក្នុងការជ្រើសរើសប្រភេទពូជស្រូវនិងការដាំដុះ មានកសិករប្រមាណ ៣៦% អាចមានលទ្ធភាពប្រមូលផលបានច្រើនជាង ៥តោន ។ ចំពោះទិន្នផលស្រូវដែលទទួលបានពីការដាំដុះ កសិកររក្សាទុកស្រូវមួយចំនួនតូចសម្រាប់ផ្គត់ផ្គង់តម្រូវការគ្រួសារ ហើយស្រូវប្រមាណ ៧៨% ត្រូវបានលក់ទៅឲ្យអ្នកប្រមូលទិញស្រូវ ។

**រូបភាព ៥៖ បទពិសោធន៍នៃការដាំដំណាំស្រូវ និង ទំហំដីរបស់ក្រុមគ្រួសារសម្រាប់ការដាំដំណាំស្រូវ**




ប្រភព៖ ទិន្នន័យស្រាវជ្រាវ

បើទោះជាយ៉ាងនេះក៏ដោយ កសិករភាគច្រើនបានបង្ហាញថា ទិន្នផលស្រូវដែលទទួលបានគឺមិនបានសម្រេចតាមការរំពឹងទុកទេ ដោយសារកត្តាមួយចំនួន ដូចជា (១) បញ្ហាអាកាសធាតុ (៦៤%) ដែលពេលខ្លះមានទឹកជំនន់ និងពេលខ្លះទៀតមានភាពរាំងស្ងួត (២) កម្លាំងពលកម្មមិនគ្រប់គ្រាន់ (១៦%) ដោយសារការធ្វើចំណាកស្រុករបស់សមាជិកក្នុងគ្រួសារទៅប្រទេសជិតខាងដែលអាចស្វែងរកប្រាក់ចំណូលដល់គ្រួសារ ច្រើនជាងការដាំដំណាំស្រូវ (៣) ការយល់ដឹងអំពីការដាំដំណាំស្រូវនៅមានកម្រិត (៨%) ដែលអនុវត្តទៅតាមបទពិសោធន៍និងចំណេះដឹងដែលទទួលបានពីឪពុក-ម្តាយ និងសមាជិកក្នុងក្រុមគ្រួសារ (៤) ការខ្វះខាតដើមទុនទិញវត្ថុធាតុដើមសម្រាប់ផ្គត់ផ្គង់ដំណើរការដាំដុះ(៦%) និង (៥) ការខ្វះខាតហេដ្ឋារចនាសម្ព័ន្ធ (៥%) ដែលមានការលំបាកក្នុងការធ្វើដំណើរទៅមក និងមិនមានទឹកគ្រប់គ្រាន់សម្រាប់ស្រោចដំណាំ ។ នេះបង្ហាញថា កត្តាប្រឈមចម្បងជាងគេដែលជាឧបសគ្គក្នុងការដាំដំណាំស្រូវរបស់ប្រជាពលរដ្ឋគឺការប្រែប្រួលអាកាសធាតុ ។

**រូបភាព ៦៖ កត្តាប្រឈមដែលជាឧបសគ្គក្នុងការដាំដំណាំស្រូវរបស់ប្រជាពលរដ្ឋ**




ប្រភព៖ ទិន្នន័យស្រាវជ្រាវ

ចំពោះដើមទុន ប្រមាណ ៥៣% នៃកសិករ ប្រើប្រាស់ប្រភពទុនផ្ទាល់ខ្លួន ខណៈដែល ២៥% ប្រើប្រាស់ប្រាក់កម្ចីដែលទទួលបាន និង ២៣% ទៀតប្រើប្រាស់ទាំងទុនផ្ទាល់ខ្លួននិងប្រាក់កម្ចី ។ ក្នុងចំណោមកសិករដែលមិនបានខ្ចីប្រាក់ពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានកសិករប្រមាណ ១៨% បានបង្ហាញនូវនិន្នាការខ្ចីប្រាក់ពីគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ កត្តាដែលជំរុញឲ្យកសិករ ភាគច្រើនជ្រើសរើសយកគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ គឺដោយសារអត្រាការប្រាក់អាចទទួលយកបាន និងទីស្នាក់ការរបស់គ្រឹះស្ថានមានភាពងាយស្រួលក្នុងការទំនាក់ទំនង ខណៈដែលកសិករផ្សេងទៀតបានបង្ហាញថា ការណ៍ដែលមិនមានបំណងខ្ចីប្រាក់ពីគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ គឺដោយសារការមិនមានលទ្ធភាពសងបំណុល និងមិនមានការយល់ដឹងអំពីផលិតផលហិរញ្ញវត្ថុ ។ ក្រៅពីគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ កសិករក៏បានខ្ចីប្រាក់ពីសាច់ញាតិ អ្នកឲ្យខ្ចីចងការ និង ការខ្ចីជីបណ្តាក់ ផងដែរ ។ កត្តាដែលជំរុញឲ្យពួកគាត់ជ្រើសរើសយកប្រភពទុនខាងលើ គឺដោយសារទីតាំងជិត និងមានភាពងាយស្រួលក្នុងការខ្ចីប្រាក់ ។

ក្នុងការទទួលបានកម្ចីពីប្រភពទុនខាងលើ កសិករភាគច្រើនត្រូវបង់កម្រៃអត្រាការប្រាក់ច្រើនជាង២២% ក្នុងមួយឆ្នាំ និងមានមួយចំនួនបង់ពី ១៨% ដល់ ២២% ក្នុងមួយឆ្នាំ ក្នុងនោះកម្ចីភាគច្រើនមានចំនួនពី ៤ លានរៀល

(១.០០០ ដុល្លារអាមេរិក) ដល់ ២០ លានរៀល (៥.០០០ដុល្លារអាមេរិក) និង តិចជាង ២លានរៀល (៥០០ ដុល្លារអាមេរិក) ដែលច្រើនជាងពាក់កណ្ដាលនៃកសិករបង្ហាញថា បរិមាណនេះគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការរបស់ពួកគាត់ ។ ក្រៅពីនេះ បើទោះជាពួកគាត់តែងតែទទួលបានការយល់ព្រមផ្ដល់កម្ចីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសម្រាប់ខ្ចីប្រាក់ដើម្បីពង្រីកមុខរបរអាជីវកម្ម ពួកគាត់នៅតែប្រឈមនឹងបញ្ហាលំបាកមួយក្នុងការដាក់ពាក្យខ្ចីប្រាក់ ដូចជា វត្ថុបញ្ចាំ អត្រាការប្រាក់ និង អ្នកធានា ។ ជាទូទៅ តម្រូវការខ្ចីប្រាក់គឺនៅក្នុងអំឡុងពេលមុនភ្ជួររាស់ ដែលកសិករត្រូវការទុនសម្រាប់ទិញវត្ថុធាតុដើម ដើម្បីភ្ជួររាស់ និងប្រមូលផលកសិកម្ម ។

## ៣.២. ការអនុវត្តរបស់រោងម៉ាស៊ីនកិនស្រូវ

រោងម៉ាស៊ីនកិនស្រូវមានតួនាទីយ៉ាងសំខាន់ក្នុងដំណើរការនៃការកែច្នៃ និងការនាំចេញអង្ករបស់កម្ពុជាតាមរយៈមុខងារជាអន្តរការីរវាងកសិករនិងអ្នកនាំចេញ ដូចជា ការប្រមូលស្រូវពីប្រជាកសិករ ជាដើម ។ ក្នុងនោះ ភាគច្រើននៃរោងម៉ាស៊ីនកិនស្រូវ មានប្រតិបត្តិការច្រើនជាង១០ឆ្នាំ ហើយមានតែរោងម៉ាស៊ីនកិនស្រូវមួយចំនួនប៉ុណ្ណោះ ដែលទើបតែចាប់ផ្ដើមដំណើរការ ។ ចំពោះសមត្ថភាពនៃការផលិត រោងម៉ាស៊ីនកិនស្រូវប្រមាណ ៦២% អាចមានលទ្ធភាពកិនស្រូវក្នុងចន្លោះ ១.០០០ តោន ទៅ ១០.០០០ តោន និងប្រមាណ ៩% អាចកិនស្រូវបានច្រើនជាង ២០.០០០ តោន ក្នុងមួយឆ្នាំ ។ ទន្ទឹមនឹងលទ្ធផលដែលទទួលបាននេះ រោងម៉ាស៊ីនកិនស្រូវប្រមាណ ១៣% បានបង្ហាញនូវការពេញចិត្តរបស់ខ្លួន ដោយលទ្ធផលនេះអាចសម្រេចបានតាមសមត្ថភាពម៉ាស៊ីនរបស់ខ្លួន ប៉ុន្តែ ៧៧% នៃរោងម៉ាស៊ីនកិនស្រូវបានបង្ហាញថា លទ្ធផលដែលទទួលបាន គឺមិនអាចបំពេញតាមសមត្ថភាពដែលរំពឹងទុកឡើយ ដោយសារការខ្វះខាតធនធានហិរញ្ញវត្ថុ (៣៥%) មិនមានស្រូវគ្រប់គ្រាន់សម្រាប់កិន (១១%) ខ្វះខាតសម្ភារៈនិងជំនាញ (៨%) មិនមានជីនិងថ្នាំសំលាប់សត្វល្អិតគ្រប់គ្រាន់ (៧%) និង កត្តាផ្សេងៗ (៣៩%) ដូចជា កម្លាំងពលកម្មមិនគ្រប់គ្រាន់ មិនមានទីផ្សារលក់ អគ្គិសនីមានតម្លៃថ្លៃ និង ការប្រមូលទិញស្រូវរបស់ប្រទេសជិតខាង ជាដើម ។

**រូបភាព ៧៖ រយៈពេលប្រតិបត្តិការរោងម៉ាស៊ីនកិនស្រូវ និងទំហំនៃការផលិត**




ប្រភព៖ ទិន្នន័យស្រាវជ្រាវ

**រូបភាព ៨៖ កត្តាប្រឈមដែលជាឧបសគ្គសម្រាប់រោងម៉ាស៊ីនកិនស្រូវ**




ប្រភព៖ ទិន្នន័យស្រាវជ្រាវ

ក្នុងការប្រមូលទិញស្រូវ រោងម៉ាស៊ីនកិនស្រូវមិនអាចរំពឹងតែប្រភពស្រូវដែលមាននៅក្នុងខេត្តនោះទេ ត្រូវពឹងផងដែរពីខេត្តផ្សេងទៀត ដែលអាចជាកសិករ និង អ្នកប្រមូលស្រូវ ។ ក្នុងចំណោម រោងម៉ាស៊ីនកិនស្រូវដែលប្រឈមនឹងកង្វះខាតដើមទុន បានបង្ហាញថាក្រៅពីប្រាក់សន្សំផ្ទាល់ខ្លួននិងការខ្ចីពីសាច់ញាតិ ពួកគាត់ក៏មានបំណងខ្ចីប្រាក់បន្ថែមពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផងដែរ ជាពិសេស គ្រឹះស្ថានធនាគារ ដោយសារដំណើការនៃការខ្ចីប្រាក់មានភាពងាយស្រួល និងអត្រាការប្រាក់មានកម្រិតជាមធ្យមប្រមាណ ៨% ទៅ ១០% ក្នុងមួយឆ្នាំទាបជាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ បើទោះជាយ៉ាងនេះក៏ដោយ មានរោងម៉ាស៊ីនកិនស្រូវមួយចំនួនមិនបានបង្ហាញពីនិន្នាការខ្ចីប្រាក់ពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទេ ដោយយោងលើកត្តាមិនមានលទ្ធភាពសង ។

ចំពោះរោងម៉ាស៊ីនកិនស្រូវដែលបានទទួលឥណទានពីគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ច្រើនជាងពាក់កណ្ដាលនៃពួកគេ បានទទួលឥណទានពី ១០០.០០០ ដុល្លារអាមេរិក ទៅ ១.០០០.០០០ ដុល្លារអាមេរិក ហើយប្រមាណ ២២,៥% បានទទួលឥណទានលើសពី ១.០០០.០០០ ដុល្លារអាមេរិក ហើយភាគច្រើននៃសំណើកម្ចីឥណទានរបស់រោងម៉ាស៊ីនកិនស្រូវ តែងតែទទួលបានការអនុម័តយល់ព្រមពីគ្រឹះស្ថាន ។ បើទោះជារោងម៉ាស៊ីនកិនស្រូវទទួលបានកម្ចីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក៏ដោយ រោងម៉ាស៊ីនកិនស្រូវប្រមាណ ៨៣% នៅតែបង្ហាញថាឥណទានដែលទទួលបាន គឺមិនគ្រប់គ្រាន់សម្រាប់ការទិញស្រូវនិងការពង្រីកអាជីវកម្មបន្ថែមទេ ។ ក្រៅពីនេះ កត្តាប្រឈមចម្បងសម្រាប់រោងម៉ាស៊ីនកិនស្រូវក្នុងការខ្ចីប្រាក់ពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គឺវត្ថុបញ្ចាំ និងអត្រាការប្រាក់ ។

គួរកត់សម្គាល់ថា ក្នុងពេលថ្មីៗនេះមានរោងម៉ាស៊ីនកិនស្រូវមួយចំនួនត្រូវបានបិទទ្វារ ដែលការណ៍នេះអាចនឹងមានការរួមចំណែកដោយការប្រើប្រាស់ធនធានហិរញ្ញវត្ថុមិនសមស្រប ដូចជាការវិនិយោគលើការពង្រីកអាជីវកម្ម ធំជាងតម្រូវការដែលបង្កឲ្យមានការចំណាយខ្ពស់ តែផលចំណេញដែលទទួលបានមកវិញតិចជាងការចំណាយ ។ ប៉ុន្តែ រោងម៉ាស៊ីនកិនស្រូវមួយចំនួនបានបង្ហាញថា បើទោះជារោងម៉ាស៊ីនមានសាច់ប្រាក់គ្រប់គ្រាន់ក៏ដោយ ការថយចុះនៃការដាំដំណាំស្រូវរបស់ប្រជាកសិករ ជាកត្តាមួយបង្កឲ្យរោងម៉ាស៊ីនពិបាករកស្រូវមកកិន និងត្រូវចំណាយថ្លៃដើមខ្ពស់ក្នុងការផលិត ការថែរក្សា និងការដឹកជញ្ជូន ។

រូបភាព ៩៖ កត្តាប្រឈមដែលជាឧបសគ្គក្នុងការទទួលបានឥណទានពីគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ




ប្រភព៖ ទិន្នន័យស្រាវជ្រាវ

## ៣.៣. ការផ្តល់ឥណទានរបស់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ទន្ទឹមនឹងការរីកចម្រើននៃសេដ្ឋកិច្ច ប្រព័ន្ធធនាគារនៅកម្ពុជា បានអភិវឌ្ឍជាបន្តបន្ទាប់ទៅតាមការវិវត្តនៃទីផ្សារ ។ គិតត្រឹមចុងឆ្នាំ២០១៥ ប្រព័ន្ធធនាគារនៅកម្ពុជារួមមាន ៖ ធនាគារពាណិជ្ជ ៣៦ ធនាគារឯកទេស ១១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន ៨ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៥០ ។ គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុដែលមានប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា បានផ្តល់កម្ចីដល់គ្រប់វិស័យ ក្នុងនោះវិស័យកសិកម្មតែងតែទទួលបានឥណទានច្រើន បើធៀបទៅនឹងវិស័យដទៃទៀត ដោយរួមបញ្ចូលទាំងការដាំដំណាំស្រូវ ការចិញ្ចឹមត្រី និង ការដាំបន្លែ ជាដើម ។ យោងតាមរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជា ឆ្នាំ២០១៥ គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុបានផ្តល់ឥណទានសរុបចំនួន ១៤,៧ ពាន់លានដុល្លារអាមេរិក ហើយឥណទានប្រមាណ ១៥,៥% ត្រូវបានផ្តល់ ដល់វិស័យកសិកម្ម (គ្រឹះស្ថានធនាគារចំនួន ១,២ ពាន់លានដុល្លារអាមេរិក និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ១,១ ពាន់លានដុល្លារអាមេរិក) ។ គ្រឹះស្ថានដែលយកចិត្តទុកដាក់ក្នុងការផ្តល់ឥណទានដល់វិស័យកសិកម្ម រួមមាន ៖ ធនាគារអេស៊ីលីដា ធនាគារកាណាឌីយ៉ា ធនាគារអេសហេចប៊ី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ថាបនា ជាដើម ។ ធនាគារអេស៊ីលីដាបាននាំមុខគេក្នុងការផ្តល់ឥណទានដល់វិស័យកសិកម្ម ដែលឥណទានប្រមាណ ៥១៦ លានដុល្លារអាមេរិក ត្រូវបានផ្តល់ដល់វិស័យនេះ ខណៈដែលធនាគារអភិវឌ្ឍន៍ជនបទបានផ្តល់ឥណទានប្រមាណ ៦៤ លានដុល្លារអាមេរិក ។

ក្នុងចំណោមគ្រឹះស្ថានទាំងនេះមានគ្រឹះស្ថានធនាគារប្រមាណ ៤៣% បានផ្តល់ឥណទានដល់វិស័យកសិកម្មអស់រយៈពេលជាង១០ឆ្នាំ មកហើយ ហើយប្រមាណ ៣៦% នៅចន្លោះពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ខណៈដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុភាគច្រើន (៩៣%) បានផ្តល់ឥណទានដល់វិស័យនេះច្រើនជាង ១០ឆ្នាំ ។ ទន្ទឹមនេះ ការផ្តល់ឥណទានរបស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុដល់វិស័យកសិកម្មមានជាមធ្យមប្រមាណ ១០% និង ៣៥% នៃឥណទានសរុបរបស់ខ្លួន ។ ការណ៍នេះបង្ហាញថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការផ្តល់ឥណទានដល់វិស័យកសិកម្ម ។

**រូបភាព ១០៖ រយៈពេលនៃការផ្តល់កម្ចីដល់វិស័យកសិកម្ម**




ប្រភព៖ ទិន្នន័យស្រាវជ្រាវ

គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុបានកំណត់អតិថិជនគោលដៅនៃវិស័យកសិកម្មរបស់ខ្លួនខុសៗគ្នា ។ ក្នុងនោះ ប្រមាណ ៧០% នៃឥណទានរបស់គ្រឹះស្ថានធនាគារ ផ្តល់ដល់រោងម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញអង្ករ ខណៈដែល ៥២% នៃឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ផ្តល់ដល់កសិករ ហើយមានតែឥណទាន ២២% ដែលផ្តល់ដល់រោងម៉ាស៊ីនកិនស្រូវ ។ ការណ៍នេះគឺដោយសាររោងម៉ាស៊ីនកិនស្រូវនិងអ្នកនាំចេញអង្ករ មានតម្រូវការឥណទានទំហំធំ ហើយកសិករភាគច្រើនមានតម្រូវការឥណទានទំហំតូច ។

**រូបភាព ១១៖ ប្រភេទអតិថិជននិងលក្ខខ័ណ្ឌក្នុងការផ្តល់ឥណទានដល់វិស័យកសិកម្ម**




ប្រភព៖ ទិន្នន័យស្រាវជ្រាវ

ទន្ទឹមពេលដែលគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុបានផ្តល់ឥណទានដល់គ្រប់វិស័យ ការផ្តល់ឥណទានដល់វិស័យកសិកម្មមិនត្រូវបានកំណត់ផ្សេងគ្នាទៅនឹងវិស័យដទៃឡើយ គឺត្រូវគោរពតាមលក្ខខណ្ឌឥណទានដែលគ្រឹះស្ថានបានកំណត់ ដូចៗគ្នា ។ ទន្ទឹមនេះផងដែរ អតិថិជនត្រូវបំពេញលក្ខខ័ណ្ឌមួយចំនួនក្នុងការស្នើសុំឥណទានពីគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ដូចជាវត្ថុបញ្ចាំ លទ្ធភាពក្នុងការសងបំណុល ផែនការអាជីវកម្ម និងអ្នកធានាជាដើម ។ ក្នុងចំណោមលក្ខខ័ណ្ឌទាំងនេះគ្រឹះស្ថានធនាគារយកចិត្តទុកដាក់សំខាន់លើវត្ថុបញ្ចាំ និងផែនការអាជីវកម្មដែលការណ៍នេះអាចជាបញ្ហាប្រឈមសម្រាប់ប្រជាពលរដ្ឋនៅទីជនបទ ដែលមិនមានប្លង់ផ្ទះនិងប្លង់ដីត្រឹមត្រូវក៏ដូចជា ក្រុមហ៊ុនតូចៗដែលមិនមានការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនិងផែនការអាជីវកម្មច្បាស់លាស់ ។ ដោយឡែកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពិនិត្យមើលសំខាន់លើលទ្ធភាពក្នុងការសងបំណុលនិងវត្ថុបញ្ចាំ ហើយគ្រឹះស្ថានក៏ពិចារណា

អំពីអ្នកធានាផងដែរ ខណៈដែលផែនការអាជីវកម្មត្រូវបានយកចិត្តទុកដាក់តិចតួច ។ ក្នុងចំណោមឥណទានដែលគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុបានផ្តល់ជូនអតិថិជនដែលមានទ្រព្យបញ្ចាំ រួមមាន ៖ ប្លង់ដីនិងប្លង់អាគារ ៧៩% និងចលនទ្រព្យផ្សេងៗ ៣១% ។ លើសពីនេះ គ្រឹះស្ថានបានបង្ហាញថា បើទោះជាអតិថិជនមិនមានទ្រព្យបញ្ចាំក៏ដោយ ប្រមាណ ២០% និង ៥៤% នៃអ្នកដាក់ពាក្យស្នើសុំ បានទទួលឥណទានពីគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ខណៈដែលអតិថិជនប្រមាណ ៥៣% និង ២៧% ដែលដាក់ពាក្យស្នើសុំដោយមិនមានផែនការអាជីវកម្ម អាចទទួលបានឥណទានពីគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ។

ចំពោះការប្រាក់ប្រចាំឆ្នាំ កម្ចីពីគ្រឹះស្ថានធនាគារមានអត្រាទាបជាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ជាទូទៅការប្រាក់អប្បបរមានៃកម្ចីពីគ្រឹះស្ថានធនាគារមានអត្រាចន្លោះពី ៦% ដល់ ៨% និង អត្រាអតិបរិមាចន្លោះពី ៩% ទៅ ១១% ខណៈដែលការប្រាក់អប្បបរមានៃកម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអត្រាចន្លោះពី ១៨% ដល់ ២០% និង អត្រាអតិបរិមាភាគច្រើនធំជាង ២៣% ផងដែរ ។ ការផ្តល់ឥណទានចំពោះវិស័យកសិកម្ម ត្រូវបានគិតអត្រាប្រហាក់ប្រហែលគ្នានឹងការផ្តល់ឥណទានដល់វិស័យផ្សេងទៀតដែរ ហើយភាគច្រើននៃកម្ចីគឺមានរយៈពេលច្រើនជាង ៣ឆ្នាំ ជាពិសេសឥណទានរបស់គ្រឹះស្ថានធនាគារ ខណៈដែលឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រមាណជិតពាក់កណ្តាល មានរយៈពេលច្រើនជាង ៣ឆ្នាំ ។ ឥណទានរបស់គ្រឹះស្ថានធនាគារមានទំហំធំ ដែលមានចាប់ពី ៥០០.០០០ ដុល្លារអាមេរិក រហូតដល់ច្រើនជាង ១០.០០០.០០០ ដុល្លារអាមេរិក ខណៈដែលឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានទំហំតូចជាង៥០០.០០០ ដុល្លារអាមេរិក ។ ក្នុងនោះ ឥណទានរបស់គ្រឹះស្ថានធនាគារប្រមាណ ៣១% មានទំហំច្រើនជាង ១០.០០០.០០០ ដុល្លារអាមេរិក និង ប្រមាណ ៦២% នៅចន្លោះពី ១.០០០.០០០ ដុល្លារអាមេរិក ទៅ១០.០០០.០០០ ដុល្លារអាមេរិក ចំណែកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវិញ ឥណទានភាគច្រើនគឺមានទំហំពី ៥.០០០ ដុល្លារអាមេរិក ទៅ ១០០.០០០ ដុល្លារអាមេរិក ហើយទន្ទឹមនេះ មានឥណទានប្រមាណ ៦% ដែលមានទំហំច្រើនជាង ១០០.០០០ ដុល្លារអាមេរិក និង ប្រមាណ ២០% ដែលមានទំហំតិចជាង ៥.០០០ ដុល្លារអាមេរិក ។

ក្នុងការសងត្រលប់មកវិញ មានវិធីសាស្រ្តចំនួន ២ ដែលអតិថិជនចូលចិត្តប្រើប្រាស់ គឺ វិធីសាស្រ្តបង់រំលោះ (Installment) និងវិធីសាស្រ្តបង់តែការប្រាក់ប្រចាំខែ រួចបង់ប្រាក់ដើមនៅចុងគ្រា (Balloon) ។ ការណ៍នេះមានភាពខុសគ្នារវាងគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយអតិថិជនរបស់គ្រឹះស្ថានធនាគារភាគច្រើនជ្រើសរើសវិធីសាស្រ្តបង់រំលោះក្នុងការសងបំណុលជាងវិធីសាស្រ្តបង់តែការប្រាក់ប្រចាំខែ រួចបង់ប្រាក់ដើមនៅចុងគ្រា ខណៈដែលអតិថិជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិយមការសងបំណុលតាមវិធីសាស្រ្តបង់តែការប្រាក់ប្រចាំខែ រួចបង់ប្រាក់ដើមនៅចុងគ្រា ជាងវិធីសាស្រ្តរំលស់ ។ ទន្ទឹមនេះ មានអតិថិជនមួយចំនួនបានជ្រើសរើសវិធីសាស្រ្តបង់តាមរដូវកាល (Seasonal Repayment) ផងដែរ ។ ឥណទានមិនដំណើរការចំពោះវិស័យកសិកម្មហាក់មានកម្រិតទាប ដោយអត្រានៃការខាតបង់របស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុប្រមាណ ៧០% គឺតិចជាង ០,៥% ហើយគ្រឹះស្ថានភាគច្រើនបានបង្ហាញថា ប្រសិនបើគ្រឹះស្ថានពិនិត្យឃើញថាវិស័យកសិកម្ម ជាពិសេសវិស័យស្រូវ-អង្ករមានការរីកចម្រើនជាលំដាប់ នោះគ្រឹះស្ថាននឹងយកចិត្តទុកដាក់បន្ថែមក្នុងការពង្រីកឥណទានដល់វិស័យនេះ ។

## ៤. ការសន្និដ្ឋាននិងផ្តល់យោបល់លើការផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្ម

ទន្ទឹមនឹងការរីកចម្រើននៃវិស័យកសិកម្ម ក៏ដូចជាការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលលើវិស័យកសិកម្ម វិស័យនេះមានការរីកចម្រើនជាលំដាប់ ដែលឆ្លុះបញ្ចាំងដោយកំណើននៃការនាំចេញអង្ករ ។ ប៉ុន្តែ បើទោះជាការនាំចេញមានកំណើនជាលំដាប់ក៏ដោយការសិក្សាបានបង្ហាញថា វិស័យស្រូវ-អង្ករប្រឈមនិងបញ្ហាមួយចំនួន ដូចជា ៖ ប្រជាកសិករមិនអាចទទួលបានទិន្នផលពីការដាំដំណាំស្រូវតាមការរំពឹងទុក ដោយសារពឹងផ្អែកច្រើនលើអាកាសធាតុ ហើយកសិករនិងរោងម៉ាស៊ីនកិនស្រូវប្រឈមនឹងការរកទីផ្សារ និងការចំណាយថ្លៃដើមខ្ពស់ក្នុងការផលិតស្រូវ-អង្ករ ។ ទន្ទឹមនេះ បើទោះជារោងម៉ាស៊ីនកិនស្រូវប្រមាណ ៣៥% បានលើកឡើងថាការខ្វះខាតធនធានហិរញ្ញវត្ថុជាបញ្ហាប្រឈមចម្បង ប៉ុន្តែមានប្រជាកសិករមួយចំនួនតូចប៉ុណ្ណោះដែលបានលើកឡើងអំពីបញ្ហានេះ ហើយការលំបាកក្នុងការទទួលបានហិរញ្ញប្បទានពីគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺដោយសារការខ្វះខាតវត្ថុបញ្ចាំនិងអត្រាការប្រាក់ខ្ពស់ ។ គួរបញ្ជាក់ផងដែរថា ការយល់ដឹងអំពីតម្រូវការជាក់ស្តែងនិងការប្រើប្រាស់ធនធានហិរញ្ញវត្ថុគឺមានសារៈសំខាន់ណាស់សម្រាប់ធានាបាននូវភាពជោគជ័យរបស់អាជីវកម្ម ហើយការប្រើប្រាស់ធនធានហិរញ្ញវត្ថុឲ្យចំគោលដៅនិងត្រឹមត្រូវ រឹតតែសំខាន់ថែមទៀតដើម្បីបង្ការការខាតបង់ធ្ងន់ធ្ងរដល់អាជីវកម្ម ។ ចំពោះការផ្តល់ហិរញ្ញប្បទាន គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការផ្តល់ឥណទានដល់វិស័យកសិកម្ម ក្នុងនោះឥណទានប្រមាណ ១៥,៥% នៃបរិមាណឥណទានសរុបរបស់គ្រឹះស្ថាន ត្រូវបានផ្តល់ដល់វិស័យកសិកម្ម ។

យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវ ដើម្បីបង្កើនហិរញ្ញប្បទានវិស័យកសិកម្ម គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាចនឹងពិចារណាលើវិធានមួយចំនួនដូចខាងក្រោម ៖

- ក្នុងការផ្តល់ឥណទានដល់អតិថិជន គ្រឹះស្ថានអាចពិចារណាលើលទ្ធភាពនៃការសង ជាជាងវត្ថុបញ្ចាំ ដូចជា ការប្រើប្រាស់ទិន្នន័យឥណទានរបស់ការិយាល័យឥណទាន ក្នុងការវិភាគនិងវាយតម្លៃគុណភាពអតិថិជន ដែលអាចជំរុញឲ្យអតិថិជនដែលពុំមានទ្រព្យបញ្ចាំអាចមានលទ្ធភាពទទួលបានហិរញ្ញប្បទានដើម្បីបង្កើនជីវភាពរស់នៅ ក៏ដូចជាការបង្កើនឱកាសដល់គ្រឹះស្ថានក្នុងការពង្រីកចំណែកទីផ្សារឥណទានដែលមានភាពរឹងមាំ
- ការទទួលយកតែអចលនទ្រព្យ (លំនៅដ្ឋាន ដីធ្លី និង អគារ ជាដើម) ជាទ្រព្យបញ្ចាំ បានបង្កឲ្យអតិថិជនដែលមិនមានអចលនទ្រព្យ តែមានចលនទ្រព្យ មិនអាចមានលទ្ធភាពទទួលបានឥណទានពីគ្រឹះស្ថាន ។ គ្រឹះស្ថានគួរពិចារណាលើចលនទ្រព្យផ្សេងទៀតក្រៅពីអចលនទ្រព្យ ដូចជា ៖
    - ការផ្តល់ហិរញ្ញប្បទានសារពើភ័ណ្ឌ (Inventory Financing) គឺជាប្រភេទមួយនៃការផ្តល់ឥណទានឬប្រាក់កម្ចីរយៈពេលខ្លី ដោយទទួលយកសារពើភ័ណ្ឌជាវត្ថុបញ្ចាំសម្រាប់ប្រាក់កម្ចី ប្រសិនបើអ្នកខ្ចីប្រាក់មិនមានលទ្ធភាពសង
    - ការផ្តល់ហិរញ្ញប្បទានតាមបញ្ចាំស្តុក (Warehouse Receipt Financing) គឺជាទម្រង់មួយនៃការផ្តល់ហិរញ្ញប្បទានសារពើភ័ណ្ឌ ដោយអតិថិជនប្រើប្រាស់វិក័យប័ត្របញ្ជាក់ពីទំនិញដែលខ្លួនមាននៅក្នុងឃ្លាំងស្តុក ជាវត្ថុបញ្ចាំសម្រាប់ធានាលើប្រាក់កម្ចីរបស់ខ្លួន ហើយឃ្លាំងស្តុកទំនិញ

នេះអាចជាឃ្លាំងសាធារណៈ ដែលបានទទួលស្គាល់ដោយអ្នកផ្តល់ប្រាក់កម្ចី ឬ ជាឃ្លាំងដែលស្ថិតនៅក្នុងទីតាំងរបស់អ្នកខ្ចី គ្រប់គ្រងដោយភាគីឯករាជ្យទីបី ។

- ការបង្កើនការយល់ដឹងរបស់កសិករ សមាគមកសិករ និងរោងម៉ាស៊ីនកិនស្រូវ អំពីផលិតផលនិងសេវាហិរញ្ញវត្ថុ ក៏ដូចជាការប្រើប្រាស់ធនធានហិរញ្ញវត្ថុឲ្យបានត្រឹមត្រូវ ដើម្បីជំរុញឲ្យការប្រើប្រាស់ធនធានហិរញ្ញវត្ថុ ឲ្យមានប្រសិទ្ធភាពនិងចំគោលដៅ
- ការបណ្តុះបណ្តាលជាមូលដ្ឋានដល់កសិករ សមាគមកសិករ និងរោងម៉ាស៊ីនកិនស្រូវ អំពីការរៀបចំផែនការអាជីវកម្ម ការកត់ត្រា និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីបង្កើនជំនឿទុកចិត្តពីគ្រឹះស្ថានផ្តល់ហិរញ្ញប្បទាន
- ការខិតខំស្វែងយល់បន្ថែមរបស់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អំពីដំណើរការនិងផលិតផលស្រូវ-អង្ករ ដើម្បីពង្រឹងគុណភាពនៃការផ្តល់ឥណទានលើវិស័យនេះ
- ការបង្កើនផ្តល់ប្រាក់កម្ចីជាប្រាក់រៀល ដែលអាចសម្រួលដល់ប្រតិបត្តិការទិញសម្ភារៈកសិកម្ម និងវត្ថុធាតុដើមរបស់កសិករ ដោយសារប្រតិបត្តិការភាគច្រើនទូទាត់ជាប្រាក់រៀល ។

ជាមួយគ្នាផងដែរ ការចូលរួមពីស្ថាប័ននិងភាគីពាក់ព័ន្ធផ្សេងទៀត ក៏អាចនឹងបង្កើនលទ្ធភាពដល់កសិករក្នុងការទទួលបានហិរញ្ញប្បទានពីគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ផងដែរ ដូចជា ៖

- ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធ ដូចជា ប្រព័ន្ធធារាសាស្ត្រ និង ផ្លូវថ្នល់ ជាដើម ដើម្បីសម្រួលដល់ការដាំដុះ និងដឹកជញ្ជូនដំណាំស្រូវ ដែលជាកត្តាសំខាន់ក្នុងការបង្កើនផលនិងការកាត់បន្ថយថ្លៃដើមផលិត
- ការធានាបាននូវទីផ្សារនិងតម្លៃស្រូវដែលអាចទទួលយកបាន ចំពោះផលិតផលស្រូវដែលកសិករប្រមូលបាន ព្រមទាំងការពង្រីកទីផ្សារសម្រាប់នាំចេញអង្ករ
- ការផ្តល់សិទ្ធិកាន់កាប់លើអចលនទ្រព្យតាមរយៈការចុះបញ្ជីដីធ្លីរបស់ប្រជាជន ជាពិសេសនៅតំបន់ជនបទ ដែលជំរុញឲ្យកសិករងាយស្រួលប្រើប្រាស់ប័ណ្ណកម្មសិទ្ធិអចលនទ្រព្យ សម្រាប់ជាវត្ថុបញ្ចាំក្នុងការខ្ចីប្រាក់ពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

❋❋❋❋❋❋❋❋❋❋

# អត្រាប្តូរប្រាក់ប្រចាំខែ

| ចុងខែ | អត្រាទីផ្សារ | | | | | អត្រាផ្លូវការ | | | គម្លាតអត្រាមធ្យម អត្រាផ្លូវការ-ទីផ្សារ | |
|---|---|---|---|---|---|---|---|---|---|---|
| | អត្រា ទិញ | អត្រា លក់ | មធ្យម | ប្រែប្រួលប្រចាំខែ +/- | ប្រែប្រួលប្រចាំខែ % | មធ្យម | ប្រែប្រួលប្រចាំខែ +/- | ប្រែប្រួលប្រចាំខែ % | +/- | % |
| **២០១៣** | | | | | | | | | | |
| តុលា | ៤.០៣១ | ៤.០៣៨ | ៤.០៣៥ | -៣៦ | -០,៨៩ | ៤.០៤០ | -២២ | -០,៥៤ | ៦ | ០,១៤ |
| វិច្ឆិកា | ៣.៩៩៤ | ៤.០០៥ | ៤.០០០ | -៣៧ | -០,៩២ | ៣.៩៩៥ | -៤៥ | -១,១១ | -៥ | -០,១១ |
| ធ្នូ | ៤.០០៣ | ៤.០១៣ | ៤.០០៨ | ៩ | ០,២៣ | ៣.៩៩៥ | ០ | ០,០០ | -១៣ | -០,៣២ |
| **២០១៤** | | | | | | | | | | |
| មករា | ៣.៩៩៥ | ៤.០០៣ | ៣.៩៩៩ | -៨ | -០,២០ | ៣.៩៩៥ | ០ | ០,០០ | -៤ | -០,១០ |
| កុម្ភៈ | ៣.៩៨១ | ៣.៩៨៩ | ៣.៩៨៥ | -១៤ | -០,៣៥ | ៣.៩៨០ | -១៥ | -០,៣៨ | -៥ | -០,១៣ |
| មីនា | ៣.៩៩៥ | ៤.០០២ | ៣.៩៩៩ | ១៤ | ០,៣៥ | ៤.០១៥ | ៣៥ | ០,៨៨ | ១៧ | ០,៤១ |
| មេសា | ៤.០១២ | ៤.០២២ | ៤.០១៧ | ១៧ | ០,៤៣ | ៤,០១៥ | ០ | ០,០០ | -២ | -០,០៥ |
| ឧសភា | ៤.០៤៣ | ៤.០៥៣ | ៤.០៤៨ | ៣១ | ០,៧៧ | ៤.០៣២ | ១៧ | ០,៤២ | -១៦ | -០,៤០ |
| មិថុនា | ៤.០៤៧ | ៤.០៥៣ | ៤.០៥០ | ៤ | ០,១០ | ៤.០៤០ | ៨ | ០,២០ | -១០ | -០,២៥ |
| កក្កដា | ៤.០៥៤ | ៤.០៦៣ | ៤.០៥៩ | ៧ | ០,១៧ | ៤.០៥០ | ១០ | ០,២៥ | -៩ | -០,២១ |
| សីហា | ៤.០៧៤ | ៤.០៨៣ | ៤.០៧៩ | ២០ | ០,៤៩ | ៤.០៦៥ | ១៥ | ០,៣៧ | -១៤ | -០,៣៣ |
| កញ្ញា | ៤.០៨៧ | ៤.០៩៦ | ៤.០៩២ | ១៣ | ០,៣២ | ៤.០៨៥ | ២០ | ០,៤៩ | -៧ | -០,១៦ |
| តុលា | ៤.០៧៤ | ៤.០៨០ | ៤.០៧៧ | -១៣ | -០,៣២ | ៤.០៧៦ | -៩ | -០,២២ | -១ | -០,០២ |
| វិច្ឆិកា | ៤.០៥៥ | ៤.០៦២ | ៤.០៥៩ | -១៩ | -០,៤៧ | ៤.០៦៣ | -១៣ | -០,៣២ | ៥ | ០,១១ |
| ធ្នូ | ៤.០៦៤ | ៤.០៧៣ | ៤.០៦៩ | ៩ | ០,២២ | ៤.០៧៥ | ១២ | ០,៣០ | ៧ | ០,១៦ |
| **២០១៥** | | | | | | | | | | |
| មករា | ៤.០៥៩ | ៤.០៦៧ | ៤.០៦៣ | -៥ | -០,១២ | ៤.០៥០ | -២៥ | -០,៦១ | -១៣ | -០,៣២ |
| កុម្ភៈ | ៤.០៣២ | ៤.០៤០ | ៤.០៣៦ | -២៧ | -០,៦៧ | ៤.០២៧ | -២៣ | -០,៥៧ | -៩ | -០,២២ |
| មីនា | ៤.០១០ | ៤.០១៨ | ៤.០១៤ | -២២ | -០,៥៥ | ៤.០១០ | -១៧ | -០,៤២ | -៤ | -០,១០ |
| មេសា | ៤.០៦៦ | ៤.០៧៦ | ៤.០៧១ | ៥៦ | ១,៤០ | ៤.០៥០ | ៤០ | ១,០០ | -២១ | -០,៥២ |
| ឧសភា | ៤.០៨៦ | ៤.០៩៦ | ៤.០៩១ | ២០ | ០,៤៩ | ៤.០៦៨ | ១៨ | ០,៤៤ | -២៣ | -០,៥៦ |
| មិថុនា | ៤.០៩៤ | ៤.១០១ | ៤.០៩៨ | ៨ | ០,២០ | ៤.០៩៨ | ៣០ | ០,៧៤ | ១ | ០,០១ |
| កក្កដា | ៤.១១៣ | ៤.១២១ | ៤.១១៧ | ១៩ | ០,៤៦ | ៤.១១៣ | ១៥ | ០,៣៧ | -៤ | -០,១០ |
| សីហា | ៤.០៩៨ | ៤.១០៥ | ៤.១០២ | -១៥ | -០,៣៦ | ៤.០៨១ | -៣២ | -០,៧៨ | -២១ | -០,៥០ |
| កញ្ញា | ៤.០៧៤ | ៤.០៨៧ | ៤.០៨១ | -២៤ | -០,៥៩ | ០.០៧៦ | -៥ | -០,១២ | -៥ | -០,១១ |
| តុលា | ០.០៤៩ | ៤.០៦០ | ៤.០៥៥ | -២៥ | -០,៦១ | ៤.០៦១ | -១៥ | -០.៣៧ | ៧ | ០,១៦ |
| វិច្ឆិកា | ៤.០៤៤ | ៤.០៥៦ | ៤.០៥០ | -៥ | -០,១២ | ៤.០៤៤ | -១៧ | -០,៤២ | -៦ | -០,១៥ |
| ធ្នូ | ៤.០៤៨ | ៤.០៥៥ | ៤.០៥២ | ៤ | ០,១០ | ៤.០៥០ | ៦ | ០,១៥ | -២ | -០,០៤ |
| **២០១៦** | | | | | | | | | | |
| មករា | ៤.០៣៧ | ៤.០៤៥ | ៤.០៤១ | -១១ | -០,២៧ | ៤.០៣៧ | -១៣ | -០,៣២ | -៤ | -០,១០ |
| កុម្ភៈ | ៤.០១០ | ៤.០១៦ | ៤.០១៣ | -២៧ | -០,៦៧ | ៤.០០៨ | -២៩ | -០,៧២ | -៥ | -០,១២ |
| មីនា | ៤.០១០ | ៤.០១៨ | ៤.០១៤ | ០ | ០,០០ | ៤.០០៦ | -២ | -០,០៥ | -៨ | -០,២០ |
| មេសា | ៤.០៦១ | ៤.០៧៣ | ៤.០៦៧ | ៥១ | ១,២៧ | ៤.០៦០ | ៥៤ | ១,៣៥ | -៧ | -០,១៧ |
| ឧសភា | ៤.០៨២ | ៤.០៩១ | ៤.០៨៧ | ២១ | ០,៥២ | ៤.០៨៥ | ២៥ | ០,៦២ | -២ | -០,០៤ |
| មិថុនា | ៤.០៨១ | ៤.០៩១ | ៤.០៨៦ | -១ | -០,០២ | ៤.០៨៤ | -១ | -០,០២ | -២ | -០,០៥ |
| កក្កដា | ៤.០៩៤ | ៤.១០៣ | ៤.០៩៩ | ១៣ | ០,៣២ | ៤.០៩៧ | ១៣ | ០,៣២ | -២ | -០,០៤ |
| សីហា | ៤.០៩៦ | ៤.១០៦ | ៤.១០១ | ២ | ០,០៥ | ៤.០៩៦ | -១ | -០,០២ | -៥ | -០,១២ |
| កញ្ញា | ៤.០៨៦ | ៤.០៩៧ | ៤.០៩២ | -១១ | -០,២៧ | ៤.០៨០ | -១៦ | -០,៣៩ | -១២ | -០,២៩ |
| តុលា | ៤.០៥៣ | ៤.០៦១ | ៤.០៥៧ | -៣៣ | -០,៨១ | ៤.០៥០ | -៣០ | -០,៧៣ | -៧ | ០,១៧ |
| វិច្ឆិកា | ៤.០៣២ | ៤.០៤១ | ៤.០៣៧ | -២១ | -០,៥២ | ៤.០៣០ | -២០ | -០,៥០ | -៧ | -០,១៧ |
| ធ្នូ | | | | | | | | | | |

## MONTHLY EXCHANGE RATE

| End month | Parallel Market Rate | | | | | Official Exchannge Rate | | | Spread | |
|---|---|---|---|---|---|---|---|---|---|---|
| | Purchase | Sale | Midpoint | Monthly Change | | Midpoint | Monthly Change | | Official-Market | |
| | | | | +/- | % | | +/- | % | +/- | % |
| **2013** | | | | | | | | | | |
| October | 4,031 | 4,038 | 4,035 | -36 | -0.89 | 4,040 | -22 | -0.54 | 6 | 0.14 |
| November | 3,994 | 4,005 | 4,000 | -37 | -0.92 | 3,995 | -45 | -1.11 | -5 | -0.11 |
| December | 4,003 | 4,013 | 4,008 | 9 | 0.23 | 3,995 | 0 | 0.00 | -13 | -0.32 |
| **2014** | | | | | | | | | | |
| January | 3,995 | 4,003 | 3,999 | -8 | -0.20 | 3,995 | 0 | 0.00 | -4 | -0.10 |
| February | 3,981 | 3,989 | 3,985 | -14 | -0.35 | 3,980 | -15 | -0.38 | -5 | -0.13 |
| March | 3,995 | 4,002 | 3,999 | 14 | 0.35 | 4,015 | 35 | 0.88 | 17 | 0.41 |
| April | 4,012 | 4,022 | 4,017 | 17 | 0.43 | 4,015 | 0 | 0.00 | -2 | -0.05 |
| May | 4,043 | 4,053 | 4,048 | 31 | 0.77 | 4,032 | 17 | 0.42 | -16 | -0.40 |
| June | 4,047 | 4,053 | 4,050 | 4 | 0.10 | 4,040 | 8 | 0.20 | -10 | -0.25 |
| July | 4,054 | 4,063 | 4,059 | 7 | 0.17 | 4,050 | 10 | 0.25 | -9 | -0.21 |
| August | 4,074 | 4,083 | 4,079 | 20 | 0.49 | 4,065 | 15 | 0.37 | -14 | -0.33 |
| September | 4,087 | 4,096 | 4,092 | 13 | 0.32 | 4,085 | 20 | 0.49 | -7 | -0.16 |
| October | 4,074 | 4,080 | 4,077 | -13 | -0.32 | 4,076 | -9 | -0.22 | -1 | -0.02 |
| November | 4,055 | 4,062 | 4,059 | -19 | -0.47 | 4,063 | -13 | -0.32 | 5 | 0.11 |
| December | 4,064 | 4,073 | 4,069 | 9 | 0.22 | 4,075 | 12 | 0.30 | 7 | 0.16 |
| **2015** | | | | | | | | | | |
| January | 4,059 | 4,067 | 4,063 | -5 | -0.12 | 4,050 | -25 | -0.61 | -13 | -0.32 |
| February | 4,032 | 4,040 | 4,036 | -27 | -0.67 | 4,027 | -23 | -0.57 | -9 | -0.22 |
| March | 4,010 | 4,018 | 4,014 | -22 | -0.55 | 4,010 | -17 | -0.42 | -4 | -0.10 |
| April | 4,066 | 4,076 | 4,071 | 56 | 1.40 | 4,050 | 40 | 1.00 | -21 | -0.52 |
| May | 4,086 | 4,096 | 4,091 | 20 | 0.49 | 4,068 | 18 | 0.44 | -23 | -0.56 |
| June | 4,094 | 4,101 | 4,098 | 8 | 0.20 | 4,098 | 30 | 0.74 | 1 | 0.01 |
| July | 4,113 | 4,121 | 4,117 | 19 | 0.46 | 4,113 | 15 | 0.37 | -4 | -0.10 |
| August | 4,098 | 4,105 | 4,102 | -15 | -0.36 | 4,081 | -32 | -0.78 | -21 | -0.50 |
| September | 4,074 | 4,087 | 4,081 | -24 | -0.59 | 4,076 | -5 | -0.12 | -5 | -0.11 |
| October | 4,049 | 4,060 | 4,055 | -25 | -0.61 | 4,061 | -15 | -0.37 | 7 | 0.16 |
| November | 4,044 | 4,056 | 4,050 | -5 | -0.12 | 4,044 | -17 | -0.42 | -6 | -0.15 |
| December | 4,048 | 4,055 | 4,052 | 4 | 0.10 | 4,050 | 6 | 0.15 | -2 | -0.04 |
| **2016** | | | | | | | | | | |
| January | 4,037 | 4,045 | 4,041 | -11 | -0.27 | 4,037 | -13 | -0.32 | -4 | -0.10 |
| February | 4,010 | 4,016 | 4,013 | -27 | -0.67 | 4,008 | -29 | -0.72 | -5 | -0.12 |
| March | 4,010 | 4,018 | 4,014 | 0 | 0.00 | 4,006 | -2 | -0.05 | -8 | -0.20 |
| April | 4,061 | 4,073 | 4,067 | 51 | 1.27 | 4,060 | 54 | 1.35 | -7 | -0.17 |
| May | 4,082 | 4,091 | 4,087 | 21 | 0.52 | 4,085 | 25 | 0.62 | -2 | -0.04 |
| June | 4,081 | 4,091 | 4,086 | -1 | -0.02 | 4,084 | -1 | -0.02 | -2 | -0.05 |
| July | 4,094 | 4,103 | 4,099 | 13 | 0.32 | 4,097 | 13 | 0.32 | -2 | -0.04 |
| August | 4,096 | 4,106 | 4,101 | 2 | 0.05 | 4,096 | -1 | -0.02 | -5 | -0.12 |
| September | 4,086 | 4,097 | 4,092 | -11 | -0.27 | 4,080 | -16 | -0.39 | -12 | -0.29 |
| October | 4,053 | 4,061 | 4,057 | -33 | -0.81 | 4,050 | -30 | -0.73 | -7 | 0.17 |
| November | 4,032 | 4,041 | 4,037 | -21 | -0.52 | 4,030 | -20 | -0.50 | -7 | -0.17 |
| December | | | | | | | | | | |

# តារាង: **អត្រាការប្រាក់លើប្រាក់បញ្ញើ** (ខែតុលា ឆ្នាំ២០១៦)

| ល.រ | ឈ្មោះធនាគារ | ប្រាក់បញ្ញើជារៀល (%) | | | | | ប្រាក់បញ្ញើជាដុល្លារអាមេរិក (%) | | | | | ប្រាក់បញ្ញើជារូបិយប័ណ្ណផ្សេងៗ (%) | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សំចៃ | មានកាលកំណត់ | | | | សំចៃ | មានកាលកំណត់ | | | | សំចៃ | មានកាលកំណត់ | | | |
| | | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ ខែ | ៦ ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| ១ | អេស៊ីលីដា | ១,២៥ | ៣,០០ | ៥,០០ | ៦,០០ | ៧,០០ | ០,៥០ | ១,៥០ | ២,៥០ | ៣,៧៥ | ៥,០០ | ០,១៥ | ០,៥០ | ១,៥០ | ២,២៥ | ៣,២៥ |
| ២ | កម្ពុជាសាធារណៈ | ០,៥០ | ១,០០ | ១,២៥ | ១,៧៥ | ២,៥០ | ០,៥០ | ១,២៥ | ២,០០ | ៣,០០ | ៣,៧៥ | ០,៥០ | | | | |
| ៣ | កាណាឌីយ៉ា | ២,០០ | | ៥,០០ | ៦,០០ | ៧,០០ | ០,៧៥ | ២,០០ | ២,៥០ | ៣,៥០ | ៤,៧៥ | ០,២៥ | ១,០០ | ១,៥០ | ២,០០ | ២,៥០ |
| ៤ | អេអ៊ិនហ្សេតរូយ៉ាល់ | | ៣,២៥ | ៣,៥០ | ៤,០០ | ៥,៥០ | ០,៥០ | ០,៣០ | ០,៥០ | ១,៥០ | ២,០០ | | | | | |
| ៥ | ពាណិជ្ជកម្មក្រៅប្រទេស | ១,៥០ | ៣,០០ | ៥,០០ | ៦,០០ | ៧,០០ | ០,៧៥ | ១,៥០ | ២,៥០ | ៣,៧៥ | ៥,០០ | | | | | |
| ៦ | អភិវឌ្ឍន៍និងវិនិ. | | ៣,៥០ | ៤,៦០ | ៥,៥៥ | ៦,៥០ | ០,៧៥ | ២,២៥ | ៣,០០ | ៤,២៥ | ៥,៥០ | | | | | |
| ៧ | មេយប៊ែង | | | | | | ១,៥០ | ២,៥០ | ៣,០០ | ៤,០០ | ៥,០០ | | | | | |
| ៨ | ធនាគារវឌ្ឍនៈ | ០,៥០ | ១,៥០ | ២,០០ | ៣,០០ | ៣,៥០ | ០,៥០ | ១,៥០ | ២,០០ | ៣,០០ | ៣,៥០ | | | | | |
| ៩ | សហពាណិជ្ជ | ០,៧៥ | | | | | ១,០០ | | ១,៥០ | ២,០០ | ២,៥០ | | | | | |
| ១០ | វឌ្ឍនៈអាស៊ី | ០,៧៥ | | | | | ០,៧៥ | ២,២៥ | ៣,២៥ | ៤,២៥ | ៥,២៥ | | | | | |
| ១១ | កម្ពុជាពាណិជ្ជ | ០,៣៥ | | ១,៥០ | ១,៥០ | ១,៥០ | ០,៣៥ | | ១,៥០ | ១,៥០ | ១,៥០ | ០,៣៥ | | ១,៥០ | ១,៥០ | ១,៥០ |
| ១២ | ពាណិជ្ជកម្មទី១ | | | | | | ០,៤០ | ២,០១ | | | | | | | | |
| ១៣ | ក្រុងថៃមហាជន | | | | | | ០,១០ | | ០,៥០ | ០,៧៥ | ១,០០ | | | | | |
| ១៤ | កម្ពុជាអាស៊ី | | | | | | ២,០០ | ២,៥០ | ៣,៨០ | ៤,៨០ | ៥,៨០ | | | | | |
| ១៥ | មេគង្គកម្ពុជា | ៣,៧៥ | | | | ៨,០០ | ២,០០ | | ២,៧៥ | ៣,៥០ | ៤,០០ | | | | | |
| ១៦ | ធនាគារកាថេ | | | | | | ០,៥០ | | ២,៥០ | ៣,០០ | ៤,០០ | | | | | |
| ១៧ | ឥណ្ឌា | | | | | | ០,៧៥ | ១,០០ | ២,២៥ | ៣,០០ | ៤,០០ | | | | | |
| ១៨ | ម៉ារ៉ូហាន់ | ៤,០០ | ៥,០០ | ៦,០០ | ៧,០០ | ៩,៥០ | ៣,០០ | ៤,៥០ | ៥,០០ | ៥,៥០ | ៧,៥០ | ៣,០០ | ៤,៥០ | ៥,០០ | ៥,៥០ | ៧,៥០ |
| ១៩ | ប៊ូយ៉ុងខ្មែរ | ១,០០ | ៣,០០ | ៤,០០ | ៥,០០ | ៦,០០ | ០,៥០ | ១,៥០ | ២,៥០ | ៣,០០ | ៣,៥០ | | | | | |
| ២០ | ស៊ីនហានខ្មែរ | | | | | | ០,២៥ | ១,២៥ | ២,២៥ | ៣,៥០ | ៤,២៥ | | | | | |
| ២១ | គូកមិនកម្ពុជា | ០,៧០ | ១,៧០ | ២,៥០ | ៣,២០ | ៣,៦០ | ០,៥០ | ១,២០ | ២,០០ | ២,៧០ | ៣,១០ | | | | | |
| ២២ | អរអេជប៊ី | ១,៥០ | ៣,៥០ | ៤,០០ | ៥,០០ | ៦,០០ | ១,០០ | ២,០០ | ២,៥០ | ៣,៥០ | ៤,៧៥ | | | | | |
| ២៣ | ហ្វីលិប | | | | | | ១,០០ | ២,២៥ | ៣,០០ | ៤,២៥ | ៥,៥០ | | | | | |
| ២៤ | ភ្នំពេញ ពាណិជ្ជ | | | | | | ២,៦០ | ២,៥០ | ៤,០០ | ៥,០០ | ៦,០០ | | | | | |
| ២៥ | សាខម | ០,៥០ | ២,២៥ | ៣,០០ | ៣,៥០ | ៥,២៥ | ០,៥០ | ២,២៥ | ៣,០០ | ៣,៥០ | ៥,២៥ | | | | | |
| ២៦ | ស៊ីអាយអិមប៊ី | | | | | | ១,៥០ | ១,៥០ | ២,៥០ | ៣,២៥ | ៤,០០ | | ២,៥០ | ៣,៥០ | ៤,២៥ | ៥,០០ |
| ២៧ | អាហ្វ្រី | ០,៥០ | ២,០០ | ៣,០០ | ៣,៧៥ | ៤,៥០ | ០,៥០ | ១,៥០ | ២,៥០ | ៣,២៥ | ៣,៧៥ | | | | | |
| ២៨ | ធនាគារ ចិន | ០,១៣ | ០,១៣ | ០,១៣ | ០,១៣ | ០,១៣ | ០,៥០ | ១,២៥ | ២,២៥ | ២,៧៥ | ៣,២៥ | ០,៣៥ | ១,៥០ | ៣,២៥ | ៣,១៥ | ៣,០០ |
| ២៩ | មេហ្គា | | | | | | ០,០២ | ០,៤០ | ០,៦០ | ០,៨០ | ១,១០ | | | | | |
| ៣០ | អាយស៊ីប៊ីស៊ី | | | | | | ០,៥០ | ១,៥០ | ២,២៥ | ៣,០០ | ៣,៥០ | | | ២,៩០ | ៣,០០ | ៣,១០ |
| ៣១ | អ៊ឹមប៊ី ភីអិលស៊ី | ០,៧៥ | ៣,៥០ | ៤,៥០ | ៥,០០ | ៦០០ | ០,៥០ | ២,៧៥ | ៣,២០ | ៤,២០ | ៥,០០ | | | | | |
| ៣២ | អេសហេជប៊ី | ១,០០ | ២,៨៥ | ៣,៧៥ | ៥,៤៥ | ៥,៥០ | ១,០០ | ៣,៧៥ | ៤,៧៥ | ៤,៨៥ | ៥,៧៥ | | | | | |
| ៣៣ | តៃវ៉ាន់ខូអបរេធីវ | | | | | | ០,១៣ | ០,៣០ | ០,៣៥ | ០,៧០ | ១,១០ | | | | | |
| ៣៤ | ហុងលីអ៊ុង | ១,០០ | | | | | ០,៧៥ | ១,៧៥ | ២,៥០ | ៣,៧៥ | ៤,៧៥ | | | | | |
| ៣៥ | ប្រែសណីយ៍ | ២,០០ | ៣០០ | ៤,០០ | ៥,០០ | ៧,០០ | ១,២៥ | ២,០០ | ៣,០០ | ៤,០០ | ៦,០០ | ២,០០ | ៣,០០ | ៤,០០ | ៥,០០ | ៧,០០ |
| ៣៦ | ធនាគារបាងកក | ០,២៥ | ០,៧៥ | ១,០០ | ១,៥០ | ២,០០ | ០,៥០ | ១,០០ | ១,៥០ | ២,៥០ | ៣,៥០ | ០,១៣ | | ០,២៥ | ០,៥០ | ០,៧៥ |
| ៣៧ | អភិវឌ្ឍន៍ជនបទ | ១,៥០ | ៣,៥០ | ៤,០០ | ៥,០០ | ៦,០០ | ១,០០ | ៣,០០ | ៣៥០ | ៤,០០ | ៥,០០ | | | | | |
| ៣៨ | ខេមខូ លីមីតធីត | | | | | | | | | | | | | | | |
| ៣៩ | ភីអេចអេសអឹមអ៊ី | | | | | | | | | | | | | | | |
| ៤០ | វិនិយោគទីមួយ | | | | | | | | | | | | | | | |
| ៤១ | អានកូ | | | | | | | | | | | | | | | |
| ៤២ | តូម៉ាតូ | | | | | | | | | | | | | | | |
| ៤៣ | អង្គរ កាពីតាល | | | | | | | | | | | | | | | |
| ៤៤ | ខេមកាប់ភីថល | | | | | | | | | | | | | | | |
| ៤៥ | ឆីហ្វ | | | | | | | | | | | | | | | |
| ៤៦ | អកស៍ឡេ | | | | | | | | | | | | | | | |
| ៤៧ | ធនាគារឯកទេសវីង | | | | | | | | | | | | | | | |
| ៤៨ | ធនាគារឯកទេសអ៊ីអន | | | | | | | | | | | | | | | |
| ៤៩ | ធនាគារឯកទេសខ្មែរ | | | | | | | | | | | | | | | |
| ៥០ | អាស៊ីប៉ាស៊ីហ្វិក | | | | | | | | | | | | | | | |
| **មធ្យមភាគ** | | ១,១៣ | ២,៥៨ | ៣,៣៩ | ៤,១៧ | ៥,២៤ | ០,៨៤ | ១,៨៣ | ២,៤៧ | ៣,២៧ | ៤,១៤ | ០,៨៤ | ២,១៧ | ២,៦០ | ៣,៣៣ | ៣,៧៣ |

## Table: INTEREST RATE ON DEPOSITS ( in October, 2016)

| No. | NAME OF BANKS | Deposit in Riel (%) | | | | | Deposit in USD (%) | | | | | Deposit in Other Foreign Currency (%) | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | Saving | Fixed | | | | Saving | Fixed | | | | Saving | Fixed | | | |
| | | | 1M. | 3M. | 6M. | 12M. | | 1M. | 3M. | 6M. | 12M. | | 1M. | 3M. | 6M. | 12M. |
| 1 | ACLEDA | 1.25 | 3.00 | 5.00 | 6.00 | 7.00 | 0.50 | 1.50 | 2.50 | 3.75 | 5.00 | 0.15 | 0.50 | 1.50 | 2.25 | 3.35 |
| 2 | Cambodian Public | 0.50 | 1.00 | 1.25 | 1.75 | 2.50 | 0.50 | 1.25 | 2.00 | 3.00 | 3.75 | 0.50 | | | | |
| 3 | Canadia Bank Ltd. | 2.00 | | 5.00 | 6.00 | 7.00 | 0.75 | 2.00 | 2.50 | 3.50 | 4.75 | 0.25 | 1.00 | 1.50 | 2.00 | 2.50 |
| 4 | ANZ Royal | | 3.25 | 3.50 | 4.00 | 5.50 | 0.50 | 0.30 | 0.50 | 1.50 | 2.00 | | | | | |
| 5 | Foreign Trade | 1.50 | 3.00 | 5.00 | 6.00 | 7.00 | 0.75 | 1.50 | 2.50 | 3.75 | 5.00 | | | | | |
| 6 | Investment & Develop | | 3.50 | 4.60 | 5.55 | 6.50 | 0.75 | 2.25 | 3.00 | 4.25 | 5.50 | | | | | |
| 7 | May Bank | | | | | | 0.50 | 2.50 | 3.00 | 4.00 | 5.00 | | | | | |
| 8 | Vattanac Bank | 0.50 | 1.50 | 2.00 | 3.00 | 3.50 | 0.50 | 1.50 | 2.00 | 3.00 | 3.50 | | | | | |
| 9 | Union Commercial | 0.75 | | | | | 1.00 | | 1.50 | 2.00 | 2.50 | | | | | |
| 10 | Advanced Bank of Asia | 0.75 | | | | | 0.75 | 2.50 | 3.25 | 4.25 | 5.25 | | | | | |
| 11 | CambodianCommercial | 0.35 | | 1.50 | 1.50 | 1.50 | 0.35 | | 1.50 | 1.50 | 1.50 | 0.35 | | 1.50 | 1.50 | 1.50 |
| 12 | First Commercial | | | | | | 0.40 | 2.01 | | | | | | | | |
| 13 | Krung Thai | | | | | | 0.10 | | 0.50 | 0.75 | 1.00 | | | | | |
| 14 | Cambodia Asia | | | | | | 2.00 | 2.50 | 3.80 | 4.80 | 5.80 | | | | | |
| 15 | Cambodia Mekong | 3.75 | | | | 8.00 | 2.00 | | 2.75 | 3.50 | 4.00 | | | | | |
| 16 | Cathay United | | | | | | 0.50 | | 2.50 | 3.00 | 4.00 | | | | | |
| 17 | Bank of India | | | | | | 0.75 | 1.00 | 2.25 | 3.00 | 4.00 | | | | | |
| 18 | Maruhan Japan | 4.00 | 5.00 | 6.00 | 7.00 | 9.50 | 3.00 | 4.50 | 5.00 | 5.50 | 7.50 | 3.00 | 4.50 | 5.00 | 5.50 | 7.50 |
| 19 | Booyoung Khmer | 1.00 | 3.00 | 4.00 | 5.00 | 6.00 | 0.50 | 1.50 | 2.50 | 3.00 | 3.50 | | | | | |
| 20 | Shinhan Khmer | | | | | | 0.25 | 1.25 | 2.25 | 3.50 | 4.25 | | | | | |
| 21 | KOOKMIN | 0.70 | 1.70 | 2.50 | 3.20 | 3.60 | 0.50 | 1.20 | 2.00 | 2.70 | 3.10 | | | | | |
| 22 | RHB Indochina | 1.50 | 3.50 | 4.00 | 5.00 | 6.00 | 1.00 | 2.00 | 2.50 | 3.50 | 4.75 | | | | | |
| 23 | Hwang DBS | | | | | | 1.00 | 2.25 | 3.00 | 4.25 | 5.50 | | | | | |
| 24 | Phnom Penh | | | | | | 2.60 | 2.50 | 4.00 | 5.00 | 6.00 | | | | | |
| 25 | SACOMBANK | 0.50 | 2.25 | 3.00 | 3.50 | 5.25 | 0.50 | 2.25 | 3.00 | 3.50 | 5.25 | | | | | |
| 26 | CIMB Bank Plc | | | | | | 1.50 | 1.50 | 2.50 | 3.25 | 4.00 | | 2.50 | 3.50 | 4.25 | 5.00 |
| 27 | AGRI Bank | 0.50 | 2.00 | 3.00 | 3.75 | 4.50 | 0.50 | 1.50 | 2.50 | 3.25 | 3.75 | | | | | |
| 28 | Bank of China | 0.13 | 0.13 | 0.13 | 0.13 | 0.13 | 0.50 | 1.25 | 2.25 | 2.75 | 3.25 | 0.35 | 1.50 | 3.25 | 3.15 | 3.00 |
| 29 | MEGA International | | | | | | 0.02 | 0.40 | 0.60 | 0.80 | 1.10 | | | | | |
| 30 | ICBC Limited | | | | | | 0.50 | 1.50 | 2.25 | 3.00 | 3.50 | | | 2.90 | 3.00 | 3.10 |
| 31 | MB Bank Plc. | 0.75 | 3.50 | 4.50 | 5.00 | 6.00 | 0.50 | 2.75 | 3.20 | 4.20 | 5.00 | | | | | |
| 32 | SHB Plc. | | 2.85 | 3.75 | 5.45 | 5.50 | | 3.75 | 4.75 | 4.85 | 5.75 | | | | | |
| 33 | Taiwan Cooperative | | | | | | 0.13 | 0.30 | 0.35 | 0.70 | 1.10 | | | | | |
| 34 | Hong Leong | 1.00 | | | | | 0.75 | 1.75 | 2.50 | 3.75 | 4.75 | | | | | |
| 35 | Cambodian Post | 2.00 | 3.00 | 4.00 | 5.00 | 7.00 | 1.25 | 2.00 | 3.00 | 4.00 | 6.00 | 2.00 | 3.00 | 4.00 | 5.00 | 7.00 |
| 36 | Bangkok Bank | 0.25 | 0.75 | 1.00 | 1.50 | 2.00 | 0.50 | 1.00 | 1.50 | 2.50 | 3.50 | 0.13 | | 0.25 | | 0.75 |
| 37 | Rural Development | 1.50 | 3.50 | 4.00 | 5.00 | 6.00 | 1.00 | 3.00 | 3.50 | 4.00 | 5.00 | | | | | |
| 38 | Camko Bank Limited. | | | | | | | | | | | | | | | |
| 39 | PHSME Specialized | | | | | | | | | | | | | | | |
| 40 | First Investment | | | | | | | | | | | | | | | |
| 41 | ANCO Specialized | | | | | | | | | | | | | | | |
| 42 | Tomato Specialized | | | | | | | | | | | | | | | |
| 43 | Angkor Capital | | | | | | | | | | | | | | | |
| 44 | CAM Capital | | | | | | | | | | | | | | | |
| 45 | Chief Specialized | | | | | | | | | | | | | | | |
| 46 | Oxley Worldbridge | | | | | | | | | | | | | | | |
| 47 | Wing Specialize Bank | | | | | | | | | | | | | | | |
| 48 | AEON Specialized Bank | | | | | | | | | | | | | | | |
| **Average** | | **1.13** | **2.58** | **3.39** | **4.17** | **5.24** | **0.84** | **1.83** | **2.47** | **3.27** | **4.14** | **0.84** | **2.17** | **2.60** | **3.33** | **3.73** |

## តារាង: អត្រាការប្រាក់លើប្រាក់កម្ចី (ខែតុលា ឆ្នាំ២០១៦)

| ល.រ | ឈ្មោះធនាគារ | ខ្ចីជារៀល (%) | | | | ខ្ចីជាដុល្លារអាមេរិក (%) | | | | ខ្ចីជារូបិយប័ណ្ណផ្សេងៗ (%) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ ខែ | ៣ ខែ | ៦ ខែ | ១២ខែ | ១ ខែ | ៣ ខែ | ៦ ខែ | ១២ខែ | ១ខែ | ៣ខែ | ៦ ខែ | ១២ខែ |
| ១ | អេស៊ីលីដា | | | | ១៥,៦០ | | | | ១០,០០ | | | | ១៥,៦០ |
| ២ | កម្ពុជាសាធារណៈ | | | | | ៩,០០ | ៩,០០ | ៩,០០ | ៩,០០ | | | | |
| ៣ | កាណាឌីយ៉ាចំកាត់ | | | | | | | | ១៣,២០ | | | | |
| ៤ | អេអ៊ិនហ្សេតរូយ៉ាល់ | | | | | | | | ៦,៨៤ | | | | |
| ៥ | ពាណិជ្ជកម្មក្រៅប្រទេស | ១៨,០០ | ១៨,០០ | ១៨,០០ | ១៨,០០ | ១៨,០០ | ១៨,០០ | ១៨,០០ | ១៨,០០ | | | | |
| ៦ | អភិវឌ្ឍន៍ និងវិនិយោគ | | | | | ១០,០០ | ១០,០០ | ១០,០០ | ១០,០០ | | | | |
| ៧ | មេយប៊ែង | | | | | | | | ១២,២៥ | | | | |
| ៨ | ធនាគារវឌ្ឍនៈ | | | | | ១៣,២០ | ១៣,២០ | ១៣,២០ | ១៣,២០ | | | | |
| ៩ | សហពាណិជ្ជ ក.អ | | | | | ១៥,០០ | ១៥,០០ | ១៥,០០ | ១៥,០០ | | | | |
| ១០ | វឌ្ឍនៈអាស៊ី ចំកាត់ | | | | | ៨,៤៦ | ៩,៣៣ | ៩,៥៤ | ១០,០២ | | | | |
| ១១ | កម្ពុជាពាណិជ្ជ ចំកាត់ | | | | | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ |
| ១២ | ពាណិជ្ជកម្មទី១ | | | | | ៧,០៦ | | | ២០,៤០ | | | | |
| ១៣ | ក្រុងថៃមហាជន | | | | | | | | ៦,០០ | | | | |
| ១៤ | កម្ពុជាអាស៊ី ចំកាត់ | | | | | | | | ១២,០០ | | | | |
| ១៥ | មេគង្គកម្ពុជា | | | | | | | | ១២,០០ | | | | |
| ១៦ | ធនាគារកាថេ | | | | | ៦,១៥ | ៦,៨០ | | ១០,៥០ | | | | |
| ១៧ | ឥណ្ឌា សាខាភ្នំពេញ | | | | | | | | ១២,០០ | | | | |
| ១៨ | ម៉ារ៉ូហាន់ | ២១,០០ | ២១,០០ | ២០,៤០ | ២០,៤០ | ២១,០០ | ២១,០០ | ១៥,៦០ | ១៥,៦០ | ២១,០០ | ២១,០០ | ២០,៤០ | ២០,៤០ |
| ១៩ | ប៊ូយ៉ុងខ្មែរ | | | | | | | | ៩,០០ | | | | |
| ២០ | ស៊ីនហានខ្មែរ | | | | | ១៥,០០ | ១៥,០០ | ១៥,០០ | ១៥,០០ | | | | |
| ២១ | គូកមិនកម្ពុជា ភីអិលស៊ី | | | | | ១៤,០០ | ១៤,០០ | ១៤,០០ | ១៤,០០ | | | | |
| ២២ | អ អេជ ប៊ី ឥណ្ឌូឆៃណា | | | | | | | | ១៤,០០ | | | | |
| ២៣ | ហ្វងឌីប៊ីអេស | | | | | | | | ១២,០០ | | | | |
| ២៤ | ភ្នំពេញ ពាណិជ្ជ | | | | | | | | ១៨,០០ | | | | |
| ២៥ | សាខម | | | | | ១៤,៤០ | ១៤,៤០ | ១៤,៤០ | ១៤,៤០ | | | | |
| ២៦ | ស៊ីអាយអិមប៊ី ភីអិលស៊ី | | | | | ១២,០០ | ១២,០០ | ១២,០០ | ១២,០០ | | | | |
| ២៧ | អាប្រ៊្គី សាខាកម្ពុជា | ១៦,៨០ | ១៦,៨០ | ១៦,៨០ | ១៦,៨០ | ១០,០០ | ១០,០០ | ១០,០០ | ១០,០០ | | | | |
| ២៨ | ចិន សាខាភ្នំពេញ | | | | | | | | ១១,០០ | | | | |
| ២៩ | មេហ្គាអ៊ិនធើណេសិនណល | | | | | | | | ៨,០០ | | | | |
| ៣០ | អាយស៊ីប៊ីស៊ី ចំកាត់ | | | | | | | | ៧,៥០ | | | | ៥,១០ |
| ៣១ | អ៊ឹមប៊ី ភីអិលស៊ី | | | | | ១០,២៥ | ១០,២៥ | ១០,២៥ | ១០,២៥ | | | | |
| ៣២ | អេសហេជប៊ី ភីអិលស៊ី | | | | | | | | ៨,០៣ | | | | |
| ៣៣ | តៃវ៉ាន់ខូអបរេធីវ | | | | | | | | ១១,០០ | | | | |
| ៣៤ | ហុងលីអ៊ុង ភីអិលស៊ី | | | | | | | | ១០,០០ | | | | |
| ៣៥ | ប្រៃសណីយ៍ ភីអិលស៊ី | | | ៣១,២០ | ៣៦,០០ | | | ៣០,០០ | ៣១,២០ | | | ២៥,២០ | ៣០,០០ |
| ៣៦ | ធនាគារបាងកក | | | | | ៩,០០ | ៩,០០ | ៩,០០ | ៩,០០ | | | | |
| ៣៧ | អភិវឌ្ឍន៍ជនបទ | | | | ១៤,០០ | | | | ៩,០០ | | | | |
| ៣៨ | ខេមខូ លីមីតធីត | | | | | | | | ២០,០០ | | | | |
| ៣៩ | ភីអេចអែសអឹមអ៊ី | | | | | | | | ១៨,០០ | | | | |
| ៤០ | វិនិយោគទីមួយ | | | | | | | | ២០,៤០ | | | | |
| ៤១ | អានកូ | | | | | | | | ២២,១៧ | | | | |
| ៤២ | តូម៉ាតូ | | | | | | | | ១១,០០ | | | | |
| ៤៣ | អង្គរ កាពីតាល | | | | | | | ២១,០០ | ១៦,៦៧ | | | | |
| ៤៤ | ខេមកាប់ភីថល | | | | | | | | ២៤,០០ | | | | |
| ៤៥ | ឆីហ្វ | | | | | | ១៨,០០ | ១៨,០០ | ១៨,០០ | | | | |
| ៤៦ | អកស៍ឡី | | | | | | | | ៩,៨២ | | | | |
| ៤៧ | ធនាគារឯកទេសវីង | | | | | | | | | | | | |
| ៤៨ | ធនាគារឯកទេសអ៊ីអន | | | | | | | | | | | | |
| | មធ្យមភាគ | ១៨,៦០ | ១៨,៦០ | ២១,៦០ | ២០,១៣ | ១១,៩៧ | ១២,៥៣ | ១៤,០៩ | ១៣,០០ | ១៥,៧៥ | ១៥,៧៥ | ១៨,៧០ | ១៦,៣២ |

## Table: INTEREST RATE ON LOAN (in October 2016)

| No. | NAME OF BANKS | Loan in Riel (%) | | | | Loan in USD (%) | | | | Loan in Other Foreign Currency (%) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | 1 M. | 3 M. | 6 M. | 12 M. | 1 M. | 3 M. | 6 M. | 12 M. | 1 M. | 3 M. | 6 M. | 12 M. |
| 1 | ACLEDA Bank | | | | 15.60 | | | | 10.00 | | | | 15.60 |
| 2 | Cambodian Public | | | | | 9.00 | 9.00 | 9.00 | 9.00 | | | | |
| 3 | Canadia Bank Ltd. | | | | | | | | 13.20 | | | | |
| 4 | ANZ Royal Cambodia | | | | | | | | 6.84 | | | | |
| 5 | Foreign Trade Bank | 18.00 | 18.00 | 18.00 | 18.00 | 18.00 | 18.00 | 18.00 | 18.00 | | | | |
| 6 | Investment & Development | | | | | 10.00 | 10.00 | 10.00 | 10.00 | | | | |
| 7 | May Bank | | | | | | | | 12.25 | | | | |
| 8 | Vattanac Bank | | | | | 13.20 | 13.20 | 13.20 | 13.20 | | | | |
| 9 | Union Commercial Bank Plc. | | | | | | | | | | | | |
| 10 | Advanced Bank of Asia Ltd. | | | | | | 9.33 | 9.54 | 10.02 | | | | |
| 11 | Cambodian Commercial | | | | | 10.50 | 10.50 | 10.50 | 10.50 | 10.50 | 10.50 | 10.50 | 10.50 |
| 12 | First Commercial Bank | | | | | 7.06 | | | | | | | |
| 13 | Krung Thai Bank Public | | | | | | | | 6.00 | | | | 10.00 |
| 14 | Cambodia Asia Bank Ltd. | | | | | | | | 12.00 | | | | |
| 15 | Cambodia Mekong Bank Ltd | | | | | | | | 12.00 | | | | |
| 16 | Cathay United Bank | | | | | 6.15 | 6.80 | | 10.50 | | | | |
| 17 | Bank of India | | | | | | | | 12.00 | 33.60 | 32.40 | 30.00 | 34.80 |
| 18 | Maruhan Japan Bank Plc. | 21.00 | 21.00 | 20.40 | 20.40 | 21.00 | 21.00 | 15.60 | 15.60 | | | | |
| 19 | Booyoung Khmer Bank | | | | | | | | 9.00 | | | | |
| 20 | Shinhan Khmer Bank | | | | | 15.00 | 15.00 | 15.00 | 15.00 | | | | |
| 21 | KOOKMIN | | | | | 14.00 | 14.00 | 14.00 | 14.00 | | | | |
| 22 | OSK Indochina Bank | | | | | | | | 14.00 | | | | |
| 23 | Hwang DBS | | | | | | | | 12.00 | | | | |
| 24 | Commercial Bank | | | | | | | | 18.00 | | | | |
| 25 | SACOMBANK | | | | | 14.00 | 14.00 | 14.00 | 14.00 | | | | |
| 26 | CIMB Bank Plc | | | | | 12.00 | 12.00 | 12.00 | 12.00 | | | | |
| 27 | AGRI Bank | 16.80 | 16.80 | 16.80 | 16.80 | 10.00 | 10.00 | 10.00 | 10.00 | | | | |
| 28 | Bank of China | | | | | | | | 11.00 | | | | |
| 29 | MEGA | | | | | | | | 8.00 | | | | |
| 30 | ICBC Limited | | | | | | | | 7.50 | | 3.50 | | 5.10 |
| 31 | MB Bank Plc. | | | | | 10.25 | 10.25 | 10.25 | 10.25 | | | | |
| 32 | SHB Plc. | | | | | | | | 8.03 | | | | |
| 33 | Taiwan Cooperative | | | | | | | | 11.00 | | | | |
| 34 | Hong Leong Bank | | | | | | | | 10.00 | | | | |
| 35 | Cambodia Post Bank Plc. | | | 31.20 | 36.00 | | | 30.00 | 31.20 | | | 25.20 | 30.00 |
| 36 | Bangkok Bank Plc. | | | | | 9.00 | 9.00 | 9.00 | 9.00 | | | | |
| 37 | Rural Development Bank | | | | 14.00 | | | | 9.00 | | | | |
| 38 | Camko Bank Limited. | | | | | | | | 20.00 | | | | |
| 39 | PHSME Specialized Bank | | | | | | | | 18.00 | | | | |
| 40 | First Investment Specialized | | | | | | | | 20.40 | | | | |
| 41 | ANCO Specialized Bank | | | | | | | | 22.17 | | | | |
| 42 | Tomato Specialized Bank | | | | | | | | 11.00 | | | | |
| 43 | Angkor Capital Specialized | | | | | | | 21.00 | 16.67 | | | | |
| 44 | CAM Capital Specialized | | | | | | | | 24.00 | | | | |
| 45 | Chief Specialized Bank | | | | | | 18.00 | 18.00 | 18.00 | | | | |
| 46 | Oxley Worldbridge Bank | | | | | | | | 9.82 | | | | |
| 47 | Wing Specialize Bank | | | | | | | | | | | | |
| 48 | AEON Specialized Bank | | | | | | | | | | | | |
| | **Average** | **18.60** | **18.60** | **21.60** | **20.13** | **11.97** | **12.53** | **14.09** | **13.00** | **15.75** | **15.75** | **18.70** | **16.32** |

# បញ្ជីឈ្មោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ (ខែធ្នូ ឆ្នាំ២០១៦)

| បញ្ជីឈ្មោះគ្រឹះស្ថានធនាគារ | | | |
|---|---|---|---|
| | | **ធនាគារបង្កើតឡើងតាមច្បាប់ក្នុងស្រុក** | **លេខទូរស័ព្ទ** |
| ១ | ១ | ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា #៣ ផ្លូវលេខ១១៤ កែងផ្លូវ៥៣ សង្កាត់ផ្សារថ្មី១ | (855-23) 724 466 |
| ២ | ២ | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ #១៤៨អាបេសេដេ មហាវិថីព្រះសីហនុ សង្កាត់បឹង កេងកង១ ចំការមន | (855-23) 225 333 |
| ៣ | ៣ | ធនាគារ កម្ពុជាអាស៊ីចំកាត់ #៧៥សេ០៣៦វិថីព្រះសីហនុសង្កាត់វាលវង់ ខណ្ឌ៧មករា | (855-23) 980 000 |
| ៤ | ៤ | ធនាគារ កាណាឌីយ៉ា ក.អ #២៦៥-២៦៧-២៦៩ វិថីព្រះអង្គឌួង (ផ្លូវ១១០) សង្កាត់វត្តភ្នំ | (855-23) 868 222 |
| ៥ | ៥ | ធនាគារ មេគង្គកម្ពុជា #៤៤៥ មហាវិថីព្រះមុនីវង្ស សង្កាត់ ស្រះចក ខណ្ឌដូនពេញ | (855-23) 430 980 |
| ៦ | ៦ | ធនាគារ វឌ្ឍនៈ #៦៦ មហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ភ្នំពេញ | (855-23) 212 727 |
| ៧ | ៧ | ធនាគារ អេស៊ីលីដា ភីអិលស៊ី #៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ ស្រះចក ខណ្ឌដូនពេញ | (855-23) 998 777 |
| ៨ | ៨ | ធនាគារ វិនិយោគនិងអភិវឌ្ឍន៍កម្ពុជា #២៣ វិថីក្រមួនស សង្កាត់ ផ្សារថ្មី២ ខណ្ឌដូនពេញ | (855-23) 210 044 |
| ៩ | ៩ | ធនាគារ ស្ថាបនា #៨៣ មហាវិថីព្រះនរោត្តម សង្កាត់បឹងរាំង ខណ្ឌដូនពេញ | (855-96)311 1111 |
| ១០ | ១០ | ធនាគារ ប៊ូយ៉ុងខ្មែរ #៨៦-៨៨ មហាវិថីព្រះនរោត្តម សង្កាត់ចតុមុខ ខណ្ឌដូនពេញ ភ្នំពេញ | (855-23) 952 888 |
| ១១ | ១១ | ធនាគារ ភ្នំពេញពាណិជ្ជ #៧៦៧-៧៦៩ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ចំការមន | (855-23) 999 500 |
| ១២ | ១២ | ធនាគារ ប្រៃសណីយ៍កម្ពុជា ភីអិលស៊ី #២៦៥-២៦៩ វិថីព្រះអង្គដួង សង្កាត់វត្តភ្នំ ដូនពេញ | (855-23) 226 888 |
| | | **បុត្តសម្ព័ន្ធធនាគារ** | **លេខទូរស័ព្ទ** |
| ១៣ | ១ | ធនាគារ កម្ពុជាពាណិជ្ជ ចំកាត់ #២៦ មហាវិថីព្រះមុនីវង្ស សង្កាត់ ផ្សារថ្មី២ ខណ្ឌដូនពេញ | (855-23) 426 145 |
| ១៤ | ២ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី #២៣ ផ្លូវ១១៤ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ | (855-23) 222 880 |
| ១៥ | ៣ | ធនាគារ មេយប៊ែង សាខាភ្នំពេញ #៤B វិថីក្រមួនស សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ ភ្នំពេញ | (855-23) 210 255 |
| ១៦ | ៤ | ធនាគារ អេអិនហ្សេតរ៉ូយ៉ាល់កម្ពុជា#២0FE-EO វិថីក្រមួនស កែងផ្លូវលេខ៦៧ ផ្សារថ្មី១ | (855-23) 999 000 |
| ១៧ | ៥ | ធនាគារ ស៊ិនហានខ្មែរ #២៧៧មហាវិថីព្រះនរោត្តម សង្កាត់ទន្លេ បាសាក់ ខណ្ឌចំការមន | (855-23) 727 380 |
| ១៨ | ៦ | ធនាគារ គូកមីនកម្ពុជា #៥៥ ផ្លូវ២១៤ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ | (855-23) 999 300 |
| ១៩ | ៧ | ធនាគារ អ.អេច.ប៊ី ឥណ្ឌូឆៃណា #២៦៣ ផ្លូវព្រះអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ភ្នំពេញ | (855-23) 992 833 |
| ២០ | ៨ | ធនាគារ ស៊ីអាយអឹមប៊ី ភីអិលស៊ី #២0AB មហាវិថីព្រះនរោត្តម សង្កាត់ ផ្សារចាស់ ដូនពេញ | (855-23) 988 388 |
| ២១ | ៩ | ធនាគារ សាយហ្គនធឿនទីន(សាខម)ភីអិលស៊ី #៦០មហាវិថីព្រះនរោត្តមសង្កាត់ជ័យជំនះ | (855-23) 223 422 |
| ២២ | ១០ | ធនាគារ ហុងលីអ៊ុង(ខេមបូឌា)ភីអិលស៊ី #២៨ផ្លូវ២១៤ កេងផ្លូវ៥១ សង្កាត់បឹងរាំងខណ្ឌ | (855-23) 999 711 |
| ២៣ | ១១ | សាជីវកម្មធនាគារ កាថេយូណៃធីតកម្ពុជាចំកាត់ #៦៨ វិថីសម្តេចប៉ាន់ ២១៤ សង្កាត់បឹងរាំង | (855-23) 211 211 |
| ២៤ | ១២ | ធនាគារ សហពាណិជ្ជ ក.អ #៦១ ផ្លូវ១៣០ សង្កាត់ផ្សារចាស់ ខណ្ឌ ដូនពេញ ភ្នំពេញ | (855-23) 212 357 |
| ២៥ | ១៣ | ធនាគារ ហ្វីលីព ភីអិលស៊ី #៦១-៦៤មហាវិថីព្រះនរោត្តម សង្កាត់ បឹងកេងកង១ ចំការមន | (855-23) 218 086 |
| ២៦ | ១៤ | ធនាគារ អេសហេជប៊ី #៧០៧ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន | (855-23) 221 900 |
| | | **សាខាធនាគារបរទេស** | **លេខទូរស័ព្ទ** |
| ២៧ | ១ | ធនាគារ ពាណិជ្ជទី១ #៦៦ មហាវិថីព្រះនរោត្តម សង្កាត់ ជ័យជំនះ ខណ្ឌដូនពេញ | (855-23)210026-8 |
| ២៨ | ២ | ធនាគារ ក្រុងថៃចំកាត់មហាជន #១៤៩ផ្លូវលេខ២១៥ សង្កាត់ផ្សារដេប៉ូ១ទួលគោក | (855-23) 882 959 |
| ២៩ | ៣ | ធនាគារ ឥណ្ឌា អគារ១០លេខ២៥៤(F4-R01) មហាវិថី ព្រះមុនីវង្សសង្កាត់បឹងរាំង | (855-23) 219 108 |
